ការិយាល័យឧត្តមស្នងការ
អង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្ស

UN-HABITAT

# សិទ្ធិមាន
# លំនៅដ្ឋាន
# សមរម្យ

អង្គការសហប្រជាជាតិ

សិទ្ធិមនុស្ស

ប័ណ្ណព័ត៌មានលេខ

២១ (Rev.១)

ការិយាល័យឧត្តមស្នងការអង្គការ
សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

UN HABITAT

# សិទ្ធិមានលំនៅដ្ឋានសមរម្យ

ប័ណ្ណព័ត៌មានលេខ ២១/Rev.១

# កំណត់សំគាល់

ចំណងជើងដែលបានប្រើ និងការបង្ហាញខ្លឹមសារនៅក្នុងសៀវភៅនេះ មិនសំដៅដល់ការបញ្ចេញមតិយោបល់ណាមួយ ទោះជាតាមបែបណាក្តី ពីខាងផ្នែកលេខាធិការដ្ឋានអង្គការសហប្រជាជាតិ អំពីស្ថានភាពផ្លូវច្បាប់នៃប្រទេស ដែនដី ទីក្រុង ឬ តំបន់ណាមួយ ឬ ស្ថានភាពនៃអាជ្ញាធរទីតាំងនោះ ឬ អំពីការកំណត់ព្រំដែន ឬ ព្រំប្រទល់ផ្នែកណាមួយខាងលើនេះឡើយ។

*

*          *

ខ្លឹមសារនៅក្នុងសៀវភៅនេះ អាចធ្វើការដកស្រង់ ឬ បោះពុម្ពឡើងវិញបានដោយសេរី ឲ្យតែមានការអនុញ្ញាត ហើយត្រូវបញ្ជូនសៀវភៅមួយក្បាលដែលបានដកស្រង់ខ្លឹមសារមកបោះពុម្ពផ្សាយឡើងវិញនោះ ទៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលមានអាស័យដ្ឋាន Palais des Nations, ៨–១៤ avenue de la Paix, CH–១២១១ Geneva ១០, Switzerland ។


**ការបកប្រែក្រៅផ្លូវការ**

ឯកសារបកប្រែនៃប័ណ្ណព័ត៌មានលេខ២១ ស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ
ត្រូវបានបោះពុម្ពផ្សាយដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំនៅកម្ពុជា
ខែធ្នូ ឆ្នាំ២០១២

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

# មាតិកា


ពាក្យបំព្រួញ .................................................................... v

សេចក្ដីផ្ដើម .................................................................... ១

I. អ្វីទៅជាសិទ្ធិមានលំនៅដ្ឋានសមរម្យ? ........................................ ៣

ក. ទិដ្ឋភាពសំខាន់ៗនៃសិទ្ធិមានលំនៅដ្ឋានសមរម្យ .................. ៣

ខ. ការយល់ខុសដែលតែងកើតមានចំពោះសិទ្ធិមានលំនៅដ្ឋានសមរម្យ ........................................................................ ៨

គ. ទំនាក់ទំនងគ្នារវាងសិទ្ធិមានលំនៅដ្ឋានសមរម្យ និងសិទ្ធិមនុស្សដទៃទៀត ........................................................ ១៤

ឃ. តើគោលការណ៍មិនរើសអើងអនុវត្តដោយរបៀបណា? .......... ១៥

ង. សិទ្ធិមានលំនៅដ្ឋានសមរម្យនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ........................................................................ ១៧

II. តើសិទ្ធិមានលំនៅដ្ឋានសមរម្យអនុវត្តចំពោះក្រុមមនុស្សជាក់លាក់ដោយរបៀបណា? ................................................ ២៦

ក. ស្ត្រី ........................................................................ ២៦

ខ. កុមារ ...................................................................... ៣១

គ. អ្នករស់នៅតំបន់ក្រីក្រតាមទីប្រជុំជន ................................ ៣៤

ឃ. ជនគ្មានផ្ទះសម្បែង ........................................................ ៣៧

ង. ជនពិការ .......................................................... ៣៩
ច. ជនចំណាកស្រុក និង ទេសន្តរប្រវេសន៍............................. ៤២
ឆ. ក្រុមជនជាតិដើមភាគតិច ................................................ ៤៨

III. តើរដ្ឋមានកាតព្វកិច្ចអ្វីខ្លះ ហើយអ្នកផ្សេងទៀតមានការទទួលខុសត្រូវអ្វីខ្លះ?.................................................................................. ៥១
ក. កាតព្វកិច្ចទូទៅ............................................................. ៥១
ខ. កាតព្វកិច្ចទាំងបីប្រភេទ..................................................... ៥៦
គ. ការទទួលខុសត្រូវរបស់អ្នកដទៃទៀត ................................. ៥៨

IV. ការឃ្លាំមើលសិទ្ធិមានលំនៅដ្ឋានសមរម្យ និងការដាក់ឲ្យរដ្ឋទទួលខុសត្រូវ ........................................................................ ៦៤
ក. គណនេយ្យភាព និងការឃ្លាំមើលថ្នាក់ជាតិ.......................... ៦៤
ខ. គណនេយ្យភាពថ្នាក់តំបន់................................................ ៧៣
គ. ការឃ្លាំមើលថ្នាក់អន្តរជាតិ................................................ ៧៤

*ឧបសម្ព័ន្ធ ៖* លិខិតុបករណ៍អន្តរជាតិមួយចំនួន ដែលបានជ្រើសសម្រាំង និងឯកសារផ្សេងៗទៀត ទាក់ទងនឹងសិទ្ធិមានលំនៅដ្ឋានសមរម្យ ....... ៨០

# ពាក្យបំព្រួញ

| | |
|---|---|
| IDPs | ជនចំណាកស្រុក នៅក្នុងប្រទេស |
| ILO | អង្គការពលកម្មអន្តរជាតិ |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| NHRI | ស្ថាប័នសិទ្ធិមនុស្សជាតិ |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| UN- Habitat | កម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅដ្ឋានមនុស្សជាតិ |
| UNHRP | កម្មវិធីសិទ្ធិមានលំនៅដ្ឋានអង្គការសហប្រជាជាតិ |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារ |

# សេចក្តីផ្តើម

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូប ក្នុងការមានកម្រិតជីវភាពសមរម្យ រួមទាំងលំនៅដ្ឋានសមរម្យផងដែរ។ ទោះបីជាសិទ្ធិនេះស្ថិតនៅចំណុចកណ្តាលក្នុងប្រព័ន្ធច្បាប់សកលក្តី ក៏មនុស្សជាងមួយពាន់លាននាក់ នៅមិនទាន់មានលំនៅដ្ឋានសមរម្យនៅឡើយទេ។ មនុស្សជាច្រើនលាននាក់នៅជុំវិញពិភពលោក រស់នៅក្នុងស្ថានភាពដែលគំរាមកំហែងដល់អាយុជីវិត និងសុខភាព ក្នុងតំបន់ក្រីក្រតាមទីប្រជុំជន ដែលមានមនុស្សរស់នៅច្រើនហួសកម្រិត និងតំបន់រស់នៅមិនទាន់រៀបរយ ឬ ក្នុងស្ថានភាពដទៃទៀត ដែលមិនលើកកំពស់សិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់ពួកគេ។ មនុស្សជាច្រើនលាននាក់ផ្សេងទៀត ត្រូវបានបណ្តេញចេញដោយបំពាន ឬបានរងការគម្រាមបណ្តេញដោយបំពានចេញពីលំនៅដ្ឋានរបស់ខ្លួន ជារៀងរាល់ឆ្នាំ។

លំនៅដ្ឋានសមរម្យត្រូវបានទទួលស្គាល់ថា ជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពសមរម្យ ដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឆ្នាំ១៩៦៦។ សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដទៃទៀត បានទទួលស្គាល់សិទ្ធិនេះ ចាប់ពីពេលនោះមក ឬបានដាក់បញ្ចូលសិទ្ធិមានលំនៅដ្ឋានសមរម្យ ឬ សមាសភាពមួយចំនួននៃសិទ្ធិនេះ ជាអាទិ៍ ការការពារលំនៅដ្ឋាន និងសិទ្ធិឯកជនរបស់បុគ្គល។

សិទ្ធិមានលំនៅដ្ឋានសមរម្យ អនុវត្តចំពោះរដ្ឋទាំងអស់ ព្រោះថា រដ្ឋទាំងនោះបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិយ៉ាងតិចណាស់ក៏មួយដែរ ដែលនិយាយអំពីសិទ្ធិមានលំនៅដ្ឋានសមរម្យ និងការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីការពារ

សិទ្ធិមានលំនៅដ្ឋានសមរម្យ តាមរយៈសេចក្តីប្រកាសអន្តរជាតិ ផែនការសកម្មភាព ឬ ឯកសារស្តីពីលទ្ធផលនៃសន្និសីទនានា។ រដ្ឋធម្មនុញ្ញខ្លះ ការពារសិទ្ធិមានលំនៅដ្ឋានសមរម្យ ឬ ចែងអំពីការទទួលខុសត្រូវទូទៅរបស់រដ្ឋ ក្នុងការធានាសិទ្ធិមានលំនៅដ្ឋាន និងជីវភាពសមរម្យសម្រាប់មនុស្សគ្រប់រូប។ តុលាការកើតចេញពីប្រព័ន្ធច្បាប់នានា ក៏បានធ្វើការវិនិច្ឆ័យសំណុំរឿងក្តីផ្សេងៗ ពាក់ព័ន្ធនឹងការប្រើប្រាស់វិសាលភាពនៃសិទ្ធិនេះ ជាអាទិ៍ ការបណ្តេញចេញដោយបំពាន ការការពារអ្នកអាស្រ័យនៅ ការរើសអើងក្នុងវិស័យផ្ទះសម្បែង ឬការទទួលបានសេវាចាំបាច់សម្រាប់លំនៅដ្ឋាន។

ការយកចិត្តទុកដាក់ពីអន្តរជាតិ ក៏មានការកើនឡើងផងដែរ លើសិទ្ធិមានលំនៅដ្ឋានសមរម្យ រាប់ទាំង ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស យន្តការសិទ្ធិមនុស្សថ្នាក់តំបន់ និងគណៈកម្មការសិទ្ធិមនុស្ស (បច្ចុប្បន្ន បានប្តូរមកជាក្រុមប្រឹក្សាសិទ្ធិមនុស្ស) ដែលបានបង្កើតឲ្យមាននូវអាណត្តិ "អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ" ក្នុងឆ្នាំ២០០០។ គំនិតផ្តួចផ្តើមទាំងនេះ បានជួយបញ្ជាក់បន្ថែមអំពីវិសាលភាព និងខ្លឹមសារនៃសិទ្ធិមានលំនៅដ្ឋានសមរម្យ។

ប័ណ្ណព័ត៌មាននេះ ផ្តើមដោយការពន្យល់អំពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ដោយគូសបង្ហាញពីអ្វីដែលជាអត្ថន័យសម្រាប់បុគ្គល និងក្រុមមនុស្សជាក់លាក់មួយចំនួន ហើយបន្ទាប់មក ធ្វើការបរិយាយអំពីកាតព្វកិច្ចពាក់ព័ន្ធផ្សេងៗរបស់រដ្ឋ។ ប័ណ្ណព័ត៌មាននេះ បរិយាយសង្ខេបអំពីការទទួលខុសត្រូវនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ និង យន្តការឃ្លាំមើលដទៃទៀត។

ប័ណ្ណព័ត៌មានរួមរវាងការិយាល័យ OHCHR និង UN-Habitat នេះ គឺជាឯកសារបោះពុម្ពផ្សាយរួមគ្នាលើកទីពីរ ដែលបានចេញជាបន្តបន្ទាប់ ដោយការិយាល័យ OHCHR ជាមួយ ភ្នាក់ងារអង្គការសហប្រជាជាតិជាដៃគូដទៃ

ទៀត ដែលផ្តោតលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ឯកសារបោះពុម្ពផ្សាយរួមគ្នាលើកទីមួយ គឺជាប័ណ្ណព័ត៌មានស្តីពីសិទ្ធិសុខភាព ដែលបានចេញរួមគ្នាជាមួយអង្គការសុខភាពពិភពលោក និង ប័ណ្ណព័ត៌មានរួមជាមួយអង្គការស្បៀងអាហារ និងកសិកម្ម នៃអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិទទួលបានស្បៀងអាហារ ដែលនឹងចេញនៅពេលដ៏ឆាប់ខាងមុខនេះ។

# I. អ្វីទៅជាសិទ្ធិមានលំនៅដ្ឋានសមរម្យ?

## ក. ទិដ្ឋភាពសំខាន់ៗ នៃសិទ្ធិមានលំនៅដ្ឋានសមរម្យ

គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របស់អង្គការសហប្រជាជាតិ បានគូសបញ្ជាក់ថា សិទ្ធិមានលំនៅដ្ឋានសមរម្យ មិនគួរត្រូវបានបកស្រាយក្នុងន័យចង្អៀតឡើយ។ ផ្ទុយទៅវិញ គេគួរតែចាត់ទុកសិទ្ធិនេះថាជាសិទ្ធិរស់នៅទីណាមួយដែលមានសន្តិសុខ សន្តិភាព និងសេចក្តីថ្លៃថ្នូរ។ ចរិតលក្ខណៈនៃសិទ្ធិមានលំនៅដ្ឋានសមរម្យ ត្រូវបានស្រាយបំភ្លឺជាពិសេស នៅក្នុងសេចក្តីពន្យល់រួម របស់គណៈកម្មាធិការលេខ៤ (១៩៩១) ស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ និង លេខ ៧ (១៩៩៧) ស្តីពីការបណ្តេញចេញដោយបំពាន។[១]

- **សិទ្ធិមានលំនៅដ្ឋានសមរម្យ មានបញ្ចូលសេរីភាពផ្សេងៗ។ សេរីភាពទាំងនេះ រួមមាន ៖**
  - ➢ ការការពារប្រឆាំងនឹងការបណ្តេញចេញដោយបំពាន ការបំផ្លិចបំផ្លាញ និងការកំទេចផ្ទះសម្បែងរបស់បុគ្គលណាមួយ តាមទំនើងចិត្ត ។

[១] សេចក្តីពន្យល់រួមមួយចំនួន ត្រូវបានអនុម័តដោយស្ថាប័នសន្ធិសញ្ញា ដោយផ្អែកលើបទពិសោធន៍របស់ខ្លួន ក្នុងការតាមឃ្លាំមើល ។ ស្ថាប័នទាំងនោះ បានផ្តល់ការណែនាំផ្នែកជំនាញរបស់ខ្លួន ដល់រដ្ឋនានា ស្តីពីកាតព្វកិច្ចរបស់រដ្ឋ ក្រោមសន្ធិសញ្ញាណាមួយ។

- ➢ សិទ្ធិរួចផុតពីការជ្រៀតជ្រែករំខានតាមទំនើងចិត្ត លើលំនៅដ្ឋាន សិទ្ធិឯកជន និង គ្រួសាររបស់ខ្លួន និង
- ➢ សិទ្ធិជ្រើសរើសនិវេសនដ្ឋានរបស់ខ្លួន សិទ្ធិកំណត់យកទីកន្លែងសំរាប់រស់នៅ និងសិទ្ធិសេរីភាពក្នុងការដើរហើរ។

- **សិទ្ធិមានលំនៅដ្ឋានសមរម្យ រួមមានសិទ្ធិផ្សេងៗ។** *សិទ្ធិទាំងនោះ រួមមាន៖*

  - ➢ សុវត្ថិភាពក្នុងការកាន់កាប់
  - ➢ សំណងជួសជុលការខូចខាតផ្ទះសម្បែង ដីធ្លី និងទ្រព្យសម្បត្តិ
  - ➢ ការទទួលបានដោយស្មើភាពគ្នា និងដោយគ្មានការរើសអើងនូវសិទ្ធិមានលំនៅដ្ឋានសមរម្យ
  - ➢ ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត ពាក់ព័ន្ធនឹងលំនៅដ្ឋាន ទាំងនៅថ្នាក់ជាតិ និងថ្នាក់សហគមន៍។

- **លំនៅដ្ឋានសមរម្យ ត្រូវតែមានច្រើនជាង ការគ្រាន់តែមានជញ្ជាំង ៤ ផ្ទាំង និង ដំបូល ១ ។** លក្ខខណ្ឌមួយចំនួន ត្រូវតែបានបំពេញមុនពេលដែលទីជម្រកក្នុងរូបភាពណាមួយ អាចនឹងត្រូវបានចាត់ទុកថាជា "លំនៅដ្ឋានសមរម្យ"។ សមាសភាពទាំងនេះ មានសារៈសំខាន់ដូចគ្នានឹងការផ្គត់ផ្គង់ចាំបាច់ និងលទ្ធភាពរកបានលំនៅដ្ឋាន។ ដើម្បីឲ្យលំនៅដ្ឋានមួយសមរម្យទៅបាន លុះត្រាតែបំពេញតាមលក្ខណៈវិនិច្ឆ័យ *ជាអប្បបរមា* ដូចខាងក្រោមនេះ ៖
  - ➢ *សុវត្ថិភាពក្នុងការកាន់កាប់ ៖* លំនៅដ្ឋានមិនមានលក្ខណៈសមរម្យឡើយ ប្រសិនបើអ្នកកាន់កាប់ មិនមានសុវត្ថិភាពក្នុងការកាន់កាប់ដែលធានាដល់ការការពារតាមផ្លូវច្បាប់ប្រឆាំងនឹងការបណ្តេញចេញដោយបំពាន ការយាយីរំខាន និងការគម្រាមកំហែងដទៃទៀត។

- *ភាពអាចទទួលបានសេវាកម្ម សម្ភារៈ អគារ ឬកន្លែងផ្តល់សេវា និងហេដ្ឋារចនាសម្ព័ន្ធ៖* លំនៅដ្ឋានមិនមានលក្ខណៈសមរម្យឡើយ ប្រសិនបើអ្នកកាន់កាប់ មិនមានទឹកពិសារមានសុវត្ថិភាព(ទឹកស្អាត) អនាម័យ ថាមពលគ្រប់គ្រាន់សម្រាប់ចំអិនម្ហូបអាហារ ប្រព័ន្ធកំដៅ ឧបករណ៍សម្រាប់បំភ្លឺ មធ្យាបាយរក្សាទុកម្ហូបអាហារ ឬកន្លែងចាក់កាកសំណល់។
- *ភាពអាចលៃលកបាន៖* លំនៅដ្ឋានមិនមានលក្ខណៈសមរម្យឡើយ ប្រសិនបើតម្លៃរបស់លំនៅដ្ឋាននោះ គំរាមកំហែង ឬបង្កឧបសគ្គដល់អ្នកកាន់កាប់ក្នុងការប្រើប្រាស់សិទ្ធិមនុស្សផ្សេងទៀត។
- *ភាពអាចរស់នៅបាន៖* លំនៅដ្ឋានមិនមានលក្ខណៈសមរម្យឡើយ ប្រសិនបើលំនៅដ្ឋាននោះ មិនធានាសុវត្ថិភាពរូបកាយ ឬមានទីធ្លាធំទូលាយគ្រប់គ្រាន់ ព្រមទាំងការការពារទប់ទល់នឹងអាកាសធាតុត្រជាក់ សំណើម កំដៅ ភ្លៀង ខ្យល់ ការគម្រាមកំហែងដទៃទៀតដល់សុខភាព និងភាពអន្តរាយខាងរចនាសម្ព័ន្ធ។
- *ភាពអាចទៅប្រើប្រាស់បាន៖* លំនៅដ្ឋានមិនមានលក្ខណៈសមរម្យឡើយ ប្រសិនបើសេចក្តីត្រូវការជាក់លាក់របស់ក្រុមងាយរងគ្រោះ និងទីទ័លក្របំផុត មិនត្រូវបានគេគិតគូដល់ទេនោះ។
- *ទីតាំង៖* លំនៅដ្ឋានមិនមានលក្ខណៈសមរម្យឡើយ ប្រសិនបើទីតាំងនោះ ផ្តាច់ចេញពីឱកាសការងារ សេវាថែទាំសុខភាព សាលារៀន មជ្ឈមណ្ឌលគាំពារកុមារ និងសេវាសង្គមដទៃទៀត ឬ ប្រសិនបើលំនៅដ្ឋាននោះ ស្ថិតនៅក្នុងតំបន់គ្រោះថ្នាក់ ឬ មានការបំពុលបរិស្ថាន។
- *ភាពសមស្របផ្នែកវប្បធម៌ និងប្រពៃណី៖* លំនៅដ្ឋានមិនមានលក្ខណៈសមរម្យឡើយ ប្រសិនបើលំនៅដ្ឋាននោះ មិនគោរព និងគិតគូពីអត្តសញ្ញាណវប្បធម៌។

**ការការពារប្រឆាំងនឹងការបណ្តេញចេញដោយបំពាន៖** ការការពារប្រឆាំងនឹងការបណ្តេញចេញដោយបំពាន គឺជាសមាសភាពដ៏សំខាន់នៃសិទ្ធិមានលំនៅដ្ឋានសមរម្យ និងជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងសុវត្ថិភាពក្នុងការកាន់កាប់។

ការបណ្តេញចេញដោយបំពានមានន័យថាជា "ការផ្លាស់ចេញជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន ពីលំនៅដ្ឋាន និង/ឬ ពីដីធ្លីដែលពួកគេកាន់កាប់ ផ្ទុយពីឆន្ទៈរបស់បុគ្គលម្នាក់ៗ គ្រួសារ និង/ឬ សហគមន៍នោះ ដោយមិនមានការផ្តល់ និងការទទួលបានការការពារតាមផ្លូវច្បាប់ ឬការការពារសមស្របដទៃទៀត"។[២] យោងតាមកម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅដ្ឋានមនុស្សជាតិ (UN-Habitat) បានឲ្យដឹងថា មនុស្សយ៉ាងតិច ២ លាននាក់នៅលើពិភពលោក ត្រូវបានបណ្តេញចេញដោយបំពានជារៀងរាល់ឆ្នាំ ខណៈដែលមនុស្សជាច្រើនលាននាក់ទៀត ត្រូវបានរងការគម្រាមកំហែងនូវការបណ្តេញចេញដោយបំពានផងដែរ។[៣]

ការបណ្តេញចេញដោយបំពាន ត្រូវបានធ្វើនៅក្នុងកាលៈទេសៈ និងមូលហេតុផ្សេងៗគ្នាជាច្រើន មានជាអាទិ៍ ការត្រួសត្រាយផ្លូវសម្រាប់គម្រោងអភិវឌ្ឍន៍ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ការអភិវឌ្ឍន៍ទីក្រុងឡើងវិញ ឬ ការកែលំអសោភ័ណ្ឌភាពទីក្រុង ឬការរៀបចំព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ ដែលបណ្តាលជាជម្លោះសិទ្ធិលើដីធ្លី ជម្លោះប្រដាប់អាវុធ ឬលំនាំនៃការរើសអើងក្នុង

---

[២] សេចក្តីពន្យល់រួមលេខ៧ ដែលបន្តធ្វើការកត់សំគាល់ថា "ទោះជាយ៉ាងណាក៏ដោយ ការហាមប្រាមលើការបណ្តេញចេញដោយបំពាន មិនអនុវត្តចំពោះការបណ្តេញចេញដោយបង្ខំស្របតាមច្បាប់ និងអនុលោមតាមបទបញ្ញត្តិនៃកតិកាសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានាឡើយ" (កថាខ័ណ្ឌទី ៤)។

[៣] UN–Habitat, *របាយការណ៍សកលស្តីពីការតាំងទីលំនៅសម្រាប់មនុស្សជាតិ ឆ្នាំ២០០៧ ៖ ការលើកកំពស់សន្តិសុខ និង សុវត្ថិភាព ក្នុងទីក្រុង* (ណៃរ៉ូប៊ី ២០០៧)។

សង្គម។ ការបណ្ដេញចេញដោយបំពាន នាំទៅរកអំពើហិង្សា និងបណ្ដាលឲ្យមានការប៉ះពាល់ប្រជាជនក្រីក្រដោយភាពមិនសមាមាត្រ ហើយជាលទ្ធផលជាញឹកញាប់ ពួកគេត្រូវទទួលរងនូវការរំលោភសិទ្ធិមនុស្សច្រើនថែមទៀត។ ក្នុងករណីជាច្រើន ការបណ្ដេញចេញដោយបំពាន ដើម្បីបង្ហាញឲ្យឃើញពីបំណងដោះស្រាយបញ្ហានោះ បានផ្សំនូវបញ្ហាទៅវិញ។

មិនថាមូលហេតុអ្វីឡើយ ការបណ្ដេញចេញដោយបំពាន អាចត្រូវចាត់ទុកថាជាការរំលោភដ៏ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស និងជាការរំលោភជាក់ស្ដែងលើសិទ្ធិមានលំនៅដ្ឋានសមរម្យ។ ជាទូទៅ ការបណ្ដេញចេញទ្រង់ទ្រាយធំ អាចត្រូវបានធ្វើយុត្តិកម្មតែក្នុងករណីពិសេសបំផុត និងក្នុងករណីដែលការបណ្ដេញចេញនោះ ធ្វើឡើងស្របតាមគោលការណ៍ពាក់ព័ន្ធនៃច្បាប់អន្តរជាតិប៉ុណ្ណោះ។

*ការធានាការពារក្នុងករណីមានការបណ្ដេញចេញ*

ប្រសិនបើការបណ្ដេញចេញ ត្រូវបានធ្វើយុត្តិកម្ម ដោយសារតែអ្នកជួលខកខានម្ដងហើយម្ដងទៀត ក្នុងការបង់ថ្លៃឈ្នួល ឬថ្លៃជួសជុលសំណងការខូចខាតទ្រព្យសម្បត្តិ ដោយគ្មានមូលហេតុសមស្រប ពេលនោះ រដ្ឋត្រូវតែធានាថាការបណ្ដេញចេញនោះ ត្រូវបានធ្វើស្របតាមច្បាប់ សមហេតុផល និងមានសមាមាត្រ និងអនុលោមតាមច្បាប់អន្តរជាតិ។ បណ្ដឹងឧបាស្រ័យ និងដំណោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព គួរតែមានសម្រាប់អ្នកដែលត្រូវគេបណ្ដេញចេញ រាប់ទាំងការផ្ដល់សំណងសមរម្យសំរាប់ចលនទ្រព្យ ឬអចលនទ្រព្យផ្ទាល់ខ្លួន ដែលរងផលប៉ះពាល់ដោយការបណ្ដេញចេញនោះ។ ការបណ្ដេញចេញ មិនគួរជាហេតុបណ្ដាលឲ្យមនុស្សក្លាយជាអ្នកគ្មានផ្ទះសម្បែង ឬកាន់តែងាយរងគ្រោះថែមទៀត ដោយការរំលោភសិទ្ធិមនុស្សឡើយ។

ជាទូទៅ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ តម្រូវឲ្យរដ្ឋាភិបាលនានា ស្វែងរកគ្រប់ជម្រើសដែលអាចធ្វើទៅបាន មុននឹងធ្វើការបណ្ដេញចេញណាមួយ ដើម្បី

ជៀសវាង ឬកាត់បន្ថយការប្រើប្រាស់កម្លាំងឲ្យនៅតិចបំផុតដល់កំរិតអប្បបរមា។ នៅពេលដែលការបណ្តេញចេញ ត្រូវបានធ្វើជាមធ្យោបាយចុងក្រោយបំផុតនោះ បុគ្គលទាំងឡាយដែលទទួលរងផលប៉ះពាល់ ត្រូវតែទទួលបានការធានាការពារតាមនីតិវិធីត្រឹមត្រូវប្រកបដោយប្រសិទ្ធភាព ដែលអាចមានអនុភាពរារាំងដល់ការបណ្តេញចេញដែលបានគ្រោងទុក ។ ការធានាការពារទាំងនេះ រួមមាន ៖

- ឱកាសសម្រាប់ការពិគ្រោះយោបល់ពិតប្រាកដ
- ការជូនដំណឹងមានពេលវេលាគ្រប់គ្រាន់ និងសមហេតុផល
- លទ្ធភាពទទួលបានព័ត៌មានស្តីពីការបណ្តេញចេញដែលបានស្នើឡើងក្នុងពេលវេលាមួយសមស្រប
- មានវត្តមានរបស់មន្ត្រីរដ្ឋាភិបាល ឬតំណាងរបស់ពួកគេ នៅក្នុងអំឡុងពេលនៃការបណ្តេញចេញ
- ការកំណត់អត្តសញ្ញាណអ្នកធ្វើការបណ្តេញចេញឲ្យបានត្រឹមត្រូវ
- ហាមធ្វើការបណ្តេញចេញ ពេលអាកាសធាតុមិនល្អ ឬ នៅពេលយប់
- លទ្ធភាពទទួលបានដំណោះស្រាយតាមផ្លូវច្បាប់
- ការទទួលបានជំនួយតាមផ្លូវច្បាប់ សម្រាប់អ្នកដែលត្រូវការលទ្ធភាពស្វែងរកសំណងតាមផ្លូវច្បាប់។

## ខ. ការយល់ខុសដែលតែងកើតមានចំពោះសិទ្ធិមានលំនៅដ្ឋានសមរម្យ

- **សិទ្ធិមានលំនៅដ្ឋានសមរម្យ មិនតម្រូវឲ្យរដ្ឋធ្វើការសាងសង់លំនៅដ្ឋានឲ្យប្រជាពលរដ្ឋគ្រប់ៗគ្នានោះឡើយ។** ការយល់ឃើញខុសមួយ ក្នុងចំណោមទស្សនៈយល់ខុសជាទូទៅបំផុត ចំពោះសិទ្ធិមានលំនៅដ្ឋានសមរម្យ គឺថា សិទ្ធិនេះតម្រូវឲ្យរដ្ឋធ្វើការសាងសង់លំនៅដ្ឋានឲ្យប្រជា

ពលរដ្ឋគ្រប់គ្នាទាំងអស់ ហើយថាប្រជាពលរដ្ឋដែលគ្មានលំនៅដ្ឋានអាចធ្វើការទាមទារផ្ទះសម្បែងពីរដ្ឋាភិបាលបានដោយស្វ័យប្រវត្តិ។ ទោះជាមានរដ្ឋាភិបាលភាគច្រើន បានចូលរួមនៅក្នុងកម្រិតខ្លះ ក្នុងការសាងសង់លំនៅដ្ឋានក្តី ក៏សិទ្ធិមានលំនៅដ្ឋានសមរម្យនេះ ពិតជាមិនតម្រូវឲ្យរដ្ឋាភិបាលធ្វើការសាងសង់លំនៅដ្ឋានឲ្យប្រជាពលរដ្ឋនៃប្រទេសនោះគ្រប់គ្នាទាំងអស់ឡើយ។

ផ្ទុយទៅវិញ សិទ្ធិមានលំនៅដ្ឋានសមរម្យ មានវិសាលភាពគ្របដណ្តប់លើវិធានការទាំងឡាយដែលចាំបាច់ ក្នុងការបង្ការភាពគ្មានផ្ទះសម្បែង ហាមប្រាមការបណ្តេញចេញដោយបំពាន ដោះស្រាយការរើសអើង ផ្តោតការយកចិត្តទុកដាក់លើក្រុមដែលងាយរងគ្រោះបំផុត និងក្រុមដែលគេមិនសូវគិតគូដល់ ដោយធានាសុវត្ថិភាពក្នុងការកាន់កាប់ដល់បុគ្គលគ្រប់រូប ហើយធានាថា លំនៅដ្ឋានរបស់មនុស្សគ្រប់រូបត្រូវមានលក្ខណៈសមរម្យ។ វិធានការទាំងនេះ អាចត្រូវការអន្តរាគមន៍ពីរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ រួមមាន៖ នីតិបញ្ញត្តិ រដ្ឋបាល គោលនយោបាយ និងអាទិភាពលើការចំណាយផ្សេងៗ។ អន្តរាគមន៍នេះអាចធ្វើទៅបាន តាមរយៈមធ្យោបាយ ឬវិធីសាស្រ្តផ្តល់លទ្ធភាពទទួលបានទីជម្រក កាលបើរដ្ឋាភិបាលដើរតួជាអ្នកសម្របសម្រួលសកម្មភាពរបស់អ្នកចូលរួមពាក់ព័ន្ធទាំងអស់ ក្នុងការសាងសង់ និងកែលំអទីជម្រក ជាជាង ការដើរតួនាទីជាអ្នកផ្តល់ផ្ទះសម្បែងផ្ទាល់តែម្តង។ គោលនយោបាយ យុទ្ធសាស្រ្ត និងកម្មវិធីផ្សេងៗ ដែលឈរលើមធ្យោបាយ ឬវិធីសាស្រ្ត ផ្តល់លទ្ធភាពនេះ ត្រូវបានលើកកំពស់ដោយអង្គការសហប្រជាជាតិចាប់ពីឆ្នាំ ១៩៨៨ រហូតដល់ឆ្នាំ២០០០ នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្រ្តសកលសម្រាប់ទីជម្រក ។

ប៉ុន្តែក្នុងករណីខ្លះ រដ្ឋអាចនឹងត្រូវផ្តល់ជំនួយដោយផ្ទាល់ ដូចជាលំនៅដ្ឋាន ឬប្រាក់ឧបត្ថម្ភសំរាប់សាងសង់ផ្ទះសម្បែង ជាពិសេស ដល់

ប្រជាពលរដ្ឋដែលរងគ្រោះមហន្តរាយ(គ្រោះធម្មជាតិ ឬគ្រោះមហន្តរាយដែលមនុស្សជាអ្នកបង្កឡើង) និងដល់ក្រុមងាយរងគ្រោះបំផុតនៅក្នុងសង្គម។ ម្យ៉ាងវិញទៀត វិធានការមួយចំនួនដែលចាំបាច់ក្នុងការធានាសិទ្ធិមានលំនៅដ្ឋានសមរម្យ គឺតម្រូវឲ្យរដ្ឋាភិបាល គ្រាន់តែបោះបង់ចោលទង្វើ ឬ ទម្លាប់អនុវត្តមួយចំនួនប៉ុណ្ណោះ។

- **សិទ្ធិមានលំនៅដ្ឋានសមរម្យ មិនមែនគ្រាន់តែជាគោលដៅកម្មវិធី ដែលត្រូវសម្រេចចឲ្យបានក្នុងរយៈពេលវែងប៉ុណ្ណោះទេ។** ការយល់ឃើញខុសមួយទៀតនោះគឺថា សិទ្ធិមានលំនៅដ្ឋានសមរម្យ មិនដាក់កាតព្វកិច្ចផ្ទាល់ភ្លាមទៅលើរដ្ឋឡើយ។ ផ្ទុយមកវិញ រដ្ឋទាំងឡាយ ត្រូវតែខិតខំប្រឹងប្រែងគ្រប់លទ្ធភាពដែលអាចធ្វើបាន តាមធនធានដែលមាន ដើម្បីធ្វើឲ្យសម្រេចបាននូវសិទ្ធិមានលំនៅដ្ឋានសមរម្យ ព្រមទាំងចាត់វិធាការផ្សេងៗក្នុងទិសដៅនោះ ដោយគ្មានការពន្យាពេល។ បើទោះបីជា រដ្ឋមានធនធានមានកម្រិតក្តី ក៏កាតព្វកិច្ចមួយចំនួន មានអានុភាពអនុវត្តភ្លាមៗ ដូចជា ការធានាការពារសិទ្ធិមានលំនៅដ្ឋានសមរម្យក្នុងលក្ខណៈស្មើភាពនិងគ្មានការរើសអើង ការបង្កើតច្បាប់ និងផែនការសកម្មភាពផ្សេងៗ ការបង្ការការបណ្តេញចេញដោយបំពាន ឬការធានាឲ្យបាននៅកម្រិតណាមួយនៃសុវត្ថិភាពក្នុងការកាន់កាប់សម្រាប់មនុស្សគ្រប់រូប។

- **សិទ្ធិមានលំនៅដ្ឋានសមរម្យ មិនរារាំងគម្រោងអភិវឌ្ឍន៍ ដែលអាចឲ្យប្រជាជនផ្លាស់ទីលំនៅនោះឡើយ។** ជួនកាលគេយល់ថា ការការពារពីការបណ្តេញចេញដោយបំពាន រារាំងដល់គម្រោងអភិវឌ្ឍន៍ ឬទំនើបភាវូបនីយកម្ម ដែលតម្រូវឲ្យមានការផ្លាស់ទីលំនៅ។ ជាក់ស្តែងមានសេចក្តីត្រូវការមួយចំនួនដែលមិនអាចជៀសផុតបាន សម្រាប់ការអភិវឌ្ឍន៍ឡើងវិញនូវតំបន់ផ្សេងៗ នៅពេលដែលទីក្រុងកំពុងរីកដុះដាល និងសម្រាប់ឲ្យស្ថាប័នសាធារណៈ មានដីសម្រាប់ប្រើប្រាស់ និងហេដ្ឋារចនា

សម្ព័ន្ធសាធារណៈ។ សិទ្ធិមានលំនៅដ្ឋានសមរម្យ មិនរារាំងការអភិវឌ្ឍន៍បែបនេះមិនឲ្យកើតមាននោះឡើយ ប៉ុន្តែគេត្រូវតែបង្កើតល័ក្ខខណ្ឌ និងកំណត់នីតិវិធីនានាសម្រាប់ការអភិវឌ្ឍនោះ។ ពោលគឺវិធីនៅក្នុងការបង្កើត អភិវឌ្ឍ និងអនុវត្តគម្រោងទាំងនោះទេដែលជាប្រការសំខាន់ចាំបាច់នោះ។ ជាញឹកញាប់បំផុត ការបណ្តេញចេញទាំងនេះ ត្រូវបានអនុវត្តដោយមានការពិគ្រោះយោបល់តិចតួច ឬគ្មានទាល់តែសោះជាមួយអ្នកដែលទទួលរងផលប៉ះពាល់ ការគិតគូនៅមានកម្រិតនៅឡើយអំពីសេចក្តីត្រូវការរបស់ពួកគេ និងមានការខិតខំប្រឹងប្រែងតិចតួចដើម្បីពង្រីកការដោះស្រាយឈានទៅកាត់បន្ថយទំហំនៃការបណ្តេញចេញ និង ការរំខានផ្សេងទៀតដែលបានបង្កឡើង ឲ្យមកនៅត្រឹមកម្រិតអប្បបរមា។

- **សិទ្ធិមានលំនៅដ្ឋានសមរម្យ មិនដូចគ្នានឹងសិទ្ធិលើទ្រព្យសម្បត្តិឡើយ។** ជួនកាល គេគិតថា សិទ្ធិមានលំនៅដ្ឋានសមរម្យ ស្មើនឹងសិទ្ធិលើទ្រព្យសម្បត្តិ។ អ្នកខ្លះជំទាស់ដែរថា សិទ្ធិមានលំនៅដ្ឋានសមរម្យ មិនដូចគ្នានឹងសិទ្ធិលើទ្រព្យសម្បត្តិនោះទេ។ សិទ្ធិលើទ្រព្យសម្បត្តិផ្ទាល់ខ្លួន មានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាសិទ្ធិមនុស្សដទៃទៀត ដូចជា អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (មាត្រា ៥ (ឃ) (v)) និងអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (មាត្រា១៦ (ជ)) ទោះបីជាមិនមាននៅក្នុងកតិកាសញ្ញាទាំងពីរនេះក៏ដោយ។[៤]

[៤] សិទ្ធិលើទ្រព្យសម្បត្តិ មានចែងផងដែរ ក្នុងអនុសញ្ញាសិទ្ធិមនុស្សអាមេរិក (មាត្រា២១) ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ (មាត្រា១៤) និងធម្មនុញ្ញស្តីពីសិទ្ធិមូលដ្ឋានសហភាពអឺរ៉ុប (មាត្រា ១៧)។

សិទ្ធិមានលំនៅដ្ឋានសមរម្យ មានវិសាលភាពទូលំទូលាយជាងសិទ្ធិលើទ្រព្យសម្បត្តិផ្ទាល់ខ្លួន ពីព្រោះ វានិយាយពីសិទ្ធិដែលមិនពាក់ព័ន្ធតែនឹងកម្មសិទ្ធិទេ ពោលសិទ្ធិនេះ មានគោលដៅធានាឲ្យ*មនុស្សគ្រប់រូប* មានលំនៅដ្ឋានមួយគត់មត់ និងមានសុវត្ថិភាព ដើម្បីរស់នៅក្នុងសុខសន្តិភាព និងសេចក្តីថ្លៃថ្នូរ រាប់ទាំងអ្នកដែលមិនមែនជាម្ចាស់កម្មសិទ្ធិលើទ្រព្យនោះផងដែរ។ សុវត្ថិភាពក្នុងការកាន់កាប់ ដែលជាសរសរគោលនៃសិទ្ធិមានលំនៅដ្ឋានសមរម្យ អាចមានលើការកាន់កាប់ជាទម្រង់ខុសៗគ្នា ដូចជាលើការជួលកន្លែងស្នាក់នៅ លំនៅដ្ឋានរួមគ្នា ការជួល ការកាន់កាប់ដោយម្ចាស់ផ្ទះ លំនៅដ្ឋាននាគ្រាមានអាសន្ន ឬ ទីលំនៅមិនរៀបរយ។ សុវត្ថិភាពក្នុងការកាន់កាប់តាមទម្រង់បែបទាំងនេះ មិនកម្រិតត្រឹមតែលើការផ្តល់កម្មសិទ្ធិស្របច្បាប់ជាផ្លូវការនោះឡើយ។[៥] ដោយសិទ្ធិមានលំនៅដ្ឋានសមរម្យ បានផ្តល់ការការពារទូលំទូលាយ ថែមទៀតនោះ ការផ្តោតតែទៅលើសិទ្ធិលើទ្រព្យសម្បត្តិតែមួយនោះ ពិតជាអាចនាំឲ្យមានការរំលោភលើសិទ្ធិមានលំនៅដ្ឋានសមរម្យ ជាក់ស្តែងមានជាអាទិ៍ ការបណ្តេញចេញដោយបំពានអ្នកតាំងទីលំនៅប្រមូលផ្តុំក្នុងទីប្រជុំជនតាមតំបន់ក្រីក្រ ដែលតាំងទីលំនៅលើដីឯកជនជាដើម។ ម្យ៉ាងវិញទៀត ការការពារសិទ្ធិលើអចលនទ្រព្យ អាចមានសារៈសំខាន់ផងដែរក្នុងការធានាឲ្យក្រុមមនុស្សជាក់លាក់មួយចំនួន អាចប្រើប្រាស់សិទ្ធិមានលំនៅដ្ឋានសមរម្យរបស់ខ្លួន។ ការទទួលស្គាល់សិទ្ធិស្មើគ្នារបស់ "សហព័ទ្ធ" លើទ្រព្យសម្បត្តិគ្រួសារ ជាញឹកញាប់ វាជាកត្តាសំខាន់មួយ ក្នុងការ

[៥] ការងាររបស់បណ្តាញដីធ្លីសកល (GLTN) ដែលសម្របសម្រួលដោយ UN-Habitat មានគោលដៅចាត់វិធានការឲ្យកាន់តែទូលំទូលាយថែមទៀត ចំពោះបញ្ហាដីធ្លី ដោយពង្រឹងការសម្របសម្រួលជាសកល រាប់ទាំង តាមរយៈការបង្កើតទំនាក់ទំនងមិនអាចកាត់ផ្តាច់បាននៃសិទ្ធិដីធ្លី ជាជាងការគ្រាន់តែផ្តោតការយកចិត្តទុកដាក់ទៅលើការផ្តល់កម្មសិទ្ធិដីធ្លីជាលក្ខណៈបុគ្គលនោះ។ សូមមើលគេហទំព័រ www.gltn.net

ធានាឲ្យស្ត្រីទទួលបានសិទ្ធិស្មើគ្នា និងមិនមានការរើសអើងចំពោះសិទ្ធិមានលំនៅដ្ឋានសមរម្យ។

- **សិទ្ធិមានលំនៅដ្ឋានសមរម្យ មិនដូចគ្នានឹងលើសិទ្ធិលើដីធ្លីឡើយ ។** ជួនកាល មានការជំទាស់ថា សិទ្ធិមានលំនៅដ្ឋានសមរម្យ គឺស្មើគ្នានឹងសិទ្ធិលើដីធ្លី។ សិទ្ធិលើដីធ្លី អាចបង្កើតជាសមាសភាពមួយដ៏សំខាន់នៃការសម្រេចបានសិទ្ធិមានលំនៅដ្ឋានសមរម្យ ជាពិសេស នៅតំបន់ជនបទ ឬ សម្រាប់ជនជាតិដើមភាគតិច។ លំនៅដ្ឋានមិនសមរម្យ ឬការអនុវត្តការបណ្តេញចេញដោយបំពាន អាចជាបច្ច័យដែលកើតចេញពីការមិនទទួលស្គាល់សិទ្ធិប្រើប្រាស់ដីធ្លី និងធនធានទ្រព្យសម្បត្តិរួម។ ក្នុងទិដ្ឋភាពនេះ ការប្រើប្រាស់សិទ្ធិមានលំនៅដ្ឋានសមរម្យ ក្នុងករណីខ្លះអាចនឹងតម្រូវឲ្យធ្វើការធានាដល់លទ្ធភាពប្រើប្រាស់ និងគ្រប់គ្រងដីធ្លី។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ មិនទទួលស្គាល់សិទ្ធិដីធ្លីតែឯកឯងឡើយ។[៦]

- **សិទ្ធិមានលំនៅដ្ឋានសមរម្យ រាប់បញ្ចូលទាំងការធានាឲ្យមានការទទួលបានសេវាសមរម្យផងដែរ។** សិទ្ធិមានលំនៅដ្ឋានសមរម្យ មិនសំដៅត្រឹមតែថាសំណង់លំនៅដ្ឋានផ្ទាល់ ត្រូវតែមានលក្ខណៈសមស្របប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានផងដែរ នូវលទ្ធភាពទទួលបានប្រកបដោយចិរភាព និងគ្មានការរើសអើងនូវសេវាផ្សេងៗដែលសំខាន់ចាំបាច់សម្រាប់សុខភាព សន្តិសុខ ផាសុកភាព និងអាហារូបត្ថម្ភ។ ឧទាហរណ៍ ត្រូវមានលទ្ធភាព

[៦] "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីភាពរស់នៅសមរម្យ លោក Miloon Kothari "(A/HRC/4/18, កថាខ័ណ្ឌ ២៦ និង ៣១)។ អ្នករាយការណ៍ពិសេសរូបនេះ បានទទួលស្គាល់ និងបានគូសបញ្ជាក់ពីសារៈសំខាន់នៃដីធ្លីថាជា "សមាសភាពសំខាន់មួយ" នៃសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ ហើយបានអំពាវនាវឲ្យក្រុមប្រឹក្សាសិទ្ធិមនុស្ស ធានាឲ្យមាន "ការទទួលស្គាល់ នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ថា ដីធ្លី គឺជាសិទ្ធិមនុស្ស"។

ប្រើប្រាស់ទឹកពិសារមានសុវត្ថិភាព ថាមពលអគ្គិសនីសម្រាប់ ចំអិនម្ហូបអាហារ ប្រព័ន្ធកំដៅ ភ្លើងបំភ្លឺ អនាម័យ និងឧបករណ៍បោកគក់ កន្លែងរក្សាទុកដាក់ម្ហូបអាហារ កន្លែងចាក់កាកសំណល់ ប្រព័ន្ធបង្ហូរទឹក និងសេវាសង្គ្រោះបន្ទាន់។

## គ. ទំនាក់ទំនងរវាងសិទ្ធិមានលំនៅដ្ឋានសមរម្យ និងសិទ្ធិមនុស្សដទៃទៀត

សិទ្ធិមនុស្សគឺពឹងអាស្រ័យគ្នា មិនអាចញែកដាច់ពីគ្នា និងមានទំនាក់ទំនងគ្នាទៅវិញទៅមក។ម្យ៉ាងទៀត ការរំលោភសិទ្ធិមានលំនៅដ្ឋានសមរម្យ អាចប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិជាច្រើនទៀត ឬប៉ះពាល់គ្នាទៅវិញទៅមក។

លទ្ធភាពទទួលបានលំនៅដ្ឋានសមរម្យ អាចជាលក្ខខ័ណ្ឌតម្រូវជាមុនមួយសម្រាប់ការទទួលបានសិទ្ធិមនុស្សមួយចំនួនទៀត ដូចជា សិទ្ធិការងារ សិទ្ធិសុខភាព សិទ្ធិទទួលបានសន្តិសុខសង្គម សិទ្ធិបោះឆ្នោត សិទ្ធិឯកជន ឬសិទ្ធិអប់រំ។ លទ្ធភាពក្នុងការប្រកបរបរចិញ្ចឹមជីវិតអាចនឹងបាត់បង់ នៅពេលដែលមនុស្សម្នាក់ត្រូវតាំងទីលំនៅថ្មីបន្ទាប់ពីការបណ្តេញចេញដោយបំពាន នៅកន្លែងមួយដែលកាត់ផ្តាច់ចេញពីឱកាសការងារ។ ហើយប្រសិនជាគ្មានលិខិតបញ្ជាក់ទីលំនៅច្បាស់លាស់ទេ អ្នកគ្មានផ្ទះសម្បែងទាំងនោះ អាចនឹងមិនមានសិទ្ធិបោះឆ្នោត សិទ្ធិទទួលបានសេវាសង្គម ឬសេវាសុខភាពឡើយ។ សាលារៀនអាចនឹងបដិសេធការចុះឈ្មោះកុមារនៅតំបន់ក្រីក្រតាមទីប្រជុំជន ដោយសារតែការតាំងទីលំនៅរបស់ពួកគេមានលក្ខណៈមិនផ្លូវការ។ លំនៅដ្ឋានមិនសមរម្យ អាចប៉ះពាល់ដល់សិទ្ធិសុខភាព ពោលគឺ ប្រសិនបើផ្ទះសម្បែង និងកន្លែងតាំងទីលំនៅនោះ មានកម្រិត ឬគ្មានទឹកពិសារមានសុវត្ថិភាព និងអនាម័យទេ អ្នករស់នៅទីនោះអាចនឹងធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ។

ការបណ្តេញចេញដោយបំពាន អាចមានផលប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិមនុស្សមួយចំនួន ដូចជា សិទ្ធិអប់រំ និងសិទ្ធិមានសន្តិសុខផ្ទាល់ខ្លួនជាដើម។

ជាញឹកញាប់ ការបណ្តេញចេញដោយបំពាន ធ្វើឲ្យរអាក់ខានដល់ការសិក្សារបស់កុមារ ឬបញ្ឈប់ការសិក្សាពួកគេទាំងស្រុងតែម្តង។ ការឈឺចាប់ផ្លូវកាយ ឬផ្លូវចិត្ត ដែលបានជួបប្រទះបន្ទាប់ពីការបណ្តេញចេញដោយបំពាននេះ ក៏អាចធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពរបស់កុមារក្នុងការរៀនសូត្រផងដែរ។ នៅក្នុងអំឡុងពេលនៃការបណ្តេញចេញដោយបំពាន ជាញឹកញាប់ ប្រជាជនត្រូវបានគេវាយដំធ្វើបាប ឬយាយីរំខាន ហើយជួនកាល ត្រូវទទួលរងការប្រព្រឹត្តិដោយអមនុស្សធម៌ ឬការសម្លាប់។ ជាពិសេស ស្ត្រី និងក្មេងស្រី មានភាពងាយរងគ្រោះដោយអំពើហឹង្សា រាប់ទាំង អំពើហឹង្សាផ្លូវភេទ នៅមុនពេល នៅក្នុងអំឡុងពេល និងនៅក្រោយពេលនៃការបណ្តេញចេញ។

ទន្ទឹមនឹងនេះ សិទ្ធិមានលំនៅដ្ឋានសមរម្យដែលរងការរំលោភបំពាននោះអាចជះឥទ្ធិពលទៅលើសិទ្ធិមនុស្សដទៃទៀត ដែលត្រូវបានធានាការពារ។ សិទ្ធិមានលំនៅដ្ឋានសមរម្យ នឹងមានហានិភ័យខ្ពស់ ចំពោះអ្នកដែលត្រូវគេបដិសេធសិទ្ធិអប់រំ សិទ្ធិការងារ និងសិទ្ធិទទួលបានសន្តិសុខសង្គម។ ការកែលំអស្ថានភាពលំនៅដ្ឋាន និងការការពារប្រឆាំងនឹងការបណ្តេញចេញដោយបំពាន ជារឿយៗ ត្រូវពឹងផ្អែកលើការប្តឹងទាមទារ ដែលធ្វើឡើងដោយអ្នកដែលរងផលប៉ះពាល់ផ្ទាល់។ ប្រសិនបើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិជួបប្រជុំ ឬ សិទ្ធិបង្កើតសមាគម មិនត្រូវបានគេគោរពទេនោះ លទ្ធភាពសម្រាប់បុគ្គល និងសហគមន៍ ក្នុងការតស៊ូមតិឲ្យមានជីវភាពរស់នៅប្រសើរឡើង ក៏ត្រូវបានកាត់បន្ថយយ៉ាងខ្លាំងដែរ។ អ្នកការពារសិទ្ធិមនុស្សដែលធ្វើការងារ ដើម្បីការពារសិទ្ធិរបស់បុគ្គលនិងសហគមន៍ឲ្យមានលំនៅដ្ឋានសមរម្យ ជារឿយៗបានទទួលរងអំពើហឹង្សា ការចាប់ខ្លួន និងការឃុំខ្លួនតាមទំនើងចិត្ត និងមានរយៈពេលយូរ។

## ឃ. តើគោលការណ៍មិនរើសអើងអនុវត្តដោយរបៀបណា?

ការរើសអើងសំដៅទៅលើការបែងចែក ការមិនរាប់បញ្ចូល ឬ ការរឹតត្បិតណាមួយ ដែលបានធ្វើឡើង ដោយផ្អែកលើចរិតលក្ខណៈជាក់លាក់របស់បុគ្គល

ណាមួយ ដូចជា ជាតិសាសន៍ សាសនា អាយុ ឬ ភេទ ដែលមានអានុភាព ឬ គោលបំណងប្រកាន់ពូជសាសន៍ ឬបដិសេធការទទួលស្គាល់ ការទទួលបាន ឬ ការប្រើប្រាស់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ វាមានទំនាក់ទំនងទៅនឹង ការមើលរំលង ឬការមិនគិតគូយកចិត្តទុកដាក់ដល់ក្រុមមនុស្សជាក់លាក់មួយ ចំនួន ហើយជាទូទៅ វាគឺជាឫសគល់នៃអសមភាពផ្នែករចនាសម្ព័ន្ធនៅក្នុង សង្គម។

ក្នុងវិស័យលំនៅដ្ឋាន ការរើសអើងអាចកើតចេញពីច្បាប់ គោលនយោបាយ ឬ វិធានការដែលមានលក្ខណៈរើសអើង បទប្បញ្ញត្តិកំណត់តំបន់ ក្នុងទីក្រុង គោលនយោបាយអភិវឌ្ឍន៍ដែលផាត់ក្រុមណាមួយចេញ ការផាត់ ចេញពីការទទួលបានផលប្រយោជន៍ខាងលំនៅដ្ឋាន ការបដិសេធសុវត្ថិភាព កាន់កាប់ កង្វះនូវការទទួលបានឥណទាន ការចូលរួមដ៏មានកម្រិតក្នុងការធ្វើ សេចក្តីសម្រេចចិត្ត ឬ កង្វះការការពារប្រឆាំងនឹងការរើសអើងពីសំណាក់វិស័យ ឯកជន។

ការមិនរើសអើង និងសមភាព គឺជាគោលការណ៍គ្រឹះនៃសិទ្ធិមនុស្ស និង ជាសមាសភាពដ៏សំខាន់នៃសិទ្ធិមានលំនៅដ្ឋានសមរម្យ។ កតិកាសញ្ញាអន្តរ ជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅក្នុងមាត្រា ២ (២) នៃកតិកា សញ្ញានោះបានកំណត់មូលដ្ឋានមួយចំនួនដែលគ្មានការរើសអើង មានដូចជា ជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ឬ ទស្សនៈផ្សេងទៀត ដើមកំណើតជាតិ ឬឋានៈសង្គម ទ្រព្យសម្បត្តិ កំណើត ឬ ស្ថានភាពឯទៀត។ បើតាមការបញ្ជាក់របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ *"ស្ថានភាពឯទៀត"* អាចនឹងរាប់បញ្ចូលទាំង ពិការភាព ស្ថានភាពសុខភាព (ដូចជា មេរោគអេដស៍/ជំងឺអេដស៍) ឬការកំណត់អត្ត សញ្ញាណភេទ។ អ្នករាយការណ៍ពិសេសស្តីពីលំនៅដ្ឋានសមរម្យ ក៏បានគូស បញ្ជាក់ផងដែរថា ការរើសអើង និងការផាត់ចេញ ក្នុងវិស័យលំនៅដ្ឋាន អាច បណ្តាលមកពីភាពក្រីក្រ និងគម្លាតសេដ្ឋកិច្ច។

ផលប៉ះពាល់នៃការរើសអើង កាន់តែធ្ងន់ធ្ងរឡើងថែមទៀត កាលណាបុគ្គលម្នាក់ទទួលរងការរើសអើងពីរយ៉ាង ឬច្រើនយ៉ាង ដូចជា ឈរលើមូលដ្ឋាននៃភេទ និងជាតិសាសន៍ ដើមកំណើតជាតិ ឬពិការភាព ជាដើម។ គណៈកម្មាធិការនេះ បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការដោះស្រាយបញ្ហាការរើសអើងប្រភេទនេះ នៅក្នុងសេចក្តីពន្យល់រួមលេខ១៦ (២០០៥) ស្តីពីសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងការប្រើប្រាស់ ទទួលបាន សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ។

រដ្ឋទាំងឡាយ មានកាតព្វកិច្ចហាមប្រាម និងបំបាត់ការរើសអើងតាមគ្រប់រូបភាព និងធានាសមភាពចំពោះការទទួលបានលំនៅដ្ឋានសមរម្យទាំងតាមផ្លូវច្បាប់ និងតាមការអនុវត្តជាក់ស្តែង និងការការពារប្រឆាំងនឹងការបណ្តេញចេញដោយបំពាន។

## ង. សិទ្ធិមានលំនៅដ្ឋានសមរម្យ នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ

សិទ្ធិមានលំនៅដ្ឋានសមរម្យ គឺជាសិទ្ធិមនុស្ស ដែលត្រូវបានទទួលស្គាល់ក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិថា ជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ។

ឯកសារមួយក្នុងចំណោមឯកសារយោងដំបូងនៃសិទ្ធិនេះ គឺមាននៅក្នុងមាត្រា ២៥ (១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាទូទៅត្រូវបានគេចាត់ទុកថាជាលិខិតុបករណ៍មួយដ៏សំខាន់ សម្រាប់ការពារសិទ្ធិមានលំនៅដ្ឋានសមរម្យសំដៅដល់*សិទ្ធិរបស់ជនគ្រប់រូប ក្នុងការមានកម្រិតជីវភាពរស់នៅសមរម្យសម្រាប់ខ្លួនផ្ទាល់ និងសម្រាប់ក្រុមគ្រួសារខ្លួន រួមមាន ចំណីអាហារ សំលៀកបំពាក់ និងលំនៅដ្ឋានសមរម្យ ព្រមទាំង ការរីកចំរើនជាលំដាប់នៃលក្ខខណ្ឌរស់នៅរបស់គេ (មាត្រា ១១)*។

ដូចបានបញ្ជាក់ខាងលើ គណៈកម្មាធិការនេះ បានអនុម័តសេចក្តីពន្យល់រួមស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ និងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងលំនៅដ្ឋាន ដោយផ្តល់ការណែនាំដ៏សំខាន់អំពីការអនុវត្តន៍បទប្បញ្ញត្តិនៃកតិកាសញ្ញានេះ ជាពិសេស សេចក្តីពន្យល់រួមនៃកតិកាសញ្ញានេះ លេខ ៤, ៧ និង ១៦។

សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដទៃទៀត បានលើកឡើងពីសិទ្ធិមានលំនៅដ្ឋានសមរម្យតាមវិធីផ្សេងៗគ្នា។ សន្ធិសញ្ញាខ្លះ និយាយអំពីការអនុវត្តន៍ទូទៅ ខ្លះទៀតនិយាយតែអំពីសិទ្ធិរបស់ក្រុមមនុស្សជាក់លាក់មួយចំនួន ដូចជា ស្ត្រី កុមារ ជនជាតិដើមភាគតិច ពលករទេសន្តប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ឬ ជនពិការ ជាដើម។

**សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដទៃទៀត ដែលទទួលស្គាល់សិទ្ធិមានលំនៅដ្ឋានសមរម្យ**

- អនុសញ្ញាឆ្នាំ១៩៥១ ពាក់ព័ន្ធនឹងឋានៈជនភៀសខ្លួន (មាត្រា ២១)
- អនុសញ្ញាអង្គការពលកម្មអន្តរជាតិ(ILO) ឆ្នាំ ១៩៦២ លេខ ១១៧ ពាក់ព័ន្ធនឹងគោលដៅមូលដ្ឋាន និងបទដ្ឋានគោលនយោបាយសង្គម (មាត្រា ៥ (២))
- អនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៥ ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (មាត្រា ៥ (ង) (iii))
- កតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រា ១៧)
- អនុសញ្ញាឆ្នាំ ១៩៧៩ ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (មាត្រា ១៤ (២) និង ១៥ (២))
- អនុសញ្ញាឆ្នាំ ១៩៨៩ ស្តីពីសិទ្ធិកុមារ (មាត្រា ១៦ (១) និង ២៧ (៣))
- អនុសញ្ញាអង្គការពលកម្មអន្តរជាតិ (ILO) ឆ្នាំ ១៩៨៩ លេខ ១៦៩ ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច និងពួកកុលសម្ព័ន្ធនៅក្នុង

ប្រទេសឯករាជ្យ (មាត្រា ១៥, ១៦ និង ១៧)
- អនុសញ្ញាអន្តរជាតិឆ្នាំ ១៩៩០ ស្ដីពីការការពារពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ (មាត្រា ៤៣ (១) (*ឃ*))
- អនុសញ្ញាឆ្នាំ ២០០៦ ស្ដីពីសិទ្ធិជនពិការ (មាត្រា ៩ និង ២៨)

នៅថ្នាក់តំបន់ សិទ្ធិមានលំនៅដ្ឋានសមរម្យ ត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញាអឺរ៉ុបស្ដីពីស្ថានភាពផ្លូវច្បាប់នៃពលករទេសន្តរប្រវេសន៍(១៩៧៧) ធម្មនុញ្ញអាហ្វ្រិកស្ដីពីសិទ្ធិ និងសុខុមាលភាពកុមារ(១៩៩០) និងធម្មនុញ្ញសង្គមអឺរ៉ុបដែលបានកែតម្រូវឡើងវិញ(១៩៩៦)។ បើទោះជា អនុសញ្ញាអឺរ៉ុបស្ដីពីការលើកស្ទួយសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន(១៩៥០) ធម្មនុញ្ញសង្គមអឺរ៉ុប (១៩៦១) អនុសញ្ញាអាមេរិកស្ដីពីសិទ្ធិមនុស្ស(១៩៦៩) និងធម្មនុញ្ញអាហ្វ្រិកស្ដីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ(១៩៨១) មិនចែងលំអិតអំពីសិទ្ធិមានលំនៅដ្ឋានសមរម្យក្ដី ក៏ការការពារ ដែលមាននៅក្នុងយុត្តិសាស្ត្ររបស់ខ្លួន បានទាញយកចេញមកពីការប្រើប្រាស់សិទ្ធិមនុស្សផ្សេងៗទៀត ដូចជា សិទ្ធិឯកជន សិទ្ធិលើទ្រព្យសម្បត្តិ និងសិទ្ធិប្រើប្រាស់ភោគៈដោយសន្តិភាព និងសិទ្ធិទទួលបានការការពារសម្រាប់គ្រួសារ។

### សិទ្ធិមានលំនៅដ្ឋានសមរម្យ ក្នុងធម្មនុញ្ញអាហ្វ្រិកស្ដីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ

នៅក្នុងករណីបណ្ដឹងរវាង *មជ្ឈមណ្ឌលសកម្មភាពសិទ្ធិសង្គម និងសេដ្ឋកិច្ច និងមជ្ឈមណ្ឌលសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច និង ប្រទេសនីហ្សេរីយ៉ា* (លិខិតលេខ ១៥៥/៩៦) គណៈកម្មការអាហ្វ្រិកទទួលបន្ទុកសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ រកឃើញថា ខណៈដែលសិទ្ធិមានលំនៅដ្ឋានសមរម្យ មិនត្រូវបានគេទទួលស្គាល់ជាក់លាក់នៅក្នុងធម្មនុញ្ញនេះ ដូច្នេះ គេអាចធ្វើការពិចារណា ឬទាញសេចក្ដីសន្និដ្ឋានពីសិទ្ធិផ្សេងៗទៀតបាន៖

*ទោះបីជាសិទ្ធិមានលំនៅដ្ឋាន ឬទីជម្រក មិនមានចែងលំអិតក្នុងធម្មនុញ្ញអាហ្វ្រិកក្តី ក៏អានុភាពនៃការផ្សំបញ្ចូលគ្នានៃបទប្បញ្ញត្តិដែលការពារសិទ្ធិទទួលបានស្ថានភាពល្អប្រសើរបំផុត ផ្នែកសុខភាពផ្លូវកាយ និងផ្លូវចិត្ត... សិទ្ធិលើទ្រព្យសម្បត្តិ និងការការពារដល់គ្រួសារ ហាមឃាត់ការបំផ្លិចបំផ្លាញយ៉ាងព្រៃផ្សៃលើទីជម្រក ព្រោះថា កាលណាលំនៅដ្ឋានត្រូវបានគេបំផ្លិចបំផ្លាញហើយនោះ នោះទ្រព្យសម្បត្តិ សុខភាព និងជីវិតរស់នៅរបស់គ្រួសារក៏ត្រូវទទួលរងផលប៉ះពាល់អវិជ្ជមានផងដែរ។ ដូច្នេះហើយ គេបានកត់សំគាល់ឃើញថា ការផ្សំបញ្ចូលគ្នានៃមាត្រា ១៤, ១៦ និង ១៨ (១) មានអានុភាពបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់ថែមទៀត ទៅក្នុងធម្មនុញ្ញនេះ អំពីសិទ្ធិមានទីជម្រក និងលំនៅដ្ឋាន....។*

គោលការណ៍ណែនាំ និងគោលការណ៍អន្តរជាតិមួយចំនួន ក៏បរិយាយផងដែរ អំពីបទប្បញ្ញត្តិជាក់លាក់ទាក់ទងនឹងសិទ្ធិមានលំនៅដ្ឋានសមរម្យ។ បើទោះបីជា មិនមានកាតព្វកិច្ចចងភ្ជាប់តាមផ្លូវច្បាប់ក្តី ក៏គោលការណ៍ទាំងនោះផ្តល់នូវការណែនាំដ៏មានសារៈប្រយោជន៍អំពីការអនុវត្តន៍សិទ្ធិមានលំនៅដ្ឋានសមរម្យផងដែរ ជាពិសេស សម្រាប់ក្រុមជាក់លាក់មួយចំនួន ដូចជា ពលករជនភៀសខ្លួន និងអ្នកផ្លាស់ទីលំនៅក្នុងប្រទេស មនុស្សចាស់ជរា និងជនជាតិដើមភាគតិច។[៧] អ្វីដែលពាក់ព័ន្ធជាពិសេសនោះ គឺ*គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត*

[៧] គោលការណ៍អង្គការសហប្រជាជាតិសម្រាប់មនុស្សចាស់ជរា គោលការណ៍ស្តីពីការសងវិញ (បដិទាន) នូវលំនៅដ្ឋាននិងទ្រព្យសម្បត្តិសំរាប់ជនភៀសខ្លួន និងអ្នកផ្លាស់ទីលំនៅ គោលការណ៍ណែនាំស្តីពីការផ្លាស់ទីលំនៅក្នុងប្រទេស អនុសាសន៍របស់អង្គការពលកម្មអន្តរជាតិ ILO លេខ ១១៥ ពាក់ព័ន្ធនឹងលំនៅដ្ឋានរបស់ពលករ និងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច។

*ដោយផ្អែកលើការអភិវឌ្ឍន៍* ដែលបានបង្កើតឡើង ក្រោមអាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ។ គោលការណ៍ទាំងនោះ រៀបរាប់ត្រួសៗ អំពីកាតព្វកិច្ចរបស់រដ្ឋនានា ក្នុងការការពារប្រឆាំងនឹងការបណ្តេញចេញដោយបំពាន ជាមួយនឹងកាតព្វកិច្ចមួយចំនួនទៀត នៅមុនពេល នៅអំឡុងពេល និងនៅក្រោយពេលនៃការបណ្តេញចេញដោយផ្អែកលើការអភិវឌ្ឍន៍។

**គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត ដោយផ្អែកលើការអភិវឌ្ឍន៍**

២២. រដ្ឋទាំងឡាយ ត្រូវតែអនុម័តវិធានការច្បាប់ និងគោលនយោបាយនានា ហាមប្រាមការបណ្តេញចេញ ដែលមិនស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន........

៣២....ការវាយតម្លៃអំពីផលប៉ះពាល់ទូទៅ និងគ្រប់ជ្រុងជ្រោយ គួរតែអនុវត្តមុនពេលមានគំនិតផ្តួចផ្តើមបង្កើតគម្រោងណាមួយដែលអាចនាំឲ្យមានការបណ្តេញចេញ និងផ្លាស់ទីលំនៅ ដោយផ្អែកលើការអភិវឌ្ឍន៍... ការវាយតម្លៃអំពី "ផលប៉ះពាល់នៃការបណ្តេញចេញ" ក៏គួរតែរាប់បញ្ចូលទាំងការរិះរកជម្រើស និងយុទ្ធសាស្ត្រនានា ដើម្បីបង្រួមផលប៉ះពាល់ឲ្យមកនៅកម្រិតអប្បបរមាផងដែរ។

៣៧... ការរៀបចំផែនការទីក្រុង ឬ ជនបទ និងដំណើរការអភិវឌ្ឍ គួរតែមានការចូលរួមពីអ្នកដែលទំនងទទួលរងផលប៉ះពាល់.......

៣៨... រដ្ឋទាំងឡាយ គួរតែស្វែងរកឲ្យបានពេញលេញនូវជម្រើសទាំងអស់ដែលអាចមានមុននឹងឈានដល់ការបណ្តេញចេញ.......

៥២. ... ក្នុងកម្រិតអប្បបរមា... អាជ្ញាធរមានសមត្ថកិច្ចគួរតែធានាថា មនុស្ស ឬ ក្រុមមនុស្សដែលបានបណ្តេញចេញទាំងអស់.....មានលទ្ធ

ភាពទទួលបានគត់មត់ និងប្រកបដោយសុវត្ថិភាពនូវ ៖ (ក) អាហារចាំបាច់ ទឹកស្អាត និងអនាម័យ (ខ) ទីជម្រក និងលំនៅដ្ឋានជាចាំបាច់ (គ) សំលៀកបំពាក់សមរម្យ (ឃ) សេវាពេទ្យចាំបាច់ (ង) ប្រភពរបរចិញ្ចឹមជីវិត (ច) ចំណីសម្រាប់សត្វពាហនៈ និងលទ្ធភាពទទួលបានប្រភពធនធានរួម ដែលពួកគេពឹងអាស្រ័យកន្លងមក (ឆ) ការអប់រំសម្រាប់កុមារ និងសេវាគាំពារកុមារ....

៥៥. កន្លែងតាំងទីលំនៅថ្មីដែលបានកំណត់យក ត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់លំនៅដ្ឋានសមរម្យ ស្របតាមច្បាប់អន្តរជាតិ...។

សន្និសីទ សេចក្តីប្រកាស និងផែនការសកម្មភាពជាច្រើន ដូចជា សេចក្តីប្រកាសទីក្រុងវេនខូវ័រ (Vancouver) ស្តីពីការតាំងទីលំនៅសម្រាប់មនុស្ស (១៩៧៦) របៀបវារៈ ២១ (១៩៩២) សេចក្តីប្រកាសទីក្រុងអ៊ីស្តង់ប៊ូល (Istanbul) ស្តីពីការតាំងទីលំនៅសម្រាប់មនុស្ស (១៩៩៦) របៀបវារៈលំនៅដ្ឋាន(១៩៩៦) និងសេចក្តីប្រកាសសហសវត្សរ៍ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (២០០០) ក៏បានជួយស្រាយបំភ្លឺអំពីទិដ្ឋភាពផ្សេងៗនៃសិទ្ធិមានលំនៅដ្ឋានសមរម្យ និងបានបញ្ជាក់ឡើងវិញ អំពីការសន្យារបស់រដ្ឋនានា ក្នុងការធ្វើឲ្យសម្រេចគោលដៅនេះ។

### របៀបវារៈនៃលំនៅដ្ឋាន

លទ្ធផលនៃសន្និសីទស្តីពីលំនៅដ្ឋានលើកទី២- សេចក្តីប្រកាសទីក្រុងអ៊ីស្តង់ប៊ូល (Istanbul) និងរបៀបវារៈស្តីពីលំនៅដ្ឋាន បានបង្កើតនូវក្របខ័ណ្ឌសម្រាប់ភ្ជាប់ទំនាក់ទំនងការអភិវឌ្ឍន៍ការតាំងទីលំនៅ សម្រាប់មនុស្សជាតិ ទៅនឹងការធ្វើឲ្យសម្រេចបាននូវសិទ្ធិមនុស្សជាទូទៅ និងជាពិសេស សិទ្ធិមានលំនៅដ្ឋានសមរម្យ។ របៀបវារៈស្តីពីលំនៅដ្ឋាន

បញ្ជាក់ថា *នៅក្នុងបរិបទទាំងមូលនៃវិធីសាស្ត្រផ្ដល់លទ្ធភាព រដ្ឋាភិបាលទាំងឡាយ គួរតែចាត់វិធានការសមស្រប ដើម្បីលើកស្ទួយការពារ និងធានាការធ្វើឲ្យសម្រេចបានទាំងស្រុង និងការរីកចម្រើនជាលំដាប់នៃសិទ្ធិមានលំនៅដ្ឋានសមរម្យ* (កថាខ័ណ្ឌ ៦១)។

ច្បាប់មនុស្សធម៌អន្តរជាតិ ក៏បានតម្រូវឲ្យមានការការពារចំពោះសិទ្ធិមានលំនៅដ្ឋានសមរម្យ នៅក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធអន្តរជាតិ និងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិផងដែរ។[៨] លក្ខន្តិកៈទីក្រុងរ៉ូមស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ចាត់ទុកថាជាឧក្រិដ្ឋកម្មសង្គ្រាម នូវការបំផ្លិចបំផ្លាញធំធេង និងការដកហូតយកទ្រព្យសម្បត្តិ ដោយមិនបានបង្ហាញពីភាពចាំបាច់ផ្នែកយោធា និងដែលបានអនុវត្តដោយខុសច្បាប់ និងយ៉ាងព្រៃផ្សៃ (មាត្រា ៨)។

នៅទីបំផុត រដ្ឋធម្មនុញ្ញជាច្រើន ចែងយ៉ាងច្បាស់អំពីសិទ្ធិមានលំនៅដ្ឋានសមរម្យ មានជាអាទិ៍ រដ្ឋធម្មនុញ្ញរបស់ប្រទេសប៊ែលហ្ស៊ិក សេសែល អាហ្វ្រិកខាងត្បូង និងអ៊ុយរ៉ាហ្គាយ។[៩] រដ្ឋធម្មនុញ្ញរបស់ប្រទេសដទៃទៀត ស្នើសុំឲ្យមានការទទួលខុសត្រូវទូទៅរបស់រដ្ឋ ក្នុងការធានាឲ្យមានលំនៅដ្ឋាន និងជីវភាពសមរម្យសម្រាប់ទាំងអស់គ្នា។[១០]

---

[៨] អនុសញ្ញាហ្សឺណែវ លើកទី ៤ ពាក់ព័ន្ធនឹងការការពារជនស៊ីវិលនៅក្នុងពេលមានសង្គ្រាម (មាត្រា ៥៣) ពិធីសារ I (មាត្រា ៦៩) ពិធីសារ II (មាត្រា ១៧)។

[៩] សូមមើលផងដែរ នូវរដ្ឋធម្មនុញ្ញរបស់ប្រទេសអេក្វាឌ័រ ហ្គួយ៉ាណា ហៃទី ហុងឌូរ៉ាស់ អ៊ីរ៉ង់ (សាធារណរដ្ឋអ៊ីស្លាមនៃ) ម៉ាល់ឌីវស៍ ម៉ាលី ម៉ិកស៊ិក នីការ៉ាហ្គា ប៉ាណាម៉ា ប៉ារ៉ាហ្គាយ ពៃរ៉ូ ព័រទុយហ្គាល់ សហព័ន្ធរូស្ស៊ី សាវតូម៉េ និងប្រាំងស៊ីប និងអេស្ប៉ាញ។

[១០] សូមមើលរដ្ឋធម្មនុញ្ញរបស់ប្រទេសអាហ្សង់ទីន បង់ក្លាដេស ប្រេស៊ីល បួគីណា ហ្វាសូ កូឡុំប៊ី កូស្តារីកា សាធារណរដ្ឋដូមីនីក អែលសាវ៉ាឌ័រ ហ្វាំងឡង់ ហ្គាតេម៉ាឡា ណេប៉ាល់ ហូឡង់ នីហ្សេរីយ៉ា ប៉ាគីស្ថាន ហ្វីលីពីន ប៉ូឡូញ សាធារណរដ្ឋកូរ៉េ ស្រីលង្កា ស៊ុយអែត ស្វីស ទួរគី វេនេហ្ស៊ូអេឡា (សាធារណរដ្ឋបូលីវ៉ា) និង វៀតណាម។

**សិទ្ធិមានលំនៅដ្ឋានសមរម្យនៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសដែលបានជ្រើសរើសមួយចំនួន**

*រដ្ឋធម្មនុញ្ញរបស់ប្រទេសម៉ិកស៊ិក ឆ្នាំ១៩១៧ (បានធ្វើវិសោធនកម្មក្នុងឆ្នាំ១៩៨៣)*

មាត្រា ៤ [...] គ្រួសារនីមួយៗ មានសិទ្ធិទទួលបានលំនៅដ្ឋានត្រឹមត្រូវ និងសមរម្យ ។ ច្បាប់ត្រូវបង្កើតលិខិតុបករណ៍ និងជំនួយគាំទ្រចាំបាច់ផ្សេងៗ ដើម្បីសម្រេចគោលដៅ ដូចមានចែងខាងលើ [...]។

*រដ្ឋធម្មនុញ្ញរបស់ប្រទេសព័រទុយហ្គាល់ ឆ្នាំ១៩៧៦ (ច្បាប់កែសម្រួលឡើងវិញ លើកទី៤ ផ្អែកលើច្បាប់រដ្ឋធម្មនុញ្ញ លេខ ១/៩៧ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ១៩៩៧)*

មាត្រា ៦៥ ៖ លំនៅដ្ឋាន និងនគរូបនីយកម្ម

(១) មនុស្សគ្រប់រូបមានសិទ្ធិ ទាំងសម្រាប់ផ្ទាល់ខ្លួន និងសម្រាប់គ្រួសាររបស់ខ្លួន ក្នុងការទទួលបានទីកន្លែងស្នាក់នៅដែលមានទំហំធំល្មម ស្របតាមបទដ្ឋានសមស្របខាងអនាម័យ និងផាសុខភាព និងរក្សាបាននូវភាពឯកជនរបស់បុគ្គល និងក្រុមគ្រួសារ។

*រដ្ឋធម្មនុញ្ញសហព័ន្ធរុស្ស៊ី ឆ្នាំ១៩៩៣*

មាត្រា ៤០

(១) ជនគ្រប់រូបមានសិទ្ធិមានលំនៅដ្ឋាន។ គ្មាននរណាម្នាក់ត្រូវបានគេបណ្តេញចេញពីលំនៅដ្ឋានរបស់ខ្លួន តាមទំនើងចិត្តឡើយ។

*រដ្ឋធម្មនុញ្ញអាហ្វ្រិកខាងត្បូង ឆ្នាំ១៩៩៦*

*មាត្រា ២៦ ៖ លំនៅដ្ឋាន*

*(១) ជនគ្រប់រូបមានសិទ្ធិមានលំនៅដ្ឋានសមរម្យ។*

*(២) រដ្ឋត្រូវចាត់វិធានការសមស្របតាមផ្លូវច្បាប់ និងចាត់វិធានការ*

*ដទៃទៀត តាមធនធានដែលខ្លួនមាន ដើម្បីឈានទៅសម្រេចបាន សិទ្ធិនេះ ជាលំដាប់។*

*(៣) គ្មាននរណាម្នាក់ត្រូវបានគេបណ្តេញចេញពីលំនៅដ្ឋានរបស់ខ្លួន ឬ ត្រូវបានគេវាយកំទេចលំនៅដ្ឋានរបស់ខ្លួន ដោយគ្មានដីការបស់តុលាការដែលបានចេញ បន្ទាប់ពីបានពិចារណាលើគ្រប់កាលៈទេសៈពាក់ព័ន្ធឡើយ។ គ្មានច្បាប់ណាមួយ ដែលអនុញ្ញាតឲ្យមានការបណ្តេញចេញតាមទំនើងចិត្តឡើយ។*

*មាត្រា ២៨ ៖ កុមារ*

(១) កុមារគ្រប់រូបមានសិទ្ធិមាន ... ទីជម្រក ...

*សូមមើលកម្មវិធីសិទ្ធិលំនៅដ្ឋានរបស់អង្គការសហប្រជាជាតិ "របាយការណ៍លេខ ១: ច្បាប់សិទ្ធិមនុស្ស ៖ ការត្រួតពិនិត្យឡើងវិញលើលិខិតុបករណ៍ច្បាប់ជាតិ និងអន្តជាតិ"* (២០០២)។

## II. តើសិទ្ធិមានលំនៅដ្ឋានសមរម្យអនុវត្តចំពោះក្រុមមនុស្សជាក់លាក់ដោយរបៀបណា?

ក្រុមមនុស្ស ឬបុគ្គលមួយចំនួន មានការលំបាកខ្លាំងក្នុងការអនុវត្តន៍សិទ្ធិមានលំនៅដ្ឋានសមរម្យរបស់ខ្លួន ដោយសារតែមូលហេតុ ថាតើពួកគេជានរណា ការរើសអើង ឬស្ថានភាពអសោចកេរ្តិ៍ (ស្ទិកម៉ា) ឬការរួមបញ្ចូលគ្នានៃកត្តាទាំងនេះ។ ដើម្បីការពារសិទ្ធិលំនៅដ្ឋានឲ្យមានប្រសិទ្ធភាព គេចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើស្ថានភាពជាក់ស្តែងរបស់បុគ្គល និងក្រុមមនុស្សទាំងនេះជាពិសេស អ្នកដែលកំពុងរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។ រដ្ឋទាំងឡាយគួរតែអនុម័តវិធានការវិជ្ជមានមួយចំនួន ដើម្បីធានាថា បុគ្គល និងក្រុមទាំងនេះមិនត្រូវបានគេរើសអើងមកលើខ្លួន ដោយសារតែហេតុផលនេះឡើយ ដូចជារដ្ឋទាំងឡាយគួរតែធ្វើច្បាប់ និងគោលនយោបាយស្តីពីលំនៅដ្ឋានឲ្យស្របតាមអ្នកដែលត្រូវការវាជាទីបំផុត ជាជាងការគ្រាន់តែផ្តោតគោលដៅទៅលើក្រុមមនុស្សភាគច្រើននោះ។

ការពិភាក្សាអំពីក្រុមមនុស្សជាក់លាក់មួយចំនួន ដែលបានកំណត់ខាងក្រោម គឺដើម្បីជួយបង្ហាញអំពីថា តើបទដ្ឋានស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យមានន័យដូចម្តេច នៅក្នុងការអនុវត្តន៍ជាក់ស្តែង។

### ក. ស្ត្រី

ទោះបីជាខ្វះទិន្នន័យ ហើយតួលេខមានការលំបាកនឹងធ្វើការវាយតម្លៃក្តី ក៏មានការយល់ឃើញជាទូទៅថា ស្ត្រីតំណាងឲ្យផ្នែកមួយដ៏សំខាន់ ក្នុងចំណោមអ្នកដែលមានលំនៅដ្ឋានមិនសមរម្យ។ ស្ត្រីប្រឈមនឹងការរើសអើងក្នុងទិដ្ឋភាពជាច្រើនខាងលំនៅដ្ឋាន ពីព្រោះដោយសារតែគាត់ជាស្ត្រី ឬ ដោយសារតែកត្តាដទៃទៀត ដូចជា ភាពក្រីក្រ អាយុ វណ្ណៈ អត្តសញ្ញាណភេទ ឬជាតិពន្ធុ។ នៅក្នុងផ្នែកជាច្រើននៃពិភពលោក ហើយជាពិសេស នៅតាមតំបន់ជនបទ ការប្រើ

ប្រាស់សិទ្ធិមានលំនៅដ្ឋានសមរម្យរបស់ស្ត្រី ជារឿយៗ គឺពឹងផ្អែកលើការទទួលបាន និងការគ្រប់គ្រងដីធ្លី និងទ្រព្យសម្បត្តិរបស់ពួកគេ។

**អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ**
**មាត្រា ១៤ (២)**

រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រី ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីនៅជនបទ ដើម្បីធានាថា ពួកគេចូលរួមក្នុងការអភិវឌ្ឍន៍ជនបទ និងទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍន៍ជនបទ និងជាពិសេសត្រូវធានាចំពោះស្ត្រីទាំងនោះនូវសិទ្ធិ ៖

[...]

(ជ) ទទួលបានពេញលេញនូវលក្ខខ័ណ្ឌរស់នៅសមរម្យ ជាពិសេសពាក់ព័ន្ធនឹងការមានផ្ទះសម្បែង អនាម័យ ការផ្គត់ផ្គង់អគ្គីសនី និងទឹក ការដឹកជញ្ជូន និងគមនាគមន៍។

**មាត្រា ១៥ (២)**

រដ្ឋភាគី ត្រូវផ្តល់ឲ្យស្ត្រីក្នុងបញ្ហារដ្ឋប្បវេណី នូវឋានៈនីត្យានុកូលដូចគ្នានឹងបុរស និងមានឱកាសដូចគ្នាក្នុងការប្រើប្រាស់ឋានៈនេះ។ ជាពិសេស រដ្ឋភាគី ត្រូវផ្តល់ឲ្យស្ត្រីនូវសិទ្ធិស្មើគ្នាក្នុងការចុះកិច្ចសន្យា និងការគ្រប់គ្រងទ្រព្យសម្បត្តិ និងត្រូវឲ្យមានការប្រព្រឹត្តមកលើស្ត្រីដូចគ្នានៅគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ និងសាលាក្តី។

ការរើសអើងប្រឆាំងនឹងស្ត្រីភេទ ក្នុងវិស័យលំនៅដ្ឋាន អាចបណ្តាល មកពី មានជាអាទិ៍៖ ច្បាប់សរសេរដែលមានការរើសអើង ច្បាប់ និង គោលនយោបាយដែលមានការរើសអើងផ្អែកយេនឌ័រ(ភេទ) ដែលមិនបានគិតគូរំពី

ស្ថានភាពពិសេសរបស់ស្ត្រី (ដូចជា ភាពងាយរងគ្រោះរបស់ពួកគេ ដោយអំពើហឹង្សាខាងផ្លូវភេទ និង ខាងផ្នែកយេនឌ័រ) ភាគលើសលុបនៃច្បាប់ទំនៀមទម្លាប់ និងការអនុវត្តន៍នានា ដែលរើសអើងចំពោះស្ត្រីភេទ ភាពលំអៀងក្នុងប្រព័ន្ធតុលាការ និងរដ្ឋបាលសាធារណៈ កង្វះការទទួលបានដំណោះស្រាយ ព័ត៌មាន ឬដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងកង្វះការយល់ដឹងអំពីសិទ្ធិ។ ការរើសអើងនេះ គឺត្រូវបានបញ្ជាក់បន្ថែមទៀតដោយកត្តារចនាសម្ព័ន្ធ និងប្រវត្តិសាស្ត្រ។

## ស្ត្រី និង ការទទួលមរតក

នៅក្នុងផ្នែកជាច្រើននៃពិភពលោកនេះ ស្ត្រី និងក្មេងស្រី ប្រឈមមុខនឹងការរើសអើងដែលចាក់ឫសយ៉ាងជ្រៅ ក្នុងការទទួលមរតក ដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ពួកគេក្នុងការទទួលបានយ៉ាងពេញលេញនូវសិទ្ធិមានលំនៅដ្ឋានសមរម្យ។ ការរើសអើងបែបនោះ អាចមានចែងនៅក្នុងច្បាប់សរសេរ (ច្បាប់ដែលសភាបានអនុម័ត) ក៏ដូចជា ច្បាប់ទំនៀមទម្លាប់ និងការអនុវត្តន៍ ដែលមិនបានទទួលស្គាល់សិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងការទទួលមរតក។ ហេតុដូច្នេះហើយ បានជាស្ត្រីមានសិទ្ធិទទួលបានមរតកក្នុងចំណែកមួយតិចតួចជាងសាច់ញាតិជាបុរស ឬត្រូវគេដកហូតសិទ្ធិទទួលមរតកពីប្តី ឬពីឪពុករបស់ខ្លួន ដែលបានទទួលអនិច្ចកម្ម។

អំពើហឹង្សាគឺជាបញ្ហារួម នៅក្នុងបរិបទនៃការទទួលមរតក ដោយសារតែទ្រព្យសម្បត្តិរបស់ស្ត្រី ត្រូវបានរឹបអូសយកដោយបង្ខំពីសំណាក់សាច់ញាតិ ហើយជាការប៉ុនប៉ងមួយដែលជារឿយៗតែងមានអំពើហឹង្សាខាងផ្លូវកាយ និងផ្លូវចិត្ត ហើយការប៉ះទង្គិចផ្លូវចិត្តនេះ ជាប់ជិតជាមរយៈពេលដ៏យូរ។ ជារឿយៗសាច់ញាតិដែលតែងតែបំពានលើ

ស្ត្រីមេម៉ាយ គឺគ្មានទោសពៃទ្បើយ ព្រោះគេយល់ឃើញថា វាគឺជាកិច្ចការឯកជនផ្ទាល់ខ្លួនរបស់គ្រួសារមួយ។

ប្រសិនបើស្ត្រីម្នាក់សម្រេចចិត្តតស៊ូទាមទារយកមរតក គាត់ក៏អាចប្រឈមនឹងអំពើហិង្សាពីសាច់ថ្លៃរបស់គាត់ ឬពីសហគមន៍ទាំងមូលផងក៏សឹងមាន។ ជាទូទៅ ការទាមទារមរតករបស់ស្ត្រី អាចនាំឲ្យមានការផាត់ចេញពីសង្គម ដែលមិនត្រឹមតែពីគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីសហគមន៍ទៀតផង។

*សូមមើល* "ស្ត្រី និងលំនៅដ្ឋានសមរម្យ ៖ ការសិក្សាធ្វើទ្បើងដោយអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពសមរម្យ លោក មីលូន ខូតារី" (ECN. ៤/២០០៥/៤៣, កថាខ័ណ្ឌ ៥៩–៦១)។

ស្ត្រី ប្រឈមនឹងការរើសអើងធ្ងន់ធ្ងរ ចំពោះសុវត្ថិភាពក្នុងការកាន់កាប់។ ទោះជាក្នុងរូបភាពណាក៏ដោយ សុវត្ថិភាពក្នុងការកាន់កាប់ ជារឿយៗ ត្រូវបានគេទទួលស្គាល់ កត់ត្រា ឬ ចុះបញ្ជីដោយប្រើឈ្មោះរបស់បុរស ហើយស្ត្រីគឺជាអ្នកនៅក្នុងបន្ទុក ជាសាច់ញាតិរបស់បុរសដែលមានសិទ្ធិកាន់កាប់។ ម្យ៉ាងវិញទៀត ប្រសិនបើសិទ្ធិកាន់កាប់មានរូបភាពជាសមូហភាពដែលមានស្ត្រីដែរនោះ នោះដំណើរការធ្វើសេចក្តីសម្រេច ជារឿយៗ បុរសគឺជាអ្នកដឹកនាំចាត់ចែង។

ក្រៅពីការគ្មានសិទ្ធិគ្រប់គ្រងលើលំនៅដ្ឋាន ដីធ្លី ឬ ទ្រព្យសម្បត្តិ ស្ត្រីមានស្វ័យភាពផ្ទាល់ខ្លួន ឬសេដ្ឋកិច្ចតិចតួច និងងាយទទួលរងការរំលោភបំពាននៅក្នុងរង្វង់គ្រួសារ សហគមន៍ និងសង្គមទាំងមូល។ កាលបើសិទ្ធិលើលំនៅដ្ឋាន ដីធ្លី ឬទ្រព្យសម្បត្តិ ត្រូវពឹងផ្អែកលើតតីយជន (ប្តី បងប្អូនប្រុស ឪពុក ឬសាច់ញាតិដទៃទៀតរបស់ខ្លួន) នោះ ពួកគាត់ងាយនឹងរងគ្រោះ ដោយការគ្មានផ្ទះ

សម្បែង ភាពក្រីក្រ និងការគ្មានមធ្យោបាយសម្រាប់ចិញ្ចឹមជីវិត ប្រសិនបើទំនាក់ទំនងនេះ លែងមានតទៅទៀតហើយនោះ។

បើទោះជាការបណ្តេញចេញដោយបំពាន មានផលប៉ះពាល់ទាំងលើបុរស និងស្ត្រីក្តី ក៏ស្ត្រីទំនងជាទទួលផលប៉ះពាល់មិនសមាមាត្រ។ ស្ត្រីប្រឈមមុខជារឿយៗនឹងអំពើហឹង្សា និងភាពតានតឹង ឬថប់អារម្មណ៍ធ្ងន់ធ្ងរ នៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលនៃការបណ្តេញចេញ ដោយសារតែអារម្មណ៍គាត់ជិតជាប់នឹងលំនៅដ្ឋាន និង តួនាទីរបស់គាត់ ជាអ្នកមើលថែទាំសមាជិកគ្រួសារទាំងមូល។[១១] ក្នុងអំឡុងពេលនៃការបណ្តេញចេញ ការជេរប្រមាថ ការវាយដំ និងអំពើរំលោភសេពសន្ថវៈ អាចនឹងកើតមាន។ បន្ទាប់ពីការបណ្តេញចេញ ជារឿយៗ ស្ត្រីងាយនឹងរងគ្រោះថែមទៀត ដោយការរំលោភបំពាន ជាពិសេស ប្រសិនបើ ពួកគាត់ត្រូវបានគេបង្ខំឲ្យផ្លាស់ទៅកាន់លំនៅដ្ឋានមួយមិនសមរម្យ ដូចជាការតាំងទីលំនៅក្នុងតំបន់មិនទាន់រៀបរយ។ ការគ្មានទីជម្រក និងគ្មានសិទ្ធិឯកជននៅកន្លែងតាំងទីលំនៅបែបនោះ អាចនាំឲ្យមានការប្រឈមខ្លាំងថែមទៀតនឹងអំពើហឹង្សាផ្លូវភេទ និង អំពើហឹង្សាក្នុងរូបភាពផ្សេងទៀត។ កាលបើស្ថានភាពលំនៅដ្ឋានមិនមានលក្ខណៈសមរម្យ ជារឿយៗ ស្ត្រីទទួលរងផលប៉ះពាល់មិនសមាមាត្រ។ ពោលគឺតាមធម្មតា ស្ត្រីជាអ្នករ៉ាប់រងការស្វែងរកទឹក ប្រសិនបើសេវាផ្គត់ផ្គង់ទឹក និងអនាម័យមិនគ្រប់គ្រាន់ ហើយជាញឹកញាប់ ពួកគាត់ត្រូវចំណាយពេលរហូតដល់ទៅបួនម៉ោងក្នុងមួយថ្ងៃ ដើម្បីដើរទៅ តម្រង់ជួរ និង រែកទឹកយកមកប្រើប្រាស់។

អំពើហិង្សាក្នុងគ្រួសារ ត្រូវបានគេកត់សម្គាល់ឃើញថា ជាមូលហេតុចម្បងដែលធ្វើឲ្យស្ត្រី និងកុមារគ្មានផ្ទះសម្បែង ជាពិសេស នៅពេលដែលមិន

[១១] "គោលនយោបាយសេដ្ឋកិច្ច និងសង្គមកិច្ច និងផលប៉ះពាល់ទៅលើអំពើហឹង្សាប្រឆាំងនឹងស្ត្រី" (E/CN.4/2000/68/dd.5)។

មានការការពារគ្រប់គ្រាន់ពីមន្ត្រីអនុវត្តច្បាប់ ឬ ពីប្រព័ន្ធច្បាប់ផ្ទាល់តែម្តង។ ផ្ទុយមកវិញ ការភ័យខ្លាចគ្មានផ្ទះសម្បែងរស់នៅ អាចបង្ខំឲ្យស្ត្រីបន្តរស់នៅតទៅទៀត ក្នុងទំនាក់ទំនងគ្រួសារដែលមានអំពើហឹង្សានោះ ។

## ខ. កុមារ

សុខភាព និងភាពជឿនលឿនខាងការរៀនសូត្រ និងសុខុមាលភាពទូទៅរបស់កុមារ មានឥទ្ធិពលយ៉ាងខ្លាំងពីគុណភាពនៃលំនៅដ្ឋានដែលពួកគេរស់នៅ។ ការគ្មានលំនៅដ្ឋានសមរម្យ ការបណ្តេញចេញដោយបំពាន ឬ ភាពគ្មានផ្ទះសម្បែង អាចនឹងមានផលប៉ះពាល់ជាខ្លាំងដល់កុមារ ដោយសារតែ សេចក្តីត្រូវការជាក់លាក់មួយចំនួនរបស់ពួកគេ ប៉ះពាល់ដល់ការលូតលាស់ ការអភិវឌ្ឍន៍ និងការទទួលបានសិទ្ធិមនុស្សយ៉ាងទូលំទូលាយ រួមមានសិទ្ធិអប់រំ សិទ្ធិសុខភាព និងសន្តិសុខផ្ទាល់ខ្លួន។

### អនុសញ្ញាស្តីពីសិទ្ធិកុមារ

**មាត្រា ១៦ (១)**

គ្មានកុមារណាម្នាក់ ត្រូវស្ថិតក្រោមការជ្រៀតជ្រែកតាមអំពើចិត្ត ឬ ដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន ឬការឆ្លើយឆ្លងរបស់កុមារ និងគ្មានកុមារណាម្នាក់ ត្រូវស្ថិតក្រោមការបំពារបំពានដោយខុសច្បាប់ លើកិត្តិយស និងកិត្តិនាមរបស់ខ្លួនឡើយ។

**មាត្រា ២៧**

១. រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់កុមារគ្រប់រូប ក្នុងការមានកម្រិតជីវភាពសមស្រប សម្រាប់ការអភិវឌ្ឍន៍រាងកាយ សតិបញ្ញា ស្មារតី សីលធម៌ និងសង្គមរបស់កុមារ។

២. ឪពុកម្ដាយ ឬអ្នកផ្សេងទៀត ដែលទទួលបន្ទុកលើកុមារ តាមលទ្ធភាពនិងសមត្ថភាពហិរញ្ញវត្ថុរបស់ខ្លួន គឺជាអ្នកទទួលខុសត្រូវទីមួយក្នុងការធានាឲ្យមានលក្ខខណ្ឌនៃការរស់នៅដែលចាំបាច់សម្រាប់ការរីកលូតលាស់របស់កុមារ។

៣. រដ្ឋភាគី ដោយយោងតាមស្ថានភាពជាតិ និងក្នុងកម្រិតមធ្យោបាយរបស់ខ្លួន ត្រូវចាត់វិធានការសមស្របនានា ដើម្បីជួយឧបត្ថម្ភដល់ឪពុកម្ដាយ និងអ្នកផ្សេងទៀត ដែលទទួលបន្ទុកលើកុមារ ដើម្បីអនុវត្តសិទ្ធិនេះ ហើយក្នុងករណីចាំបាច់ ត្រូវឧបត្ថម្ភសម្ភារៈ និងផ្ដល់កម្មវិធីគាំទ្រនានា ជាពិសេស ទាក់ទងនឹងចំណីអាហារ សំលៀកបំពាក់ និងកន្លែងស្នាក់នៅ។

៤. [...]

នៅក្នុងរបាយការណ៍ស្ដីពី*ស្ថានភាពកុមារក្នុងពិភពលោក ឆ្នាំ ២០០៥* មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) បានបង្ហាញឲ្យដឹងថាមានកុមារច្រើនជាងម្នាក់ក្នុងចំណោមកុមារបីនាក់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (មានកុមារច្រើនជាង ៦៤០ លាននាក់) មិនបានរស់នៅក្នុងលំនៅដ្ឋានសមរម្យឡើយ។ ដោយមានការរីករាលដាល និងផលប៉ះពាល់នៃភាពគ្មានផ្ទះសម្បែង និងលំនៅដ្ឋានមិនសមរម្យសម្រាប់កុមារនោះ ទើបគណៈកម្មាធិការអង្គការសហប្រជាជាតិខាងសិទ្ធិកុមារ បានគូសបញ្ជាក់អំពីចរិតលក្ខណៈសកលនៃសិទ្ធិមានលំនៅដ្ឋានសមរម្យ ដោយសង្កត់ធ្ងន់ថា សិទ្ធិនេះ អនុវត្តចំពោះកុមារគ្រប់រូបដោយមិនមានការបែងចែក ឬ ការរឹតត្បិតក្នុងទម្រង់ណាមួយឡើយ។

ទន្ទឹមនឹងមានកុមាររាប់លាននាក់រស់នៅតាមចិញ្ចើមថ្នល់ ដែលជារឿយៗវាជាសញ្ញាមួយបង្ហាញឲ្យឃើញយ៉ាងច្បាស់ ពីកង្វះខាតទីជម្រក សម្រាប់កុមារ

នោះ ស្ថានភាពដទៃទៀត ក៏ជាមូលហេតុផងដែរ សម្រាប់កុមារក្នុងការប្រើប្រាស់សិទ្ធិមានលំនៅដ្ឋានសមរម្យ។ ស្ថានភាពលំនៅដ្ឋាន ដែលតូចចង្អៀត មានមនុស្សពពាក់ពពូន មានសំឡេងខ្សៀវខ្សារ ឬមានសភាពទ្រុឌទ្រោម ធ្វើឲ្យអន្តរាយយ៉ាងធ្ងន់ធ្ងរដល់ការរីកលូតលាស់ និងសុខភាពរបស់កុមារ ព្រមទាំងសមត្ថភាពរបស់ពួកគេក្នុងការសិក្សា ឬការកំសាន្ត។ ការសិក្សាបានបង្ហាញថា កង្វះលំនៅដ្ឋានសមរម្យ ធ្វើឲ្យអត្រាស្លាប់របស់កុមារអាយុក្រោម ៥ ឆ្នាំ មានការកើនឡើង ទន្ទឹមនេះដែរ ទម្រង់ធ្ងន់ធ្ងរបំផុតនៃការប្រើប្រាស់សារធាតុគីមីពុល បង្កផលប៉ះពាល់ដល់សុខភាពរបស់កុមារ ក្នុងបណ្តាប្រទេសដែលមានចំណូលទាប និងមធ្យម ហើយការបំពុលនៅក្នុងផ្ទះ ជាពិសេស បណ្តាលមកពីចង្ក្រានមានគុណភាពអន់ និងខ្យល់ចេញចូលមិនគ្រប់គ្រាន់។[១២]

ការទទួលបានសេវាមូលដ្ឋានសម្រាប់លំនៅដ្ឋានមួយ ដូចជាទឹកពិសារមានសុវត្ថិភាព និងអនាម័យល្អត្រឹមត្រូវ គឺជាមូលដ្ឋានគ្រឹះក្នុងការធានាដល់សុខភាពរបស់កុមារ។ ជំងឺរាគរូស បានឆក់យកជីវិតកុមារជាងពីរលាននាក់ជារៀងរាល់ឆ្នាំ ដែលពី៨០ ទៅ ៩០ ភាគរយនៃករណីទាំងនេះ គឺបណ្តាលមកពីទឹកកខ្វក់ និងប្រព័ន្ធអនាម័យមិនគ្រប់គ្រាន់។ ជាពិសេស សម្រាប់កុមារី កង្វះទឹកពិសារមានសុវត្ថិភាពនៅក្នុង ឬនៅក្បែរផ្ទះ អាចនឹងនាំឲ្យមានការធ្វើដំណើរវែងឆ្ងាយ ដើម្បីទៅរកទឹកនៅទីតាំងដែលមានទឹកនៅតំបន់ឆ្ងាយៗ ដែលជាញឹកញាប់ ផ្តល់ផលប៉ះពាល់ដល់ការសិក្សារបស់ពួកគេ រួមជាមួយនឹងហានិភ័យនៃការយាយី និងការគំរាមកំហែងផ្សេងៗទៀតនៅតាមផ្លូវផងដែរ។

ទីតាំងលំនៅដ្ឋាន ក៏មានសារៈសំខាន់ផងដែរ ក្នុងការធានាថា កុមារអាចទទួលបានសេវាថែទាំកុមារ ការអប់រំនៅសាលារៀន សេវាថែទាំសុខភាព និងសេវាផ្សេងៗទៀត។ ប្រសិនបើការតាំងទីលំនៅ នៅឆ្ងាយពីសាលារៀន ឬ

[១២] UNICEF, *ភាពក្រីក្រ និងការដាត់ចេញក្នុងចំណោមកុមារក្នុងទីក្រុង,* Innocenti Digest លេខ ១០ (Florence, ២០០២), ទំព័រ ១០.

ប្រសិនជាមិនមានសេវាដឹកជញ្ជូន ឬ មានតម្លៃថ្លៃពេកនោះ វាមានការលំបាកសម្រាប់កុមារ ក្នុងការទទួលបានការអប់រំ ឬ ការថែទាំសុខភាព។

ភាពគ្មានផ្ទះសម្បែង មានផលប៉ះពាល់ជាពិសេសទៅលើកុមារ ធ្វើឲ្យប៉ះពាល់ដល់ការលូតលាស់ ការអភិវឌ្ឍន៍ និងសន្តិសុខរបស់ពួកគេ។ កុមារគ្មានផ្ទះសម្បែង អាចប៉ះពាល់ដល់សតិអារម្មណ៍ជាច្រើន រួមមាន ការថប់អារម្មណ៍ ការដេកមិនលក់ ភាពឆេវឆាវ និងភាពឯកោ។ ការទទួលបានសេវាមូលដ្ឋានផ្សេងៗសម្រាប់ខ្លួនគេ ដូចជា ការអប់រំ និងការថែទាំសុខភាព ក៏អាចនឹងរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរ ប្រសិនបើពួកគេ មិនមានទីស្នាក់នៅជាអចិន្ត្រៃយ៍ទេនោះ។ កុមារដែលរស់នៅ និងធ្វើការងារនៅតាមចិញ្ចើមថ្នល់ ពិតជាងាយរងគ្រោះខ្លាំងទៅនឹងការគំរាមកំហែង ការយាយី និងអំពើហិង្សាពីបុគ្គល និងនគរបាល។

ការបណ្តេញចេញដោយបំពាន អាចនឹងបង្កផលប៉ះពាល់ ទៅលើក្រុមគ្រួសារទាំងមូល ប៉ុន្តែវាមានការប៉ះទង្គិចជាពិសេសទៅលើកុមារ។ បន្ទាប់ពីការបណ្តេញចេញដោយបំពាន ស្ថិរភាពរបស់គ្រួសារ ជាញឹកញាប់ ត្រូវទទួលរងហានិភ័យ និងប៉ះពាល់ដល់ជីវភាពរស់នៅ។ ផលប៉ះពាល់នៃការបណ្តេញចេញដោយបំពានទៅលើការលូតលាស់របស់កុមារ ត្រូវបានចាត់ទុកថាមានលក្ខណៈស្រដៀងគ្នាទៅនឹងផលប៉ះពាល់ដោយជម្លោះប្រដាប់អាវុធផងដែរ។[១៣]

## គ. អ្នករស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជន

នៅត្រឹមដំណាច់ឆ្នាំ ២០០៨ ចំនួនពាក់កណ្តាលនៃប្រជាជនសរុបនៅទូទាំងពិភពលោក ត្រូវបានគេគិតថា កំពុងរស់នៅតាមទីក្រុង ដោយក្នុងនោះពួកគេភាគច្រើនរស់នៅដោយគ្មានហេដ្ឋារចនាសម្ព័ន្ធ និង សេវាគ្រប់គ្រាន់នោះទេ។

[១៣] T. Rahmatullah, *ផលប៉ះពាល់នៃការបណ្តេញចេញទៅលើកុមារ ៖ ករណីសិក្សាទទួលបានពីទីក្រុងភ្នំពេញ, ទីក្រុងម៉ានីឡា, ទីក្រុងមុំបៃ* (ទីក្រុងញូវយ៉ក, គណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសំរាប់ទ្វីបអាស៊ី និងប៉ាស៊ីហ្វិក និងសម្ព័ន្ធអាស៊ី ដើម្បីសិទ្ធិលំនៅដ្ឋាន ឆ្នាំ១៩៩៧)

UN-Habitat កត់សំគាល់ឃើញថា ប្រជាជនរស់នៅតាមតំបន់ទីក្រុងដែលគ្មានសុវត្ថិភាពបំផុត គឺជាប្រជាជនក្រីក្រចំនួន ១,០០០ លាន នាក់ លើពិភពលោក ដែលរស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជន។ អ្នករស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជនជាង ៩៣០ លាននាក់ រស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលពួកគេមានចំនួន ៤២% នៃប្រជាជនដែលរស់នៅតាមទីក្រុង។ ចំនួននេះមានកម្រិតខ្ពស់ខ្លាំង នៅអនុតំបន់សាហារ៉ា ក្នុងទ្វីបអាហ្វ្រិក ដែលអ្នករស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជនមានចំនួន ៧២% នៃចំនួនប្រជាជនក្នុងទីក្រុង និង នៅតំបន់អាស៊ីអាគ្នេយ៍ ដែលអ្នករស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជនមានចំនួន ៥៩%។

តំបន់ក្រីក្រតាមទីប្រជុំជន រងការបំផ្លាញដោយសារកង្វះលំនៅដ្ឋានដែលរឹងមាំ ទីធ្លារស់នៅមិនគ្រប់គ្រាន់ កង្វះទឹកស្អាត កង្វះអនាម័យជាដើម។ ដោយសារតែចរិតលក្ខណៈមិនរៀបរយនៃការតាំងទីលំនៅរបស់ខ្លួន អ្នករស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជន ជាញឹកញាប់តែងតែខ្វះការធានាសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីរបស់ខ្លួន ដែលធ្វើឲ្យពួកគេងាយប្រឈមនឹងការបណ្តេញចេញដោយបំពាន ការគំរាមកំហែង និងទម្រង់នៃការយាយីផ្សេងៗ។ UN-Habitat រាយការណ៍ថា មានប្រជាជនប្រហែលជា ២ លាន នាក់ ដែលភាគច្រើនជាអ្នករស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជន ត្រូវបានបណ្តេញចេញដោយបំពានជារៀងរាល់ឆ្នាំ។ ផលប៉ះពាល់នៃការបណ្តេញចេញដោយបំពានទៅលើអ្នករស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជន ជាញឹកញាប់ គឺមានសភាពមហន្តរាយ ដែលធ្វើឲ្យពួកគេគ្មានផ្ទះសម្បែង និងបង្ខំឲ្យពួកគេធ្លាក់ចូលទៅក្នុងភាពក្រីក្រកាន់តែជ្រៅទៅៗ។

ក្រុមអាជ្ញាធរទាំងថ្នាក់ជាតិ ទាំងថ្នាក់មូលដ្ឋាន តែងតែរារែកក្នុងការផ្តល់សេវាកម្មមូលដ្ឋានឲ្យអ្នករស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជន ពីព្រោះគេចាត់ទុកថា សំណង់ទាំងនោះជាសំណង់មិនរៀបរយ។ អាស្រ័យហេតុនេះ អ្នករស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជន ជាទូទៅ កម្រនឹងទទួលបានទឹកពិសារមានសុវត្ថិភាព អនាម័យល្អ ឬ អគ្គិសនីគ្រប់គ្រាន់ណាស់ ហើយការប្រមូលសំរាមទៀតសោត ក៏នៅមានកម្រិត ឬ គ្មានសោះតែម្តង។ ដោយសារតែតំបន់ក្រីក្រ

តាមទីប្រជុំជន មិនមានតភ្ជាប់ប្រព័ន្ធទឹកស្អាត ទើបអ្នករស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជនទាំងនោះ ត្រូវបង្ខំចិត្តចំណាយប្រាក់ថ្លៃទឹក៥ ទៅ ១០ ដង ច្រើនជាងអ្នករស់នៅទីក្រុង ដែលមានចំណូលខ្ពស់ជាងខ្លួនទៀតនោះ។ [១៤]

ការអភិវឌ្ឍន៍នៅនឹងកន្លែង សម្រាប់តំបន់ក្រីក្រតាមទីប្រជុំជន ត្រូវបានទទួលស្គាល់ថា ជាមធ្យោបាយមួយមានប្រសិទ្ធភាព ក្នុងការធ្វើឲ្យប្រសើរឡើងដល់លក្ខខណ្ឌលំនៅដ្ឋាន របស់អ្នករស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជនទាំងនោះ។ មធ្យោបាយនេះ ត្រូវបានកំណត់ដោយសម្ព័ន្ធភាពទីក្រុង ដែលជាសម្ព័ន្ធភាពទីក្រុងសកលមួយ បង្កើតឡើងដោយធនាគារពិភពលោក និង UN-Habitat នៅក្នុងឆ្នាំ១៩៩៩ ដោយក្នុងនោះមានរួមបញ្ចូលនូវការធ្វើឲ្យប្រសើរឡើងខាងផ្នែករូបវន្ត សង្គមកិច្ច សេដ្ឋកិច្ច ការរៀបចំរចនាសម្ព័ន្ធ និងបរិស្ថាន ដែលត្រូវបានអនុវត្តរួមគ្នា និងនៅតាមមូលដ្ឋាន ក្នុងចំណោមប្រជាពលរដ្ឋ ក្រុមសហគមន៍ ក្រុមអាជីវកម្ម និងអាជ្ញាធរមូលដ្ឋាន។”[១៥] កម្មវិធីអភិវឌ្ឍន៍នៅនឹងកន្លែងសម្រាប់តំបន់ក្រីក្រតាមទីប្រជុំជន អាចរួមចំណែកដល់ការទទួលបានសិទ្ធិមានលំនៅដ្ឋានសមរម្យ សម្រាប់អ្នករស់នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជន ប្រសិនបើកម្មវិធីទាំងនោះ ធានាសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីសម្រាប់ប្រជាជនទាំងអស់ រួមទាំងអ្នកជួលផង ការយកចិត្តទុកដាក់ទៅលើសិទ្ធិស្ត្រី និងធានាការមិនរើសអើងនៅក្នុងគម្រោងផែនការកាន់កាប់ដីធ្លី និង ធានាឲ្យមានការចូលរួមពេញលេញ និង ប្រកបដោយអត្ថន័យពីសហគមន៍ដែលរងផលប៉ះពាល់។

---

[១៤] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ *របាយការណ៍ស្តីពីការអភិវឌ្ឍន៍មនុស្សជាតិ ឆ្នាំ២០០៦ មានចំណងជើងថា ហួសពីការខ្វះខាត ៖ អំណាច, ភាពក្រីក្រ និងវិបត្តិទឹកសកល* (ទីក្រុងញូយ៉ក) ពីទំព័រ ៥២ ដល់ ទំព័រ ៥៣។

[១៥] ធនាគារពិភពលោក និង UNCHS (Habitat), *សម្ព័ន្ធទីក្រុងសំរាប់ទីក្រុងគ្មានសំណង់អនាធិបតេយ្យ ៖ ផែនការសកម្មភាព ដើម្បីរំកិលការលើកកម្ពស់សំណង់អនាធិបតេយ្យឲ្យដល់គោលដៅ*, ឯកសារសង្ខេបពិសេស (ឆ្នាំ ១៩៩៩) ទំព័រ ២ ( អាចរកបានពី ៖ www.citi*es*alliance.org)។

## ឃ. ជនគ្មានផ្ទះសម្បែង

អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ បានហៅភាពគ្មានផ្ទះសម្បែងថា "ជារោគសញ្ញាដែលអាចមើលឃើញច្បាស់ និងធ្ងន់ធ្ងរបំផុតនៃការមិនគោរពសិទ្ធិមានលំនៅដ្ឋានសមរម្យ។"

មិនមាននិយមន័យ ដែលបានឯកភាពគ្នាជាអន្តរជាតិទេ ចំពោះពាក្យថាភាពគ្មានផ្ទះសម្បែង។ និយមន័យជាច្រើនរាប់ចាប់ពី និយមន័យក្នុងន័យចង្អៀត ដែលធ្វើការប្រៀបធៀបពាក្យ ភាពគ្មានផ្ទះសម្បែង ស្មើនឹងពាក្យ ការគ្មានដំបូលជ្រក រហូតដល់និយមន័យក្នុងន័យទូលាយ ដែលផ្អែកលើភាពសមស្របនៃការតាំងទីលំនៅ ហានិភ័យនៃការក្លាយទៅជាគ្មានផ្ទះសម្បែង ពេលវេលាដែលប្រឈមនឹងភាពគ្មានផ្ទះសម្បែង និងការទទួលខុសត្រូវដើម្បីបំបាត់ស្ថានភាពគ្មានផ្ទះសម្បែង។ សម្រាប់គោលបំណងស្ថិតិ អង្គការសហប្រជាជាតិបានកំណត់និយមន័យ ចំពោះគ្រួសារដែលគ្មានផ្ទះសម្បែងថាជា "គ្រួសារដែលមិនមានជម្រកស្នាក់អាស្រ័យ ដែលធ្លាក់ចូលក្នុងរង្វង់នៃការដែលមិនអាចឲ្យរស់នៅបាន។ ពួកគេមានរបស់របរមួយចំនួនជាប់នឹងខ្លួន ដេកនៅតាមចិញ្ចើមថ្នល់ នៅតាមច្រកទ្វារចូល ឬ នៅលើកំពង់ផែ ឬ នៅទីកន្លែងផ្សេងទៀតដែលទំនេរដោយគ្មានការតាំងនៅជាប់លាប់។[១៦] អ្នករាយការណ៍ពិសេសស្តីពីលំនៅដ្ឋានសមរម្យ បានសម្គាល់ឃើញថា និយមន័យក្នុងន័យចង្អៀត គឺមិនគ្រប់ជ្រុងជ្រោយទេ ហើយថា នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍វិញ និយមន័យទូទៅបំផុតទទួលស្គាល់ថា សមាសធាតុនៃការផាត់ចេញពីសង្គម គឺជាផ្នែកមួយនៃបទពិសោធន៍ដែលនាំឲ្យគ្មានផ្ទះសម្បែង។ UN-Habitat គូសបញ្ជាក់ត្រង់ចំណុចនេះថា ភាពគ្មានផ្ទះសម្បែងសំដៅដល់ការគ្មានទីណាមួយជារបស់ខ្លួន ជាជាងការគ្រាន់តែគ្មានទីកន្លែងសំរាប់ដេកនោះ។ ដោយសារមិនមាននិយមន័យណាមួយ

---

[១៦] *គោលការណ៍ និងអនុសាសន៍សម្រាប់ធ្វើជំរឿនប្រជាជន និងលំនៅដ្ឋាន* (បោះពុម្ពផ្សាយដោយអង្គការសហប្រជាជាតិ ចេញលក់លេខ ០៧.XVII.៨ P), កថាខ័ណ្ឌ ១.៣២៨.

ត្រូវបានឯកភាពគ្នាជាសកល អំពីភាពគ្មានផ្ទះសម្បែងនេះហើយ ទើបទិន្នន័យដែលមាន នៅមានកម្រិតអំពីទំហំនៃបាតុភាព រារាំងដល់ការបង្កើតយុទ្ធសាស្រ្ត និងគោលនយោបាយស្របគ្នា ដើម្បីទប់ស្កាត់ និងដោះស្រាយបញ្ហានេះ។

អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ បានគូសបញ្ជាក់ថា ភាពក្រីក្រ គឺជាសមាសភាពរួមមួយ នៅក្នុងបទពិសោធន៍របស់អ្នកគ្មានផ្ទះសម្បែង។ បុព្វហេតុ ឬ កត្តាដទៃទៀត ដែលធ្វើឲ្យប្រជាជនងាយនឹងទទួលរងថែមទៀតនូវភាពគ្មានផ្ទះសម្បែងនោះ គឺ ភាពគ្មានការងារធ្វើ កង្វះប្រព័ន្ធសេវាសន្តិសុខសង្គម កង្វះលំនៅដ្ឋានដែលមានតម្លៃសមរម្យអាចរកទិញបាន ការបណ្តេញចេញដោយបំពាន ភាពគ្មានលំនៅដ្ឋានបែបសង្គមកិច្ច ជម្លោះ និងគ្រោះធម្មជាតិ ព្រមទាំងកង្វះការយកចិត្តទុកដាក់ អំពីសេចក្តីត្រូវការរបស់ប្រជាជនដែលងាយរងគ្រោះបំផុតផងដែរ។

ការ "បំបាត់ចេញពីស្ថាប័ន" នូវសេវាថែទាំសុខភាពផ្លូវចិត្ត ដែលបានផ្តើមធ្វើដំបូងគេនៅក្នុងប្រទេសជាច្រើន ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ និង ឆ្នាំ១៩៧០ បាននាំឲ្យជនពិការក្លាយជាជនគ្មានផ្ទះសម្បែង មានចំនួនច្រើនឡើង លុះត្រាតែមានការដើរទន្ទឹមគ្នានូវការរីកដុះដាលនៃសេវាគាំទ្រក្នុងសហគមន៍ និងផ្នែកគាំទ្រដទៃទៀត ។

ក្រៅពីការរំលោភសិទ្ធិមានលំនៅដ្ឋានសមរម្យរបស់ពួកគេ ជនគ្មានផ្ទះសម្បែង អាចនឹងត្រូវបានដកហូតសិទ្ធិដទៃទៀតជាច្រើនផងដែរ។ ច្បាប់ដែលកំណត់ថាជាទោសព្រហ្មទណ្ឌចំពោះភាពគ្មានផ្ទះសម្បែង ភាពអនាថា ឬ ការដេកក្រៅផ្ទះ ស្របពេលដែលមានប្រតិបត្តិការសំអាតផ្លូវថ្នល់ ដើម្បីប្រមូលជនគ្មានលំនៅដ្ឋានចេញពីចិញ្ចើមផ្លូវ បានធ្វើឲ្យប៉ះពាល់ដោយផ្ទាល់ដល់បូរណភាពផ្លូវកាយ និង ផ្លូវចិត្តរបស់ពួកគេ។ ដោយសារតែការគ្មានកន្លែងមួយគត់មត់សម្រាប់ស្នាក់នៅ ឬ សិទ្ធិឯកជន ជនគ្មានផ្ទះសម្បែង ត្រូវប្រឈមខ្លាំងថែមទៀតនឹងអំពើហិង្សា ការគម្រាមកំហែង និង ការយាយីរំខានផ្សេងៗ។

កាតព្វកិច្ចរបស់រដ្ឋភាគី ចំពោះការធ្វើឲ្យសម្រេចបានពេញលេញនូវសិទ្ធិមានលំនៅដ្ឋានសមរម្យ គឺរាប់បញ្ចូលទាំងការចាត់វិធានការផ្សេងៗ ដើម្បីបង្ការភាពគ្មានផ្ទះសម្បែង។ ក្នុងចំណោមវិធានការទាំងឡាយដែលត្រូវចាត់ជាបន្ទាន់នោះ មានសេចក្តីពន្យល់រួមលេខ ៤ (ចាប់ពីកថាខ័ណ្ឌ១០ ដល់ ១៣) បានបញ្ជាក់ថា ការកំណត់វិសាលភាពនៃភាពគ្មានផ្ទះសម្បែង ក៏ដូចជា ការអនុម័តទទួលយកយុទ្ធសាស្ត្រជាតិស្តីពីលំនៅដ្ឋាន ដែលគួរផ្តោតការគិតគូដល់ការពិគ្រោះយោបល់ពិតប្រាកដ និង ទូលំទូលាយជាមួយប្រជាជនដែលគ្មានផ្ទះសម្បែង។ សេចក្តីពន្យល់រួមលេខ៧ (កថាខ័ណ្ឌ១៧) ក៏បានសង្កត់ធ្ងន់ផងដែរថា ការបណ្តេញចេញដោយបំពាន មិនគួរបណ្តាលឲ្យបុគ្គលណាមួយក្លាយជាជនគ្មានផ្ទះសម្បែងឡើយ។

## ង. ជនពិការ

មានមនុស្សជាង ៦៥០ លាននាក់ ជាជនពិការនៅទូទាំងពិភពលោក ដែលក្នុងនោះមានប្រហែលជា ៨០% រស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ជាទូទៅ ពួកគេទាំងនោះប្រឈមនឹងឧបសគ្គជាច្រើនក្នុងការទទួលបានសិទ្ធិមានលំនៅដ្ឋានសមរម្យ រួមមានកង្វះការទទួលបានផ្នែករូបវ័ន្ត ការរើសអើងឥតឈប់ឈរ និងស្ថានភាពអសោចកេរ្តិ៍ (ស្ទិកម៉ា) របាំងសង្គម កង្វះលទ្ធភាពឈានចូលទីផ្សារការងារ ប្រាក់ចំណូលទាប និងកង្វះសេវាលំនៅដ្ឋានសង្គមកិច្ច ឬការគាំទ្រពីសហគមន៍។

លទ្ធភាពអាចទទួលបាន នៅតែជាបញ្ហាមួយដ៏សំខាន់ដដែល។ លំនៅដ្ឋានសេវាលំនៅដ្ឋាន និងតំបន់ជិតខាង ត្រូវបានរៀបចំឡើងតាមទម្លាប់ សម្រាប់តែមនុស្សដែលមិនពិការ។ ការផាត់ចេញ និងការមិនគិតគូរអើពើដល់ជនពិការ ជាទូទៅមានន័យថា ជនពិការទាំងនោះ កម្រត្រូវបានគេពិគ្រោះយោបល់ជាមួយណាស់ នៅពេលធ្វើការអភិវឌ្ឍន៍សំណង់លំនៅដ្ឋានថ្មី ឬតំបន់ជិតខាង ឬការអភិវឌ្ឍន៍នៅនឹងកន្លែងសម្រាប់តំបន់ក្រីក្រតាមទីប្រជុំជន។ ជនពិការ ក៏ងាយរងគ្រោះផងដែរ ដោយការរំលោភបំពានផ្សេងៗលើសិទ្ធិរបស់ខ្លួន។ ឧទាហរណ៍ កង្វះ

គ្រឿងបរិក្ខារ និង សេវាកម្មផ្សេងៗដែលចាំបាច់ សម្រាប់រក្សាអនាម័យឲ្យបានសមស្រប នៅកន្លែងតាំងទីលំនៅមិនទាន់រៀបរយ អាចបង្កជាបញ្ហាធ្ងន់ធ្ងរដល់ពួកគេ។

សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី គឺជាបញ្ហាប្រឈមមួយផ្សេងទៀត សំរាប់ជនពិការ ជាពិសេស ជនពិការខាងបញ្ញាស្មារតី ឬខាងផ្លូវចិត្ត។ ជាញឹកញាប់ ការខ្វះខាតនូវការទទួលស្គាល់សមត្ថភាពតាមផ្លូវច្បាប់របស់ពួកគាត់ ដែលជារឿយៗគួបផ្សំនឹងការតម្រូវឲ្យគាត់ដាក់ពាក្យស្នើសុំដោយផ្ទាល់នោះ មានន័យថា ជនពិការបែបនេះ កម្រនឹងមានលទ្ធភាពចុះកិច្ចសន្យាលំនៅដ្ឋានផ្លូវការប្រភេទណាមួយណាស់ (កិច្ចសន្យាជួល សិទ្ធិកាន់កាប់ ជាដើម) ដោយសារតែបញ្ហានេះហើយ ទើបពួកគាត់ពឹងផ្អែកលើមធ្យោបាយមិនសូវផ្លូវការ ដើម្បីកាន់កាប់លំនៅដ្ឋាន។ ជាលទ្ធផល ការរៀបចំបែបនេះ ធ្វើឲ្យពួកគាត់ត្រូវប្រឈមខ្លាំងឡើងថែមទៀត ទៅនឹងការបណ្តេញចេញដោយបំពាន។

ជាទូទៅ នៅពេលដែលស្ថានភាពអសោចន៍កេរ្តិ៍ (ស្ទិកម៉ា) នៅមិនទាន់ត្រូវបានដោះស្រាយ និងមិនមានសេវាសង្គមកិច្ច ឬសហគមន៍ រួមទាំងលំនៅដ្ឋានសង្គមកិច្ចផងដែរនោះ ជនពិការ នៅតែបន្តប្រឈមនឹងការរើសអើងដដែល នៅពេលដែលពួកគាត់ស្វែងរកលំនៅដ្ឋាន ឬបញ្ហាប្រឈមទូទៅជាច្រើនទៀត ក្នុងការធានារក្សាធនធានចាំបាច់ ដើម្បីទទួលបានលំនៅដ្ឋានសមរម្យ។ បញ្ហាប្រឈមមិនអាចជៀសផុតបែបនេះ ធ្វើឲ្យពួកគាត់កាន់តែងាយរងគ្រោះពីការបណ្តេញចេញដោយបំពាន ការគ្មានផ្ទះសម្បែង និងស្ថានភាពលំនៅដ្ឋានមិនសមរម្យ។

**សន្ធិសញ្ញាស្តីពីសិទ្ធិជនពិការ** តម្រូវឲ្យរដ្ឋទាំងឡាយ លើកស្ទួយ ការពារ និងធានាឲ្យជនពិការទទួលបានដោយពេញលេញ និងស្មើភាពគ្នានូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ រួមទាំងសិទ្ធិមានលំនៅដ្ឋានសមរម្យផងដែរ។

**មាត្រា ១** តម្រូវឲ្យរដ្ឋទាំងឡាយ លើកកំពស់ការគោរពសេចក្តីថ្លៃថ្នូររបស់ពួកគេ ដែលមានពីកំណើត។

**មាត្រា ៩** តម្រូវបន្ថែមទៀតថា រដ្ឋទាំងឡាយ ត្រូវអនុម័តវិធានការផ្សេងៗ ដើម្បីកំណត់ និងបំបាត់ឧបសគ្គ និងការរារាំងទាំងឡាយដល់ការទទួលបានសិទ្ធិទាំងនេះ ជាពិសេស ពាក់ព័ន្ធនឹងសិទ្ធិមានលំនៅដ្ឋានសមរម្យ។

**មាត្រា១២** ទទួលស្គាល់ថា ជនពិការ មានសមត្ថភាពតាមផ្លូវច្បាប់ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត និងតម្រូវឲ្យរដ្ឋចាត់វិធានការសមស្របនានា ដើម្បីផ្តល់លទ្ធភាពឲ្យជនពិការទទួលបានការជួយឧបត្ថម្ភ ដែលពួកគេអាចត្រូវការ ក្នុងការអនុវត្តន៍សមត្ថភាពតាមផ្លូវច្បាប់របស់ពួកគេ។

**មាត្រា ២៨** ទទួលស្គាល់សិទ្ធិរបស់ជនពិការ ចំពោះជីវភាពរស់នៅសមរម្យសំរាប់ខ្លួនគេផ្ទាល់ និងសំរាប់ក្រុមគ្រួសាររបស់ពួកគេ រួមទាំងសិទ្ធិមានលំនៅដ្ឋានសមរម្យ និងតម្រូវឲ្យរដ្ឋទាំងឡាយ ចាត់វិធានការសមស្រប ដើម្បីការពារ និងលើកស្ទួយដល់ការធ្វើឲ្យបានសំរេចនូវសិទ្ធិនេះ ដោយគ្មានការរើសអើង ដោយសារពិការភាពនោះឡើយ ជាអាទ៍ ដោយការធានាថា ជនពិការអាចចូលរួមបានក្នុងកម្មវិធីលំនៅដ្ឋានសាធារណៈ ។

សេចក្តីពន្យល់រួមលេខ៤ បញ្ជាក់ថា ជនពិការត្រូវតែទទួលបានលទ្ធភាពពេញលេញ និងប្រកបដោយនិរន្តរភាព ក្នុងការប្រើប្រាស់ធនធានលំនៅដ្ឋានសមរម្យ និងចែងទៀតថា ច្បាប់ និងគោលនយោបាយស្តីពីលំនៅដ្ឋាន ត្រូវតែគិតគូអំពីសេចក្តីត្រូវការពិសេសរបស់ជនពិការ។ នៅក្នុងសេចក្តីពន្យល់រួមលេខ ៥ (ឆ្នាំ១៩៩៤) គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានអះអាង

ជាថ្មីថា សិទ្ធិមានលំនៅដ្ឋានសមរម្យ រួមបញ្ចូលទាំងលទ្ធភាពទទួលបានសម្រាប់ជនពិការផងដែរ។ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធមានលំនៅដ្ឋានសមរម្យ ក៏បានគូសបញ្ជាក់ផងដែរថា មិនត្រឹមតែលំនៅដ្ឋានទេ ដែលជនពិការគួរតែទទួលបានទាំងផ្នែករូបវន្ត និងសេដ្ឋកិច្ចនោះ ប៉ុន្តែពួកគេ គួរតែមានលទ្ធភាពអាចចូលរួមបានប្រកបដោយប្រសិទ្ធភាព ក្នុងជីវភាពសហគមន៍ ដែលពួកគេរស់នៅ។

## ច. ជនចំណាកស្រុក និង ទេសន្តរប្រវេសន៍

ប្រជាជនផ្លាស់ទីលំនៅ មិនថាជាជនភៀសខ្លួន អ្នកសុំសិទ្ធិជ្រកកោន ជនចំណាកស្រុក ឬ ទេសន្តរន្រវេសន៍ គឺសុទ្ធតែត្រូវប្រឈមជាខ្លាំងទៅនឹងការរំលោភបំពានលើសិទ្ធិមនុស្សច្រើនបែបយ៉ាង រួមមានការរំលោភលើសិទ្ធិមានលំនៅដ្ឋានសមរម្យផងដែរ។ ជនចំណាកស្រុក ក៏ប្រឈមខ្លាំងទៅនឹងការរើសអើង ការប្រកាន់ពូជសាសន៍ និងការស្អប់ខ្ពើមជនបរទេស ដែលអាចរំខានដល់សមត្ថភាពរបស់គេ ក្នុងការធានាលក្ខខណ្ឌរស់នៅសមរម្យ និងប្រកបដោយនិរន្តរភាព។ ជនដែលត្រូវបានគេឲ្យចាកចេញដោយបង្ខំ ជារឿយៗ ត្រូវទទួលរងការឈឺចាប់យ៉ាងខ្លាំង ក្នុងអំឡុងពេលនៃការធ្វើដំណើររបស់ខ្លួន ហើយនឹងត្រូវបាត់បង់យុទ្ធសាស្ត្រដោះស្រាយ និងយន្តការគាំទ្រ ដែលធ្លាប់មាន។

ជំរុំជនភៀសខ្លួន និងជនចំណាកស្រុក(IDP) នៅទូទាំងពិភពលោក តែងតែជួបប្រទះជារឿយៗ ជាពិសេស នៅពេលដែលការតាំងនៅមានរយៈពេលវែង ធ្វើឲ្យជំរុំទាំងនោះមានសភាពចាស់ទ្រុឌទ្រោម និងមានមនុស្សច្រើនហួសកម្រិត ដែលមិនអាចផ្តល់ទីជម្រក និងសេវាបានគ្រប់គ្រាន់។ ពេលខ្លះ អ្នករស់នៅក្នុងជំរុំទាំងនោះ មិនទទួលបានសេវាកម្មចាំបាច់ទាល់តែសោះ។ ជនចំណាកស្រុកជាស្ត្រី និង ក្មេងស្រីដែលរស់នៅក្នុងជំរុំ អាចនឹងទទួលរងអំពើហិង្សាផ្លូវភេទនិងខាងយេនឌ័រ ជាអាទិ៍ ដោយសារតែគ្មានការយកចិត្តទុកដាក់គ្រប់គ្រាន់លើសេចក្តីត្រូវការជាក់លាក់ និងភាពងាយរងគ្រោះរបស់ពួកគេ ក្នុងការរៀបចំរចនាប្លង់ និងទ្រង់ទ្រាយនៃជំរុំ។

នៅតំបន់ទីប្រជុំជនវិញ ជនចំណាកស្រុកនៅតាមទីប្រជុំជន អ្នកសុំសិទ្ធិជ្រកកោន និងចំណាកស្រុកក្នុងប្រទេស អាចនឹងមានភាពជឿនលឿនជាងបន្តិច។ ប៉ុន្តែទោះជាដូច្នេះក្តី ជារឿយៗ តាមការជាក់ស្តែងមិនអាចធ្វើបានទេ ឬក៏មកពីស្ថានភាពផ្លូវច្បាប់របស់គេ នៅក្នុងការជួលកន្លែងស្នាក់នៅសមរម្យ ទើបពួកគេភាគច្រើនត្រូវបង្ខំចិត្តរស់នៅផ្តុំគ្នា និង ក្នុងលក្ខខណ្ឌអសុវត្ថិភាព។ ទេសន្តរប្រវេសន៍ជាញឹកញាប់ ក៏ត្រូវបង្ខំចិត្តរស់នៅក្នុងស្ថានភាពមិនប្រាកប្រជា និងគ្មានសុវត្ថិភាពនៅទីក្រុង និងតាមតំបន់ទីប្រជុំជនផងដែរ។ និយោជកមួយចំនួន អាចនឹងតម្រូវឲ្យកម្មករចំណាកស្រុកក្នុងប្រទេស ឬកម្មកររោងចក្រ ស្នាក់នៅកន្លែងធ្វើការរបស់ពួកគេ។ ពួកគេភាគច្រើន ត្រូវបង្ខំចិត្តរស់នៅក្នុងអគារស្នាក់នៅរួមដែលមានមនុស្សច្រើនហួសកម្រិត ដោយប្តូរវេនគ្នាដេក និងមិនមានអនាម័យសមស្របឡើយ។ កម្មករក្នុងស្រុក អាចនឹងត្រូវបានគេឲ្យដេកនៅក្នុងបន្ទប់ដែលមានខ្យល់ចេញចូលមិនគ្រប់គ្រាន់ ក្នុងឃ្លាំងដាក់ឥវ៉ាន់ ឬកន្លែងរស់នៅរួមដោយមិនគិតគូដល់សេចក្តីថ្លៃថ្នូរ សិទ្ធិឯកជន ឬ សន្តិសុខផ្ទាល់ខ្លួនឡើយ។

ទេសន្តរប្រវេសន៍មិនអចិន្ត្រៃយ៍ ឬមិនមានឯកសារត្រឹមត្រូវ រាប់ទាំងអ្នកស្វែងរកសិទ្ធិជ្រកកោនដែលត្រូវបានគេបដិសេធផងដែរ មានការប្រឈមជាខ្លាំងទៅនឹងការរំលោភសិទ្ធិមនុស្ស រាប់ទាំងការរំលោភសិទ្ធិមានលំនៅដ្ឋានសមរម្យ។ ជនចំណាកស្រុកមិនអចេន្ត្រៃយ៍ ជាញឹកញាប់ ក្លាយជាជនគ្មានផ្ទះសម្បែងដោយសារតែគ្មានលទ្ធភាពបង់ថ្លៃជួលផ្ទះ ដែលជាទូទៅ នាំឲ្យមានការបណ្តេញចេញភ្លាមៗ។ ការគ្មានឋានៈតាមផ្លូវច្បាប់ និងការកំណត់ជាទោសព្រហ្មទណ្ឌចំពោះការធ្វើចំណាកស្រុកមិនអចិន្ត្រៃយ៍នៅក្នុងប្រទេសជាច្រើន បានធ្វើឲ្យមនុស្សភាគច្រើនបំផុតបាត់បង់លទ្ធភាព ឬ គ្មានឆន្ទៈក្នុងការប្រឈមនឹងទង្វើរើសអើង ឬ ការប្រព្រឹត្តបំពានលើការជួលកន្លែងស្នាក់នៅ និងការស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ណាមួយឡើយ។ យុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់លំនៅដ្ឋាន កម្រនឹងមានបញ្ចូលទេសន្តរប្រវេសន៍ខ្លាំងណាស់ ហើយជាក់ស្តែងមិនបានដាក់បញ្ចូលទេសន្តរប្រវេសន៍មិនអចិន្ត្រៃយ៍ទេ។

ក្នុងបរិបទនៃដំណោះស្រាយយូរអង្វែង បទដ្ឋានដ៏សំខាន់មួយនៃសំណង បដិទានលើលំនៅដ្ឋាន និងទ្រព្យសម្បត្តិ ធានាការពារសិទ្ធិរបស់ជនភៀសខ្លួន និងជនចំណាកស្រុកក្នុងប្រទេស ដែលបានសម្រេចចវិលត្រឡប់ទៅកាន់ទីលំនៅដើមរបស់ខ្លួនវិញដោយស្ម័គ្រចិត្ត។ ក្នុងរយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ ការវិលត្រឡប់ ឬការធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្តបានកើនឡើង ក្នុងន័យទូលំទូលាយជាងការគ្រាន់តែវិលត្រឡប់ទៅកាន់ប្រទេសរបស់ខ្លួនវិញ សម្រាប់ជនភៀសខ្លួន ឬ ទីក្រុង ឬតំបន់ណាមួយរបស់ខ្លួន សម្រាប់ជនចំណាកស្រុកក្នុងប្រទេស។ មានការយល់ដឹងច្រើន នៅក្នុងន័យមួយថា ជាការវិលត្រឡប់មកវិញ និងការបញ្ជាក់ជាថ្មីនូវសិទ្ធិគ្រប់គ្រងលំនៅដ្ឋាន ដីធ្លី ឬ ទ្រព្យសម្បត្តិដើមរបស់ខ្លួន។ ជនភៀសខ្លួន និងជនចំណាកស្រុកក្នុងប្រទេស ដែលបានជ្រើសរើសយកការមិនវិលត្រឡប់ទៅកាន់ទីលំនៅដើមរបស់ខ្លួនវិញ ត្រូវទទួលបានការការពារប្រឆាំងនឹងការបង្ខំឲ្យវិលត្រឡប់ទៅកន្លែងដើមវិញ នៅគ្រប់កាលៈទេសៈទាំងអស់ ហើយគួរត្រូវបានផ្តល់លទ្ធភាពឲ្យតាំងទីលំនៅសារជាថ្មី នៅក្នុងលក្ខខណ្ឌដែលក្នុងនោះ មានការគោរពសិទ្ធិមានលំនៅដ្ឋានសមរម្យរបស់ពួកគេផងដែរ។

ស្ថិតក្រោម **អនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន** រដ្ឋភាគីទាំងអស់ត្រូវផ្តល់ដល់ជនភៀសខ្លួន នូវការយកចិត្តទុកដាក់ដល់ពួកគេដោយក្តីអនុគ្រោះ តាមដែលអាចធ្វើទៅបាន ហើយការយកចិត្តទុកដាក់នេះមិនត្រូវឲ្យទាបជាងការយកចិត្តទុកដាក់ចំពោះជនបរទេសទូទៅដែលស្ថិតក្នុងស្ថានភាពដូចគ្នានេះឡើយ ចំពោះបញ្ហាលំនៅដ្ឋាន (មាត្រា ២១)។

មាត្រា ៤៣ **នៃអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ** ធានាដល់ទេសន្តរប្រវេសន៍ ចំពោះការយកចិត្តទុកដាក់ដោយស្មើភាពក្នុងការ

ទទួលបានលំនៅដ្ឋាន រួមមានគម្រោងលំនៅដ្ឋានបែបសង្គមកិច្ច និងការការពារប្រឆាំងនឹងការកេងប្រវ័ញ្ចពាក់ព័ន្ធនឹងការជួលទៅឲ្យក្រុមកម្មករចំណាកស្រុកអចិន្ត្រៃ និងគ្រួសាររបស់ពួកគេ។

**អនុសញ្ញា ILO លេខ ៩៧ ទាក់ទងនឹងការធ្វើចំណាកស្រុកស្វែងរកការងារធ្វើ (កែសម្រួលឡើងវិញ) (១៩៤៩)** មានចែងអំពីកន្លែងស្នាក់នៅរបស់កម្មករចំណាកស្រុក។

**គោលការណែនាំស្តីពីចំណាកស្រុកក្នុងប្រទេស** ដែលចេញដោយតំណាងអគ្គលេខាធិការស្តីពីជនចំណាកស្រុកក្នុងប្រទេស បានបញ្ជាក់ជាថ្មីថា ជនចំណាកស្រុកក្នុងប្រទេសមានសិទ្ធិមានជីវភាពសមរម្យ ហើយថា យ៉ាងហោចណាស់ ដោយមិនគិតពីកាលៈទេសៈ និងដោយគ្មានការរើសអើង អាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តល់ និងធានាឲ្យជនចំណាកស្រុកក្នុងប្រទេសទទួលបានប្រកបដោយសុវត្ថិភាពនូវទីជម្រក និងលំនៅដ្ឋានចាំបាច់ (គោលការណ៍ ១៨)។

**សេចក្តីពន្យល់រួមលេខ ៣០ (២០០៤) របស់គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍** អំពាវនាវដល់រដ្ឋភាគីទាំងអស់ឲ្យ "ធានាការប្រើប្រាស់ដោយស្មើភាពគ្នានូវសិទ្ធិមានលំនៅដ្ឋានសមរម្យសម្រាប់ប្រជាពលរដ្ឋ និងអ្នកមិនមែនជាប្រជាពលរដ្ឋ ជាពិសេសជៀសវាងការផាត់ចេញ (ការដាក់ឲ្យនៅដោយឡែក) ក្នុងការតាំងលំនៅដ្ឋាន និងធានាថា ក្រុមភ្នាក់ងារផ្ទែកលំនៅដ្ឋានត្រូវបានទប់ស្កាត់មិនឲ្យមានទង្វើរើសអើង។"

ការផ្លាស់ប្តូរនេះ បានឆ្លុះបញ្ចាំងកាន់តែច្រើនឡើងជាលំដាប់ នៅក្នុងច្បាប់អន្តរជាតិ ច្បាប់ក្នុងតំបន់ និងច្បាប់ជាតិ និងលិខិតុបករណ៍ផ្សេងៗទៀត ដែល

ទទួលស្គាល់យ៉ាងច្បាស់ចំពោះបដិទានលើលំនៅដ្ឋាន និងទ្រព្យសម្បត្តិថា ជាសិទ្ធិមនុស្ស។ ក្នុងខែសីហា ឆ្នាំ២០០៥ អនុគណៈកម្មការការពារ និងលើកស្ទួយសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានអនុម័តគោលការណ៍ស្តីពីបដិទានលើលំនៅដ្ឋាន និងទ្រព្យសំរាប់ជនភៀសខ្លួន និងជនផ្លាស់លំនៅដ្ឋាន ដែលគេស្គាល់ម្យ៉ាងទៀតផងដែរថា "គោលការណ៍ភីនអៃរ៉ូ" (The Pinheiro Principles)។ គោលការណ៍ទាំងនេះ ផ្តល់ការណែនាំអំពីគោលនយោបាយជាក់លាក់ក្នុងការធានាសិទ្ធិទទួលបានបដិទានលើលំនៅដ្ឋាន និងទ្រព្យសម្បត្តិក្នុងការអនុវត្តន៍ជាក់ស្តែង និងការអនុវត្តន៍ច្បាប់ កម្មវិធី និងគោលនយោបាយបដិទានដោយផ្អែកលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ច្បាប់មនុស្សធម៌ និងច្បាប់ពាក់ព័ន្ធជនភៀសខ្លួន ដែលមានស្រាប់ និងផ្អែកលើបទដ្ឋានជាតិ។[១៧]

"គោលការណ៍ ភីនអៃរ៉ូ" (The Pinheiro Principles)

**គោលការណ៍ ២ ៖ សិទ្ធិទទួលបានបដិទានលើលំនៅដ្ឋាន និងទ្រព្យសម្បត្តិ**

២.១ ជនភៀសខ្លួន និងជនផ្លាស់លំនៅដ្ឋានគ្រប់រូប មានសិទ្ធិទទួលបានបដិទានលើលំនៅដ្ឋាន ដីធ្លី និង/ឬ ទ្រព្យសម្បត្តិ ដែលត្រូវបានគេដកហូតដោយបំពាន និងដោយខុសច្បាប់ [...]។

[១៧] សំណាងសម្រាប់លំនៅដ្ឋាន និងទ្រព្យសម្បត្តិ ក្នុងបរិបទនៃការវិលត្រឡប់មកវិញ របស់ជនភៀសខ្លួន និងជនផ្លាស់លំនៅដ្ឋានក្នុងប្រទេស ៖ របាយការណ៍ចុងក្រោយរបស់អ្នករាយការណ៍ពិសេស, Paulo Sérgio Pinheiro" (E/CN.៤/ Sub.២/២០០៥/១៧) ។ អាចរកមើលបានផងដែរ នៅក្នុងឯកសាររបស់អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ និងឯកសារផ្សេងៗទៀត រួមមាន *Handbook on Housing and Property Restitution for Refugees and Displaced Persons: Implementing the "Pinheiro Principles"* (២០០៧)។

**គោលការណ៍ ៣ ៖ នីតិវិធី ស្ថាប័ន និងយន្តការជាតិ**

១២.១ រដ្ឋទាំងឡាយ គួរបង្កើត និងគាំទ្រ នីតិវិធី ស្ថាប័ន និងយន្តការមិនរើសអើង ឯករាជ្យ ទាន់ពេលវេលា និងសមធម៌ ដើម្បីវាយតម្លៃ និងពង្រឹងការអនុវត្តការប្តឹងទាមទារបដិទានលើលំនៅដ្ឋាន ដីធ្លី និងទ្រព្យសម្បត្តិ [...]។

**គោលការណ៍ ១៣ ៖ ការទទួលបាននីតីវិធីប្តឹងទាមទារសំណង**

១៣.១ ជនទាំងឡាយដែលទទួលរងការដកហូតដោយបំពាន ឬដោយខុសច្បាប់នូវសិទ្ធិមានលំនៅដ្ឋាន ដីធ្លី/ទ្រព្យសម្បត្តិ គួរមានលទ្ធភាពដាក់ពាក្យបណ្តឹងទាមទារបដិទាន ឬសំណងថ្លៃខូចខាតទៅកាន់ស្ថាប័នណាមួយដែលឯករាជ្យ និងមិនលំអៀង [...]។

**គោលការណ៍ ១៨ ៖ វិធានការច្បាប់**

១៨.១ រដ្ឋទាំងឡាយ ត្រូវធានាថា សិទ្ធិជនភៀសខ្លួន និងសិទ្ធិជនភៀសសឹក ក្នុងការទទួលបានបដិទានលើលំនៅដ្ឋាន ដីធ្លី និងទ្រព្យសម្បត្តិ ត្រូវបានទទួលស្គាល់ថាជាសមាសភាពដ៏សំខាន់មួយនៃនីតិរដ្ឋ។ រដ្ឋទាំងអស់ ត្រូវធានាចំពោះសិទ្ធិទទួលបានបដិទានលើលំនៅដ្ឋាន ដីធ្លី និងទ្រព្យសម្បត្តិ តាមរយៈមធ្យោបាយច្បាប់គ្រប់បែបយ៉ាងដែលចាំបាច់ រួមមាន តាមរយៈការអនុម័ត ការធ្វើវិសោធនកម្ម ការធ្វើកំណែទម្រង់ ឬ ការលុបច្បាប់ បទបញ្ញា និង/ឬ ការអនុវត្តន៍ដែលពាក់ព័ន្ធ។ រដ្ឋទាំងឡាយ គួរបង្កើតក្របខ័ណ្ឌច្បាប់មួយសម្រាប់ការពារសិទ្ធិទទួលបានបដិទានលើលំនៅដ្ឋាន ដីធ្លី និងទ្រព្យសម្បត្តិ ដែលមានភាពច្បាស់លាស់ មានស្ថិរភាព ហើយប្រសិនជាចាំបាច់ ត្រូវច្របាច់បញ្ចូលគ្នាជាច្បាប់តែមួយ។

## ឆ. ជនជាតិដើមភាគតិច

ជនជាតិដើមភាគតិច គឺជាក្រុមដែលលក្ខខណ្ឌរស់នៅរបស់ពួកគេ ក្នុងស្ថានភាពនៃលំនៅដ្ឋានមិនសមរម្យ ខ្លាំងជាងក្រុមដទៃទៀត ហើយតែងតែប្រឈមនឹងការរើសអើងជាប្រព័ន្ធនៅក្នុងទីផ្សារលំនៅដ្ឋាន។[១៨] ការព្រួយបារម្ភជាពិសេស គឺលើស្ថានភាពលំនៅដ្ឋានដែលមានកម្រិតទាបជាទូទៅ (ជាពិសេសបើប្រៀបធៀបទៅនឹងប្រជាជនភាគច្រើន) រួមមានសេវាមូលដ្ឋានមិនគ្រប់គ្រាន់ភាពងាយរងគ្រោះរបស់ពួកគេ ក្នុងនាមជាក្រុមដែលទទួលរងការបង្ខិតបង្ខំឲ្យផ្លាស់ទីលំនៅ ការកាន់កាប់គ្មានសុវត្ថិភាព ដែលពួកគេតែងជួបប្រទះលើដីប្រពៃណីរបស់ខ្លួន និងជម្រើសលំនៅដ្ឋានមិនសមស្របតាមវប្បធម៌ដែលជាញឹកញាប់ស្មើទ្បើងពីអាជ្ញាធរ ។ ក្រុមជនជាតិដើមភាគតិច ទទួលរងការរើសអើងស្ទើរគ្រប់ទិដ្ឋភាពទាំងអស់ក្នុងបញ្ហាលំនៅដ្ឋាន៖ ច្បាប់ និងគោលការណ៍ដែលរើសអើងពួកគេ មានជាអាទិ៍ ការមិនបានគិតគូរអំពីស្ថានភាពជាក់លាក់របស់ពួកគេ មានការរើសអើងក្នុងការបែងចែកធនធានសម្រាប់លំនៅដ្ឋាន រួមមានឥណទាន និងប្រាក់កម្ចី ហើយម្ចាស់ដីឯកជនរើសអើងពួកគេ ក្នុងទីផ្សារជួលផ្ទះសម្បែង។

បើទោះបីជាជនជាតិដើមភាគតិចភាគច្រើននៅទូទាំងពិភពលោក នៅតែបន្តរស់នៅតាមតំបន់ជនបទក្តី ក៏មានការកើនឡើងនៃចំនួនអ្នកទាំងនោះដែលបាននិងកំពុងធ្វើចំណាកស្រុកដោយស្ម័គ្រចិត្ត និងមិនស្ម័គ្រចិត្តទៅកាន់តំបន់ទីប្រជុំជន ចាកចោលដីធ្លី ទឹកដី និងធនធានប្រពៃណីរបស់ខ្លួន ហើយជារឿយៗធ្វើឲ្យពួកគេត្រូវប្រឈមនឹងភាពក្រីក្រកាន់តែខ្លាំងឡើងថែមទៀត។ ព្រោះតែហេតុនេះហើយ ទើបស្ថានភាពលំនៅដ្ឋានរបស់បុគ្គល និងក្រុមជនជាតិដើម

---

[១៨] កម្មវិធីសិទ្ធិមានលំនៅដ្ឋានរបស់អង្គការសហប្រជាជាតិ "របាយការណ៍លេខ ៧ ៖ សិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការទទួលបានលំនៅដ្ឋានសមរម្យ។ ទិដ្ឋភាពទូទៅជាសកល" (២០០៥)។

ភាគតិចជាច្រើននៅតាមតំបន់ទីប្រជុំជន មានលក្ខណៈមិនសមរម្យ។ ស្ត្រីជនជាតិដើមភាគតិច ជារឿយៗតែងទទួលបន្ទុកធ្ងន់ធ្ងរ ចំពោះស្ថានភាពលំនៅដ្ឋានដែលមានកម្រិតទាបនេះ។ ដោយហេតុថា នៅប្រទេសមួយចំនួន មានជនជាតិដើមភាគតិចជាងពាក់កណ្ដាល បច្ចុប្បន្ននេះកំពុងរស់នៅតាមទីក្រុង ទើបសិទ្ធិមានលំនៅដ្ឋានសមរម្យរបស់ពួកគេ គឺជាបញ្ហាប្រឈមថ្មីមួយទៀត សម្រាប់រដ្ឋាភិបាលទាំងនោះ។[១៩]

មាត្រា ១១ (១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចែងថា សិទ្ធិមានលំនៅដ្ឋានសមរម្យ គឺមានសម្រាប់មនុស្សគ្រប់រូប។ លើសពីនេះទៅទៀត មាត្រា ២ (២) បានចែងផងដែរថា សិទ្ធិទាំងឡាយដែលចែងក្នុងកតិកាសញ្ញានេះ នឹងត្រូវប្រើប្រាស់ដោយគ្មានការរើសអើង។ នេះមានន័យថា ក្រុមជនជាតិដើមភាគតិច មានសិទ្ធិមានលំនៅដ្ឋានសមរម្យ ដោយគ្មានការរើសអើង និងឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយនឹងប្រជាជនភាគច្រើន។

---

[១៩] UN-Habitat, *ការផ្ដល់លំនៅដ្ឋានដល់ក្រុមជនជាតិដើមភាគតិចនៅទីក្រុង ៖ គោលនយោបាយផ្ដល់លំនៅដ្ឋានដល់ក្រុមជនជាតិដើមភាគតិចនៅទីក្រុង* គោលនយោបាយណែនាំតាមទីក្រុងសំរាប់ក្រុមជនជាតិដើមភាគតិច (Nairobi, ២០០៩) ។

**សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច** (២០០៧) បានដាក់ចេញនូវបទដ្ឋានអន្តរជាតិកំរិតអប្បបរមាសម្រាប់ការពារ និងលើកស្ទួយសិទ្ធិជនជាតិដើមភាគតិច ដែលចាំបាច់សម្រាប់ការរស់រាន សុខុមាលភាព និងសេចក្តីថ្លៃថ្នូររបស់ពួកគេ។ សិទ្ធិដែលពាក់ព័ន្ធជាពិសេសទៅនឹងសិទ្ធិមានលំនៅដ្ឋានសមរម្យដែលមានចែងក្នុងសេចក្តីប្រកាសនេះ រាប់ទាំងសិទ្ធិស្វ័យសម្រេច សិទ្ធិពាក់ព័ន្ធនឹងដីធ្លី ធនធាន និងទឹកដី សិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច និងសិទ្ធិពាក់ព័ន្ធនឹងការមិនរើសអើង។ ការរំលោភសិទ្ធិស្វ័យសំរេច និងសិទ្ធិពាក់ព័ន្ធនឹងដីធ្លី ធនធាន និងទឹកដី របស់ជនជាតិដើមភាគតិច ជារឿយៗតែងឈានទៅដល់ការរំលោភសិទ្ធិមានលំនៅដ្ឋានសមរម្យរបស់ពួកគេ។ មាត្រា ២១ (១) ទទួលស្គាល់សិទ្ធិមានលំនៅដ្ឋានល្អប្រសើរនៅក្នុងចំណោមសិទ្ធិដទៃទៀត។ លើសពីនេះទៅទៀត សេចក្តីប្រកាសនេះ គូសបញ្ជាក់បន្ថែមអំពីសារៈសំខាន់នៃសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការកំណត់នូវស្ថានប័ន កម្មវិធី និងគោលនយោបាយលំនៅដ្ឋានរបស់ខ្លួន។

នៅក្នុងសេចក្តីពន្យល់រួមលេខ ២៣ (១៩៩៧) **គណៈកម្មាធិការបំបាត់រាល់ទំរង់នៃការរើសអើងពូជសាសន៍** បានបញ្ជាក់យ៉ាងច្បាស់អំពីការរើសអើងចំពោះជនជាតិដើមភាគតិច និងអំពាវនាវឲ្យរដ្ឋភាគីទាំងឡាយទទួលស្គាល់ និងការពារសិទ្ធិរបស់ពួកគេ "ក្នុងការកាន់កាប់ អភិវឌ្ឍន៍ គ្រប់គ្រង និងប្រើប្រាស់ដីធ្លី ទឹកដី និងធនធានសហគមន៍របស់ពួកគេ ក្នុងករណីមានការដកហូតដីធ្លី និងទឹកដីដែលពួកគេបានកាន់កាប់តាមប្រពៃណី ឬមានអ្នកមករស់នៅ ឬប្រើប្រាស់ដោយមិនបានប្រាប់ឲ្យដឹង និងមិនមានការយល់ព្រមដោយសេរីទេនោះ នោះរដ្ឋភាគី ត្រូវចាត់វិធានការប្រគល់ដីធ្លី និងទឹកដីនោះ ឲ្យទៅម្ចាស់ដើមវិញ។"

អនុសញ្ញាអង្គការពលកម្មអន្តរជាតិ លេខ ១៦៩ ស្តីពីជនជាតិដើមភាគតិច និងពួកកុលសម្ព័ន្ធ នៅក្នុងប្រទេសឯករាជ្យ (១៩៨៩) អំពាវនាវឲ្យរដ្ឋាភិបាលទាំងឡាយ ធានាថា ពលករជាជនជាតិដើមភាគតិច មិនត្រូវបានរើសអើងពាក់ព័ន្ធនឹងលំនៅដ្ឋានឡើយ(មាត្រា២០ (២) (គ))។

## III. តើរដ្ឋមានកាតព្វកិច្ចអ្វីខ្លះ ហើយអ្នកផ្សេងទៀតមានការទទួលខុសត្រូវអ្វីខ្លះ?

រដ្ឋមានកាតព្វកិច្ចធំជាងគេក្នុងការការពារ និងលើកស្ទួយសិទ្ធិមនុស្ស។ កាតព្វកិច្ចសិទ្ធិមនុស្ស ត្រូវបានកំណត់ និងធានាការពារដោយច្បាប់ទំនៀមទំលាប់អន្តរជាតិ (ភស្តុតាងនៃការអនុវត្តន៍ទូទៅរបស់រដ្ឋនានា ដែលត្រូវបានទទួលយកថាជាច្បាប់មួយ និងត្រូវបានអនុវត្តក្នុងន័យជាកាតព្វកិច្ចច្បាប់) និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលបង្កើតចំណងកាតព្វកិច្ចដល់រដ្ឋទាំងឡាយដែលបានផ្តល់សច្ចាប័ន និង ផ្តល់សុពលភាពអនុវត្តសិទ្ធិទាំងនេះ។

### ក. កាតព្វកិច្ចទូទៅ

តាមរយៈការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្ស រដ្ឋទាំងឡាយត្រូវបានតម្រូវឲ្យផ្តល់សុពលភាពអនុវត្តសិទ្ធិទាំងនេះ នៅក្នុងយុត្តាធិការរបស់ខ្លួន។ កាតព្វកិច្ចមួយចំនួន គឺមាន*សុពលភាពអនុវត្តភ្លាមៗ* រាប់ទាំងភារកិច្ចសំខាន់ក្នុងការធានាថា សិទ្ធិមានលំនៅដ្ឋានសមរម្យត្រូវបានអនុវត្ត ដោយឈរលើមូលដ្ឋាននៃ*ការមិនរើសអើង* ។

ស្ថិតក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋទាំងឡាយ មានកាតព្វកិច្ចធ្វើឲ្យមានការរីកចំរើនជាលំដាប់ នូវការសម្រេចបានដោយពេញលេញនូវសិទ្ធិមានលំនៅដ្ឋានសមរម្យ។ ម្យ៉ាងទៀត

កតិកាសញ្ញានេះទទួលស្គាល់ថា រដ្ឋទាំងឡាយ មានធនធាននៅមានកម្រិត ហើយថា គេអាចនឹងត្រូវការពេលវេលាមួយ ដើម្បីធានាបានសិទ្ធិមានលំនៅដ្ឋានសមរម្យសម្រាប់មនុស្សគ្រប់រូប។ ដូច្នេះ សមាសភាពមួយចំនួននៃសិទ្ធិមានលំនៅដ្ឋានសមរម្យ ត្រូវបានចាត់ទុកថា *ស្ថិតក្នុងការធ្វើឲ្យមានការរីកចំរើនជាលំដាប់*។ ប៉ុន្តែ កាតព្វកិច្ចមួយចំនួនទៀត ជាអាទិ៍ ការមិនរើសអើង គឺ*មិនស្ថិតក្នុងការធ្វើឲ្យមានការរីកចំរើនជាលំដាប់នោះទេ*។

**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**មាត្រា ២ (១)**

រដ្ឋភាគីនីមួយៗនៃកតិកាសញ្ញានេះ ដោយការប្រឹងប្រែងដោយខ្លួនឯងផ្ទាល់ និងតាមរយៈជំនួយ និងកិច្ចសហប្រតិបត្តិការអន្តជាតិ ជាពិសេស ខាងសេដ្ឋកិច្ច និងបច្ចេកទេស សន្យាចាត់វិធានការដោយប្រើប្រាស់ជាអតិបរមានូវធនធានដែលខ្លួនមាន សម្រាប់ធ្វើឲ្យមានការរីកចំរើនជាលំដាប់ នូវការសម្រេចបានពេញលេញនូវសិទ្ធិទាំងអស់ដែលទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ តាមគ្រប់មធ្យោបាយសមស្រប រួមមានជាពិសេស ការអនុម័តវិធានការច្បាប់ផង។

បើទោះជាមិនសុទ្ធសឹងតែគ្រប់ទិដ្ឋភាពទាំងអស់ នៃសិទ្ធិមានលំនៅដ្ឋានសមរម្យ អាច ឬនឹងអាចធ្វើឲ្យសម្រេចបានដោយពេញលេញក្តី ក៏យ៉ាងហោចណាស់ រដ្ឋទាំងឡាយត្រូវបង្ហាញថា ខ្លួនកំពុងតែខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងតាមធនធានដែលមាន ដើម្បីការពារ និងលើកស្ទួយសិទ្ធិនេះឲ្យកាន់តែល្អប្រសើរឡើងថែមទៀត។ ធនធានដែលមាន សំដៅដល់ធនធានទាំងឡាយដែលមានស្រាប់នៅក្នុងរដ្ឋ ក៏ដូចជា ធនធានទាំងឡាយ ដែលអាចរកបានពីសហគមន៍អន្តរជាតិ តាមរយៈកិច្ចសហប្រតិបត្តិការ និងជំនួយអន្តរជាតិ ដូចបាន

គូសបញ្ជាក់ក្នុងមាត្រា ២ (១) មាត្រា ១១ និង មាត្រា ២៣ នៃកតិកាសញ្ញានេះ។

មាត្រា ៣ នៃកតិកាសញ្ញានេះ បានតម្រូវបន្ថែមឲ្យរដ្ឋភាគី ធានានូវសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងការទទួលបានសិទ្ធិទាំងឡាយ ដូចមានចែងក្នុងកតិកាសញ្ញានេះ។

**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌**

**មាត្រា ២ (២)**

រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាថា សិទ្ធិទាំងឡាយដែលមានចែងនៅក្នុងកតិកាសញ្ញានេះ នឹងត្រូវប្រើប្រាស់ដោយគ្មានការរើសអើងណាមួយ ផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬ មតិផ្សេងៗទៀត ដើមកំណើតជាតិ ឬ សង្គម ទ្រព្យសម្បត្តិ កំណើត ឬ ស្ថានភាពដទៃទៀតឡើយ។

ក្នុងនោះក៏មានកាតព្វកិច្ចបន្ទាន់មួយផងដែរ ក្នុងការ*ចាត់វិធានការ*ច្បាស់លាស់ មានស្មារតីទទួលខុសត្រូវ និងមានគោលដៅពិតប្រាកដ ដើម្បីបំពេញសិទ្ធិមានលំនៅដ្ឋានសមរម្យ។ រដ្ឋភាគីនីមួយៗ ត្រូវធានាការពារសិទ្ធិនេះ យ៉ាងហោចណាស់ក៏ក្នុងកំរិតអប្បបរមាដែរ។ ជាអាទិ៍ រដ្ឋត្រូវធានាថា មិនមានបុគ្គលណាមួយ ត្រូវបានគេដកហូតសិទ្ធិមានលំនៅដ្ឋាន និងទីជម្រកចាំបាច់ឡើយ។ ប្រសិនបើរដ្ឋមួយ មិនអាចធ្វើបែបនេះបាន រដ្ឋនោះ ត្រូវតែបង្ហាញថា ខ្លួនបានខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ក្នុងការប្រើប្រាស់រាល់ធនធានដែលមាន ដើម្បីបំពេញឲ្យបាន ជាបញ្ហាអាទិភាព នូវកំរិតអប្បបរមាជាសារវ័ន្តទាំងនេះ។ ម្យ៉ាងវិញទៀត ប្រសិនជារដ្ឋនោះ បានអនុម័តវិធានការមួយ ដែលដើរថយក្រោយវិញ ឧទាហរណ៍ថា ជាវិធានការមួយ ដែលធ្វើឲ្យចុះខ្សោយដល់ការការពារសិទ្ធិមាន

លំនៅដ្ឋានសមរម្យ រដ្ឋនោះនឹងត្រូវបង្ហាញថា ខ្លួនបានធ្វើការថ្លឹងថ្លែងយ៉ាងប្រុងប្រយ័ត្នលើគ្រប់ជម្រើសទាំងអស់ ដោយបានគិតអំពីផលប៉ះពាល់ទូទៅនៃវិធានការលើរាល់សិទ្ធិមនុស្ស និងបានប្រើប្រាស់ធនធានដែលខ្លួនមានទាំងអស់។ ដោយសារតែវិធានដែលត្រូវធ្វើភាគច្រើនបំផុត ក្នុងការអនុវត្តន៍សិទ្ធិមានលំនៅដ្ឋានសមរម្យ មានលក្ខណៈខុសប្លែកគ្នាពីរដ្ឋមួយទៅរដ្ឋមួយនោះ ទើបបានជាសន្ធិសញ្ញាអន្តរជាតិ មិនផ្តល់សំណុំអនុសាសន៍អ្វីឡើយ។ កតិកាសញ្ញានេះគ្រាន់តែចែងថា ការសម្រេចបានដោយពេញលេញនូវសិទ្ធិដែលមានក្នុងនោះ ត្រូវតែធ្វើឲ្យសម្រេច តាមរយៈគ្រប់មធ្យោបាយសមស្រប រាប់ទាំងជាពិសេសការអនុម័តវិធានការច្បាប់ផងដែរ"។

គណៈកម្មាធិការបានបញ្ជាក់ផងដែរថា វិធានការមួយចំនួន ត្រូវតែដាក់ចេញជាបន្ទាន់ ជាអាទិ៍ វិធានការទាំងឡាយ ដែលមានគោលដៅផ្តល់សុវត្ថិភាពកាន់កាប់ស្របច្បាប់ដល់អ្នកដែលគ្មានការការពារបែបនេះ ការឃ្លាំមើលប្រកបដោយប្រសិទ្ធភាពលើស្ថានភាពលំនៅដ្ឋាន ជាពិសេស ការកំណត់វិសាលភាពពេញលេញនៃភាពគ្មានផ្ទះសម្បែង និងលំនៅដ្ឋានសមរម្យ ការការពារប្រឆាំងនឹងការបណ្តេញចេញដោយបំពាន និងការផ្តល់ដំណោះស្រាយតាមផ្លូវច្បាប់ ឬដំណោះស្រាយសមស្របផ្សេងទៀត ប្រកបដោយប្រសិទ្ធភាព សម្រាប់ការរំលោភបំពានលើសិទ្ធិមានលំនៅដ្ឋានសមរម្យ។

**ការធ្វើឲ្យសម្រេចបានជាលំដាប់ នូវសិទ្ធិមានលំនៅដ្ឋានសមរម្យ ក្នុងការអនុវត្តជាក់ស្តែង**

យោងតាមសាធារណរដ្ឋដូមីនីកង់ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានសង្កត់ធ្ងន់ថា "ដើម្បីធ្វើឲ្យសម្រេចបានជាលំដាប់នូវសិទ្ធិមានលំនៅដ្ឋានសមរម្យ រដ្ឋាភិបាលត្រូវបានស្នើឲ្យផ្តល់សេវាមូលដ្ឋាន (ទឹក អគ្គីសនី ប្រព័ន្ធលូ ប្រព័ន្ធអនាម័យ ការប្រមូលសំរាម ជាដើម) ដល់លំនៅដ្ឋាន ហើយធានាថា លំនៅដ្ឋាន

សាធារណៈ ត្រូវបានផ្តល់ឲ្យក្រុមមនុស្សក្នុងសង្គមដែលមានសេចក្តីត្រូវការខ្ពស់បំផុត។ រដ្ឋ គួរស្វែងរកដើម្បីធានាផងដែរថា វិធានការទាំងនេះត្រូវបានអនុវត្តដោយគោរពច្បាប់ទាំងស្រុង។ ដើម្បីជំនះបញ្ហាទាំងឡាយកំពុងកើតមានដែលរដ្ឋាភិបាលបានទទួលស្គាល់ ក្នុងការសន្ទនារបស់ខ្លួនជាមួយនឹងគណៈកម្មាធិការនេះ រដ្ឋាភិបាលត្រូវបានស្នើយ៉ាងទទូចឲ្យគិតគូដល់គំនិតផ្តួចផ្តើមផ្សេងៗ ដែលបានតាក់តែងឡើងដើម្បីលើកកំពស់ការចូលរួមពីអ្នកដែលទទួលរងផលប៉ះពាល់ក្នុងការរៀបចំតាក់តែង និងការអនុវត្តន៍គោលនយោបាយលំនៅដ្ឋាន។ គំនិតផ្តួចផ្តើមទាំងនេះ អាចរាប់បញ្ចូល ៖ (ក) ការប្តេជ្ញាចិត្តជាផ្លូវការ ក្នុងការជួយសម្រួលដល់ការចូលរួម ដែលមានប្រជាប្រិយភាពនៅក្នុងដំណើរការអភិវឌ្ឍតំបន់ទីប្រជុំជន (ខ) ការទទួលស្គាល់តាមផ្លូវច្បាប់ អង្គការមូលដ្ឋានសហគមន៍ (គ) ការបង្កើតឲ្យមានប្រព័ន្ធហិរញ្ញវត្ថុមួយសម្រាប់លំនៅដ្ឋានតាមសហគមន៍ដែលតាក់តែងឡើង ដើម្បីបើកបណ្តាញឥណទានបន្ថែម សម្រាប់វិស័យសង្គមអ្នកក្រីក្រខ្លាំង (ឃ) ការពង្រឹងតួនាទីរបស់អាជ្ញាធរក្រុង ក្នុងវិស័យលំនៅដ្ឋាន (ង) ពង្រឹងការសម្របសម្រួលរវាងស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាលដែលទទួលខុសត្រូវលើកិច្ចការលំនៅដ្ឋាន និងពិចារណាលើការបង្កើតទីភ្នាក់ងារផ្នែកលំនៅដ្ឋានរបស់រដ្ឋាភិបាលតែមួយ” (E/C.១២/១៩៩៤/២០, paras. ៣៣២–៣៣៣)។

តួនាទីនៃជំនួយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ត្រូវបានចែងផងដែរនៅក្នុងលិខិតុបករណ៍ផ្សេងទៀត ដូចជា ធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ តួនាទីនោះមិនជំនួសឲ្យកាតព្វកិច្ចជាតិទេ ប៉ុន្តែវានឹងពាក់ព័ន្ធ ប្រសិនបើរដ្ឋណាមួយមិនអាច

ផ្តល់សុពលភាពអនុវត្តសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច និងវប្បធម៌ បានដោយខ្លួនឯង ហើយត្រូវការជំនួយពីរដ្ឋដទៃ ដើម្បីធ្វើការងារនេះ។ កិច្ចសហប្រតិបត្តិការអន្តរជាតិ ពឹងផ្អែកជាពិសេស លើរដ្ឋទាំងឡាយដែលមានតួនាទីជួយរដ្ឋផ្សេងទៀតក្នុងបញ្ហានេះ។ ដូច្នេះ រដ្ឋទាំងឡាយ ត្រូវមានកម្មវិធីសកម្មមួយសម្រាប់ការជួយឧបត្ថម្ភ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងផ្តល់ជំនួយផ្នែកសេដ្ឋកិច្ច និងបច្ចេកទេស ដើម្បីឲ្យរដ្ឋផ្សេងទៀត មានលទ្ធភាពបំពេញកាតព្វកិច្ចរបស់ខ្លួនខាងសិទ្ធិមានលំនៅដ្ឋានសមរម្យ។ កាតព្វកិច្ចទូទៅដើម្បីធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិនេះ ត្រូវបានបញ្ជាក់នៅក្នុងសេចក្តីពន្យល់រួមលេខ ៣ (១៩៩០) របស់គណៈកម្មាធិការនេះ ស្តីពីចរិតលក្ខណៈនៃកាតព្វកិច្ចរបស់រដ្ឋភាគីទាំងឡាយ និងសេចក្តីពន្យល់រួមលេខ ១៤ (២០០០) ស្តីពីសិទ្ធិមានបទដ្ឋានសុខភាពកម្រិតខ្ពស់បំផុត។

## ខ. កាតព្វកិច្ចបីប្រភេទ

រដ្ឋមានកាតព្វកិច្ចបីប្រភេទគឺ *កាតព្វកិច្ចគោរព កាតព្វកិច្ចការពារ និង កាតព្វកិច្ចបំពេញ ។*

*កាតព្វកិច្ចគោរព*

កាតព្វកិច្ចគោរព តម្រូវឲ្យរដ្ឋទាំងឡាយ ជៀសវាងការជ្រៀតជ្រែកដោយផ្ទាល់ ឬដោយប្រយោល ក្នុងការប្រើប្រាស់សិទ្ធិមានលំនៅដ្ឋានសមរម្យ។

ឧទាហរណ៍ រដ្ឋទាំងឡាយ ត្រូវជៀសវាងការបណ្តេញចេញដោយបំពាន និងការបំផ្លិចបំផ្លាញផ្ទះសម្បែង ការបដិសេធសុវត្ថិភាពក្នុងការកាន់កាប់ ចំពោះក្រុមជាក់លាក់មួយចំនួន ការបង្កើតទង្វើរើសអើងដែលរឹតត្បិតសិទ្ធិ និងការគ្រប់គ្រងរបស់ស្ត្រីលើលំនៅដ្ឋាន ដីធ្លី និងទ្រព្យសម្បត្តិ ការរំលោភបំពានលើសិទ្ធិឯកជន និងការការពារផ្ទះសម្បែង ការបដិសេធបដិទានលើលំនៅដ្ឋាន ដីធ្លី និងទ្រព្យសម្បត្តិ ចំពោះក្រុមជាក់លាក់ណាមួយ ឬ ការបំពុលប្រភពទឹក។

*កាតព្វកិច្ចការពារ*

កាតព្វកិច្ចការពារ តម្រូវឲ្យរដ្ឋភាគី រារាំងភាគីទីបីពីការជ្រៀតជ្រែកក្នុងការអនុវត្តន៍សិទ្ធិមានលំនៅដ្ឋានសមរម្យ។

រដ្ឋត្រូវអនុម័តច្បាប់ ឬវិធានការផ្សេងទៀត ដើម្បីធានាថា តួអង្គឯកជន (ជាអាទិ៍ ម្ចាស់ផ្ទះ អ្នកអភិវឌ្ឍអចលនទ្រព្យ ម្ចាស់ដី និងក្រុមហ៊ុនសាជីវកម្មនានា) គោរពបទដ្ឋានសិទ្ធិមនុស្សពាក់ព័ន្ធនឹងសិទ្ធិមានលំនៅដ្ឋានសមរម្យ។ ឧទាហរណ៍ រដ្ឋគួរតែធ្វើនិយតកម្មទីផ្សារលំនៅដ្ឋាន និងការជួលផ្ទះសម្បែង ក្នុងវិធីមួយដែលលើកស្ទួយ និងការពារសិទ្ធិមានលំនៅដ្ឋានសមរម្យ ដោយធានាថា ធនាគារ និងស្ថាប័នហិរញ្ញវត្ថុនានា ផ្តល់ហិរញ្ញប្បទានសម្រាប់លំនៅដ្ឋាន ដោយគ្មានការរើសអើង ធានាថា ការផ្តល់ជាលក្ខណៈឯកជននូវទឹក សេវាអនាម័យ និង សេវាចាំបាច់ដទៃទៀតពាក់ព័ន្ធនឹងលំនៅដ្ឋាន មិនធ្វើឲ្យខូចលទ្ធភាពអាចរកបាន ទទួលបាន និងគុណភាពនៃសេវា ធានាថា ភាគីទីបី មិនដកហូតសេវាទាំងនោះតាមទំនើងចិត្ត និងដោយខុសច្បាប់ឡើយ ទប់ស្កាត់ទង្វើរើសអើងខាងមរតក ដែលប៉ះពាល់ដល់សិទ្ធិ និងការគ្រប់គ្រងលំនៅដ្ឋាន ដីធ្លី និងទ្រព្យសម្បត្តិ ធានាថា ម្ចាស់ផ្ទះមិនរើសអើងលើក្រុមជាក់លាក់ទាំងនេះ និងធានាថា តួអង្គឯកជន មិនត្រូវធ្វើការបណ្តេញពួកគេចេញដោយបំពានឡើយ។

*កាតព្វកិច្ចបំពេញ*

កាតព្វកិច្ចបំពេញ តម្រូវឲ្យរដ្ឋទាំងឡាយ អនុម័តវិធានការសមស្របផ្នែកច្បាប់ រដ្ឋបាល ថវិកា យុត្តិធម៌ ផ្សព្វផ្សាយ និង វិធានការដទៃទៀត ដើម្បីឲ្យសម្រេចបានពេញលេញនូវសិទ្ធិមានលំនៅដ្ឋានសមរម្យ។

ឧទាហរណ៍ រដ្ឋត្រូវតែអនុម័តគោលនយោបាយលំនៅដ្ឋានជាតិ ឬផែនការលំនៅដ្ឋានជាតិមួយ ដែលកំណត់គោលដៅសម្រាប់ការអភិវឌ្ឍន៍វិស័យលំនៅដ្ឋាន ដោយផ្តោតសំខាន់លើក្រុមងាយរងគ្រោះ និងប្រជាពលរដ្ឋក្រីក្រ កំណត់ធនធានដែលមានដើម្បីបំពេញគោលដៅទាំងនេះ កំណត់មធ្យោបាយ

ដែលមានប្រសិទ្ធភាពបំផុតក្នុងការប្រើប្រាស់ធនធានទាំងនេះ បរិយាយត្រួសៗ អំពីការទទួលខុសត្រូវ និងក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្តវិធានការចាំបាច់ទាំងឡាយ ឃ្លាំមើលលទ្ធផល និងធានាឲ្យមានដំណោះស្រាយសមស្របចំពោះការរំលោភបំពានផ្សេងៗ។

ស្ថិតក្រោមកាតព្វកិច្ចបំពេញ តាមកម្រិតធនធានដែលមាន និងជាលំដាប់ រដ្ឋទាំងឡាយ ក៏ត្រូវបង្ការ និងដោះស្រាយបញ្ហាគ្មានផ្ទះសម្បែង ដោយផ្តល់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តចាំបាច់សម្រាប់លំនៅដ្ឋាន ដើម្បីឲ្យអាចចាត់ទុកបានថាជាលំនៅដ្ឋានសមរម្យ (នេះរាប់បញ្ចូលផងដែរនូវចំណាត់វិធានការផ្សេងៗ ដើម្បីធានាដល់ការទទួលបានជាសកល និងដោយគ្មានការរើសអើងនូវថាមពល អគ្គីសនី ទឹកពិសារមានសុវត្ថិភាព សេវាអនាម័យល្អ សេវាប្រមូលសំរាម និង សេវាចាំបាច់ផ្សេងទៀត) ឬ ធានាឲ្យមានលំនៅដ្ឋានសមរម្យសម្រាប់បុគ្គល ឬ ក្រុមដែលមិនអាចប្រើប្រាស់សិទ្ធិមានលំនៅដ្ឋានសមរម្យនេះបានដោយសារតែហួសលទ្ធភាពរបស់ខ្លួន ជាពិសេស តាមរយៈការជួយឧបត្ថម្ភធនធានសំរាប់លំនៅដ្ឋាន និងវិធានការនានា។

## គ. ការទទួលខុសត្រូវរបស់អ្នកដទៃទៀត

កាតព្វកិច្ចរបស់រដ្ឋ ក្នុងការការពារសិទ្ធិមនុស្ស រួមមាន ការធានាថា តួអង្គដែលមិនមែនជារដ្ឋ មិនរំលោភសិទ្ធិមានលំនៅដ្ឋានសមរម្យ។ នេះជាកាតព្វកិច្ចការពារ ដូចបានរៀបរាប់ខាងលើ។ ម្យ៉ាងវិញទៀត មានការជជែកពិភាក្សាកាន់តែកើនឡើង អំពីវិសាលភាព ដែលតួអង្គដទៃទៀតនៅក្នុងសង្គម (ឯកត្តបុគ្គល អង្គការអន្តររដ្ឋាភិបាល ឬ អង្គការមិនមែនរដ្ឋាភិបាល និង ក្រុមហ៊ុនសាជីវកម្ម) មានការទទួលខុសត្រូវក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស។

ផ្នែកនេះ បង្ហាញពីតួនាទីរបស់ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងវិស័យឯកជន។

*ទីភ្នាក់ងារអង្គការសហប្រជាជាតិ*

យោងតាមធម្មនុញ្ញអង្គការសហប្រជាជាតិ គោលបំណងមួយក្នុងចំណោមគោលបំណងជាច្រើនទៀតរបស់អង្គការសហប្រជាជាតិ គឺការលើកកំពស់ការគោរពសិទ្ធិមនុស្ស។ សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ក៏មើលឃើញផងដែរ អំពីតួនាទីពិសេសមួយសម្រាប់ទីភ្នាក់ងារអង្គការសហប្រជាជាតិក្នុងការអនុវត្តន៍របស់ខ្លួន។ នៅក្នុងសេចក្ដីពន្យល់រួមលេខ ២ (១៩៩០) ស្ដីពីវិធានការជំនួយឧបត្ថម្ភផ្នែកបច្ចេកទេសអន្តរជាតិ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក៏បានគូសបញ្ជាក់ផងដែរថា គ្រប់អង្គការ និងទីភ្នាក់ងារទាំងអស់របស់អង្គការសហប្រជាជាតិដែលពាក់ព័ន្ធក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ គួរតែធានាថា សិទ្ធិទាំងឡាយដែលមានក្នុងកតិកាសញ្ញានេះ ត្រូវបានយកមកពិចារណាយ៉ាងពេញលេញនៅក្នុងដំណាក់កាលនីមួយៗនៃគម្រោងអភិវឌ្ឍន៍។

**កម្មវិធីអង្គការសហប្រជាជាតិ សម្រាប់លំនៅដ្ឋានមនុស្សជាតិ (UN-Habitat)**

UN-Habitat គឺជាទីភ្នាក់ងារមួយរបស់អង្គការសហប្រជាជាតិសម្រាប់លំនៅដ្ឋានមនុស្សជាតិ។ ទីភ្នាក់ងារនេះ ត្រូវបានមហាសន្និបាតប្រគល់អាណត្តិឲ្យលើកកំពស់តំបន់ទីប្រជុំជន និងទីក្រុងប្រកបដោយនិរន្តរភាពផ្នែកសង្គម និងបរិស្ថាន ដែលមានគោលដៅផ្ដល់ទីជម្រកសមស្របដល់មនុស្សគ្រប់រូប។ ក្នុងការដោះស្រាយបញ្ហាប្រឈមនេះ UN-Habitat បាននិងកំពុងអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការស្ថាប័នរយៈពេលមធ្យមរបស់ខ្លួន សម្រាប់ឆ្នាំ ២០០៨ ដល់ ២០១៣ ។ ផែនការនេះ មានគោលដៅផ្ដោតលើនគរូបនីយកម្មប្រកបដោយនិរន្តរភាព ដែលអាចសម្រេចទៅបាន លុះត្រាតែការបង្ការ និងការអភិវឌ្ឍន៍លំនៅដ្ឋានរបស់ជនក្រីក្រតាមតំបន់ទីប្រជុំជន

ត្រូវបានដោះស្រាយតាមរយៈវិធានសមស្រប ដែលអនុញ្ញាតិឲ្យមានការផ្តល់ដីធ្លី និងលំនៅដ្ឋានសម្រាប់ជនក្រីក្រ ក៏ដូចជាការទទួលបានដោយស្មើភាពគ្នានូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាផ្សេងៗ។ លទ្ធផលសំខាន់ៗដែលរំពឹងទុកនៅក្នុងតំបន់គោលដៅ "ដីធ្លី និងលំនៅដ្ឋានសម្រាប់ជនក្រីក្រ" រួមមាន ៖

យុទ្ធសាស្ត្រទីជម្រកឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងការយល់ដឹងអំពីយេនឌ័រ និងអាយុ និងក្របខ័ណ្ឌច្បាប់រឹងមាំ និងសមត្ថភាពដែលផ្តល់សម្រាប់ការធ្វើឲ្យសម្រេចបានជាលំដាប់នូវសិទ្ធិមានលំនៅដ្ឋាន ដីធ្លី និងទ្រព្យសម្បត្តិ ការបង្ការ និងការអភិវឌ្ឍន៍លំនៅដ្ឋានរបស់ជនក្រីក្រតាមតំបន់ទីប្រជុំជន ដែលរដ្ឋសមាជិកទាំងឡាយ បានអនុម័ត និងបានអនុវត្ត។

អង្គការសហគមន៍ផ្អែកលើសមាជិកភាព សម្រាប់លំនៅដ្ឋាន លទ្ធកម្មដីធ្លី និងនិងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័នតាមតំបន់ទីប្រជុំជនត្រូវបានបង្កើតឡើង ឬត្រូវបានពង្រឹង។

លទ្ធភាពច្រើនថែមទៀត ក្នុងការទទួលបានដីធ្លី លំនៅដ្ឋាន និងទ្រព្យសម្បត្តិ ដោយផ្តោតជាពិសេសលើជនក្រីក្រតាមតំបន់ទីប្រជុំជន និងប្រជាជនដែលរងផលប៉ះពាល់ពីការតាំងលំនៅដ្ឋាន ស្ថិតក្នុងស្ថានភាពមានវិបត្តិ។

ជំនួយសង្គ្រោះសម្រាប់ទីជម្រកឆ្លើយតបដោយនិរន្តរភាពទៅនឹងការយល់ដឹងអំពីយេនឌ័រ និងគំរូសាងសង់ជាថ្មីនៅក្នុងតំបន់ក្រោយជម្លោះ និងតំបន់បន្ទាប់ពីគ្រោះមហន្តរាយ ត្រូវបានបង្កើត និងត្រូវបានអនុវត្ត។

សមិទ្ធិផលសម្រេចបាននៃសុវត្ថិភាពក្នុងការកាន់កាប់ តាមរយៈ

វិធានការល្អប្រសើរ ផ្នែកសុវត្ថិភាពក្នុងការកាន់កាប់សម្រាប់ស្ត្រី និងយុវវ័យផងដែរ រួមជាមួយនឹងការបង្កើត និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពនូវយន្តការឃ្លាំមើល និងវាយតម្លៃជាសកលមួយស្តីពីវឌ្ឍនភាពក្នុងការធ្វើឲ្យសម្រេចបានសិទ្ធិមានលំនៅដ្ឋាន ដីធ្លី និងទ្រព្យសម្បត្តិ។

ការងាររបស់អង្គការUN-Habitat គឺពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងសេចក្តីប្រកាសសហសវត្សរ៍អង្គការសហប្រជាជាតិ ជាពិសេសគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ទី៧ គោលដៅ ៧.ឃ ក្នុងការធ្វើឲ្យប្រសើរឡើងដល់ជីវិតរស់នៅរបស់មនុស្ស យ៉ាងហោចណាស់ ១០០ លាន នាក់ ដែលរស់នៅតំបន់ក្រីក្រតាមទីប្រជុំជននៅត្រឹមឆ្នាំ ២០២០ និងគោលដៅ ៧.គ ដែលអំពាវនាវឲ្យមានការកាត់បន្ថយមកនៅត្រឹមពាក់កណ្តាលនៃចំនួនប្រជាជនដែលមិនទទួលបានដោយនិរន្តរភាពនូវទឹកពិសារមានសុវត្ថិភាព និងសេវាអនាម័យមូលដ្ឋាននៅត្រឹមឆ្នាំ ២០១៥។

*ប្រភព:* www.unhabitat.org

ក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កំណែទម្រង់របស់អង្គការសហប្រជាជាតិ ដោយអគ្គលេខាធិការ (ក្នុងឆ្នាំ១៩៩៧, ២០០២ និង ២០០៥) បានផ្តោតសំខាន់លើតួនាទី និងការទទួលខុសត្រូវរបស់ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិចំពោះសិទ្ធិមនុស្ស។ ទាំងធនាគារពិភពលោក ទាំងអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍន៍(OECD) បានអនុម័តគោលការណ៍ណែនាំស្តីពីការផ្លាស់ប្តូរទីលំនៅដោយបង្ខំ និង/ឬ ការតាំងទីលំនៅថ្មី ដើម្បីកម្រិតទំហំនៃការរងទុក្ខរបស់មនុស្ស ដែលកើតចេញពីការបណ្តេញចេញដោយបំពាន។ នៅក្នុងឆ្នាំ២០០៣ ដោយមានការយល់ឃើញជារួមមួយ

បណ្តាទីភ្នាក់ងារអង្គការសហប្រជាជាតិ បានអះអាងថា រាល់ជំនួយឧបត្ថម្ភ និង កម្មវិធីអភិវឌ្ឍន៍ ត្រូវតែគោរពសិទ្ធិមនុស្ស និងត្រូវអនុវត្តន៍តាមគោលការណ៍និង បទដ្ឋានសិទ្ធិមនុស្ស។

ទីភ្នាក់ងារអង្គការសហប្រជាជាតិ បាននិងកំពុងធ្វើការងារកាន់តែច្រើន ឡើងៗក្នុងបញ្ហាពាក់ព័ន្ធនឹងសិទ្ធិលំនៅដ្ឋាន និងសិទ្ធិមនុស្ស។ ការងារដែល ពាក់ព័ន្ធជាពិសេសនោះគឺ កម្មវិធីសិទ្ធិលំនៅដ្ឋានអង្គការសហប្រជាជាតិ (UNHRP) ដែលបានរួមគ្នាបើកឲ្យប្រើប្រាស់ជាផ្លូវការ ដោយការិយាល័យឧត្តម ស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) និង អង្គការ UN-Habitat នៅក្នុងឆ្នាំ២០០២ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិ បាលនានា សង្គមស៊ីវិល និងស្ថាប័នសិទ្ធិមនុស្សជាតិ(NHRI) ដើម្បីឈានទៅ សំរេចបានសិទ្ធិមានលំនៅដ្ឋានសមរម្យ។

*វិស័យឯកជន*

ធុរកិច្ច និងវិស័យឯកជនគឺជាតួអង្គដ៏សំខាន់។ វិស័យឯកជន មានជា អាទិ៍ អ្នកអភិវឌ្ឍន៍អចលនទ្រព្យ ក្រុមហ៊ុនសំណង់ និងអ្នកផ្តល់ហេដ្ឋារចនា សម្ព័ន្ធ គឺពាក់ព័ន្ធដោយផ្ទាល់ក្នុងការសាងសង់លំនៅដ្ឋានមួយផ្នែកធំ។ ក្រុមហ៊ុន ទាំងឡាយ ក៏បានចូលរួមផងដែរ ក្នុងការគ្រប់គ្រង និងថែទាំអាគារ និងលំនៅ ដ្ឋាន។ នៅប្រទេសជាច្រើន ការគ្រប់គ្រងការជួល និងកិច្ចសន្យាលក់រវាងភាគី ឯកជន បានបំពេញសេចក្តីត្រូវការខាងលំនៅដ្ឋានបានមួយភាគធំ។

ទន្ទឹមនេះដែរ វិស័យឯកជន អាចមានផលប៉ះពាល់អវិជ្ជមានផងដែរ ដល់ សិទ្ធិមានលំនៅដ្ឋានសមរម្យ។ ផលប៉ះពាល់នេះ អាចមានជាប្រាកដ ក្នុងបរិបទ នៃការសាងសង់ទំនប់ទឹកធំៗ និងគម្រោងអភិវឌ្ឍន៍ផ្សេងៗ ជាពិសេស គម្រោង ដែលពាក់ព័ន្ធនឹងការទាញយកធនធាន ដូចជា ឧស្ម័ន ប្រេង ដែលអាចបង្ខំឲ្យ អ្នកស្រុកធ្វើការរុះរើចេញពីតំបន់នោះ ឬការធ្វើឲ្យខូចបរិស្ថាន។ ម្ចាស់ផ្ទះ ម្ចាស់ កម្មសិទ្ធិឯកជន ទីភ្នាក់ងារលំនៅដ្ឋាន ឬ ទីភ្នាក់ងារអចលនទ្រព្យ ក៏អាចប៉ះពាល់

ដល់ការប្រើប្រាស់សិទ្ធិមានលំនៅដ្ឋានសមរម្យផងដែរ ជាពិសេស ប្រសិនបើពួកគេធ្វើការបណ្តេញចេញដោយបំពាន ឬរើសអើងចំពោះក្រុមជាក់លាក់ណាមួយ ដូចជា ការគិតថ្លៃឈ្នួលខ្ពស់ហួសលទ្ធភាពបង់បានជាដើម។

វិស័យឯកជន ក៏អាចមានការប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិមានលំនៅដ្ឋានសមរម្យផងដែរ ក្នុងករណីដែលលំនៅដ្ឋានត្រូវបានផ្តល់ឲ្យដោយនិយោជក ។ អនុសាសន៍របស់អង្គការពលកម្មអន្តរជាតិ (ILO) លេខ ១១៥ ស្តីពីលំនៅដ្ឋានរបស់កម្មករ (១៩៦១) បានគូសបញ្ជាក់ថា ជាទូទៅ វាជារឿងពុំគួរនោះទេ ដែលនិយោជក ផ្តល់លំនៅដ្ឋានឲ្យកម្មកររបស់ខ្លួនដោយផ្ទាល់នោះ។ មានករណីលើកលែងខ្លះ ដែលនិយោជក គឺជាអ្នកផ្តល់កន្លែងស្នាក់នៅឲ្យកម្មករ តែទោះជាយ៉ាងណាក៏ដោយ គេត្រូវតែទទួលស្គាល់សិទ្ធិមនុស្សជាមូលដ្ឋានរបស់កម្មករ ហើយមិនគួរគិតថ្លៃឈ្នួលពីកម្មករលើសពីចំណែកសមាមាត្រសមស្របនៃប្រាក់ចំណូលរបស់គេ និងមិនគួរគៃយកកម្រៃឡើយ។ អនុសាសន៍នេះបានគូសបញ្ជាក់បន្ថែមថា និយោជក មិនត្រូវផ្តល់កន្លែងស្នាក់នៅ និងសេវាប្រើប្រាស់រួមគ្នា ដល់កម្មករជាថ្នូរ ជាដាច់ខាត ផ្ទុយទៅវិញ គេគួរតែធ្វើនិយតកម្មក្នុងកម្រិតចាំបាច់ណាមួយ ដើម្បីការពារផលប្រយោជន៍កម្មករ។

ទន្ទឹមនឹងរដ្ឋ មានការទទួលខុសត្រូវសំខាន់ ក្នុងការធានាថា តួអង្គឯកជនត្រូវគោរពសិទ្ធិមនុស្ស តាមប្រសាសន៍របស់តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកធុរកិច្ច និងសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្មទាំងឡាយ ក៏មានការទទួលខុសត្រូវ ក្នុងការគោរពសិទ្ធិមនុស្សគ្រប់យ៉ាងផងដែរ រាប់ទាំងសិទ្ធិមានលំនៅដ្ឋានសមរម្យ។ ការទទួលខុសត្រូវនេះ គឺជាការរំពឹងទុកដ៏សំខាន់មួយដែលសង្គមមានទៅលើធុរកិច្ច និងត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាលិខិតុបករណ៍ច្បាប់ដែលមិនមានលក្ខណៈចាប់បង្ខំ (ច្បាប់ទន់) ។ ការទទួលខុសត្រូវនេះ ត្រូវបានលើកមកសំអាងដោយអង្គការអាជីវកម្មសកល និងក្រុមហ៊ុនឯកជននានា នៅទូទាំងពិភពលោកផងដែរ។

គំនិតផ្តួចផ្តើមដោយស្ម័គ្រចិត្តផ្សេងៗ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ក៏ត្រូវបានចាប់ផ្តើមធ្វើផងដែរ។ ឧទាហរណ៍ដូចជា វេទិកាសកលរបស់អង្គការសហប្រជាជាតិ (គ្លូបលកំផែក)[២០] កំណត់គោលការណ៍ចំនួន ១០ ទាក់ទងនឹងសិទ្ធិមនុស្ស បទដ្ឋាន ការងារ បរិស្ថាន និងការប្រឆាំងនឹងអំពើពុករលួយ ដែលក្រុមហ៊ុនជាហត្ថលេខីបានសន្យាគោរពតាម។ ក្រុមហ៊ុនខ្លះ បានបង្កើតគោលនយោបាយ កម្មវិធី និងឧបករណ៍សិទ្ធិមនុស្សរបស់ខ្លួនផ្ទាល់ ដើម្បីធ្វើសមាហរណកម្មសិទ្ធិមនុស្សទៅក្នុងប្រតិបត្តិការធុរកិច្ចរបស់ខ្លួន។

## IV. ការឃ្លាំមើលសិទ្ធិមានលំនៅដ្ឋានសមរម្យ និង ការដាក់ឲ្យរដ្ឋទទួលខុសត្រូវ

យន្តការគណនេយ្យភាព មានសារៈសំខាន់ណាស់ ក្នុងការធានាថា រដ្ឋទាំងឡាយ ត្រូវគោរពកាតព្វកិច្ចរបស់ខ្លួន ចំពោះសិទ្ធិមានលំនៅដ្ឋានសមរម្យ។ ត្រូវមានការពិនិត្យតាមដាននៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ និងជំរុញឲ្យមានការចូលរួមពីតួអង្គពាក់ព័ន្ធផ្សេងៗ ដូចជា រដ្ឋខ្លួនឯងផ្ទាល់ សង្គមស៊ីវិល ស្ថាប័នសិទ្ធិមនុស្សជាតិ(NHRI) និងយន្តការសិទ្ធិមនុស្សអន្តរជាតិជាដើម។

### ក. គណនេយ្យភាព និងការឃ្លាំមើលថ្នាក់ជាតិ

គណនេយ្យភាព តម្រូវឲ្យរដ្ឋមួយ ពន្យល់អំពីអ្វីដែលខ្លួនកំពុងធ្វើ និងអំពីមូលហេតុ និងវិធីសាស្ត្រ ដែលខ្លួនកំពុងអនុវត្ត ឈានទៅសម្រេចបាននូវសិទ្ធិមានលំនៅដ្ឋានសមរម្យសម្រាប់មនុស្សគ្រប់រូប ឲ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ មិនចែងអំពីរូបមន្តជាក់លាក់ណាមួយ សម្រាប់យន្តការក្នុងស្រុក ទាក់ទងនឹងគណនេយ្យភាព និងការដោះស្រាយឡើយ។ គ្រប់យន្តការគណនេយ្យភាពទាំងអស់ យ៉ាងហោចណាស់ ត្រូវតែអាចរកបាន មានតម្លាភាព និងមានប្រសិទ្ធភាព។

---

[២០] http://www.unglobalcompact.org

*យន្តការរដ្ឋបាល គោលនយោបាយ និងនយោបាយ*

យន្តការរដ្ឋបាល និងយន្តការនយោបាយ គឺជាការបំពេញបន្ថែម ឬជាមធ្យោបាយស្របគ្នាមួយទៅនឹងយន្តការច្បាប់ ទាក់ទងនឹងគណនេយ្យភាព។ ឧទាហរណ៍ ការបង្កើតយុទ្ធសាស្ត្រ ឬគោលនយោបាយលំនៅដ្ឋានថ្នាក់ជាតិមួយ ដែលផ្សាភ្ជាប់ទៅនឹងផែនការការងារ និងថវិកាបដិភាគ ដើរតួនាទីមួយដ៏សំខាន់ក្នុងការធានាឲ្យរដ្ឋាភិបាលមានគណនេយ្យភាព។ សូចនាករផ្នែកសិទ្ធិមនុស្ស គាំទ្រដល់ការឃ្លាំមើលប្រកបដោយប្រសិទ្ធភាព លើលទ្ធផលសំខាន់ៗទាក់ទងនឹងលំនៅដ្ឋាន និងដំណើរការមួយចំនួន ដែលឈានទៅសម្រេចបាននូវលទ្ធផលទាំងនោះ។ម្យ៉ាងវិញទៀត ការវាយតម្លៃប្រភេទផ្សេងៗគ្នា មានដូចជា ការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្ស បើកផ្លូវឲ្យអ្នកធ្វើគោលនយោបាយ អាចប្រមើលមើលពីផលប៉ះពាល់ដែលអាចមាន នៃគោលនយោបាយដែលគ្រោងនឹងបង្កើតឡើងនោះ ហើយបន្ទាប់មកទៀត ធ្វើការពិនិត្យផលប៉ះពាល់ជាក់ស្តែងរបស់វា លើការប្រើប្រាស់សិទ្ធិមានលំនៅដ្ឋានសមរម្យ។

យន្តការនយោបាយ ដូចជា ដំណើរការលទ្ធិប្រជាធិបតេយ្យ ការឃ្លាំមើល និង ការតស៊ូមតិដោយតួអង្គឯករាជ្យ ក៏រួមចំណែកជួយពង្រឹងគណនេយ្យភាពផងដែរ។ អង្គការសង្គមស៊ីវិល និងអង្គការផ្សេងៗទៀត កំពុងតែបង្កើនការប្រើប្រាស់វិធីសាស្ត្រឃ្លាំមើល ដោយផ្អែកលើសូចនាករ ចំណុចគោល ការវាយតម្លៃផលប៉ះពាល់ និងការវិភាគលើថវិកា ដើម្បីដាក់ឲ្យរដ្ឋាភិបាលនានា ទទួលខុសត្រូវលើសិទ្ធិមានលំនៅដ្ឋានសមរម្យ។ សូចនាករ ជាពិសេសពេលដែលវាមិនត្រូវបានបំបែកចេញដោយមូលហេតុនៃការរើសអើង (ឧ. ភេទ) ផ្តល់នូវព័ត៌មានដ៏សំខាន់ អំពីរបៀបដែលសិទ្ធិមានលំនៅដ្ឋានសមរម្យអាចនឹងសម្រេចបាន ក្នុងបរិបទនៃប្រទេសមួយជាក់លាក់។ ការិយាល័យ OHCHR បានបង្កើតក្របខ័ណ្ឌទ្រឹស្តី និងវិធីសាស្ត្រមួយ សម្រាប់ប្រើប្រាស់សូចនាករ ដើម្បីលើកស្ទួយ និងឃ្លាំមើលការអនុវត្តន៍សិទ្ធិមនុស្ស ទាំងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ទាំងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

## ក្របខ័ណ្ឌមួយ ដែលបានស្នើឡើង សម្រាប់សូចនាករសិទ្ធិមនុស្ស

ក្របខ័ណ្ឌដែលបានអនុម័តដោយការិយាល័យOHCHR និងរិតតែជាក់លាក់ថែមទៀតនោះ គឺសំណុំសូចនាកររបស់ខ្លួន គួរតែកំណត់ពីការវាយតម្លៃលើវិធានការទាំងឡាយ ដែលរដ្ឋមួយបានចាត់ឡើង ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ចាប់ពីពេលដែលខ្លួនអនុម័តទទួលយកបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ (សូចនាករ*រចនាសម្ព័ន្ធ*) រហូតដល់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបំពេញកាតព្វកិច្ច ដែលមានលំហូរពីបទដ្ឋាន (សូចនាករ*ដំណើរការ*) ហើយបន្តរហូតដល់លទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងទាំងនោះ លើទស្សនវិស័យនៃប្រជាជនដែលរងផលប៉ះពាល់ (សូចនាករ*លទ្ធផល*)។ ឧទាហរណ៍នៃសូចនាករសម្រាប់សិទ្ធិមានលំនៅដ្ឋានសមរម្យ គឺកាលបរិច្ឆេទដាក់បញ្ចូលសិទ្ធិមានលំនៅដ្ឋានសមរម្យទៅក្នុងរដ្ឋធម្មនុញ្ញ (សូចនាករ*រចនាសម្ព័ន្ធ*) ថវិកាលៃបម្រុងសម្រាប់ចំណាយសាធារណៈលើលំនៅដ្ឋានសង្គម ឬសហគមន៍ (សូចនាករ*ដំណើរការ*) ចំណែកថវិកាសម្រាប់ប្រជាជនក្នុងទីប្រជុំជនដែលរស់នៅក្នុងតំបន់ក្រីក្រ និង/ឬ ករណីដែលបានរាយការណ៍អំពីការបណ្តេញចេញដោយបំពាន (សូចនាករ*លទ្ធផល*) ។ វាជាការសំខាន់ផងដែរ ក្នុងការបង្កើតសូចនាករ ដែលបំបែកទន្និន័យតាមក្រុម និងមូលហេតុនៃការរើសអើង ដែលអាចមាន ។

ក្របខ័ណ្ឌនេះ ត្រូវបានផ្តល់សុពលភាពតាមរយៈសិក្ខាសាលា និងកិច្ចប្រជុំពិគ្រោះយោបល់ ដែលរៀបចំឡើងដោយការិយាល័យ OHCHR ជាមួយអ្នកពាក់ព័ន្ធសិទ្ធិមនុស្សថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ រួមមាន អ្នកជំនាញការមកពីស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ទីភ្នាក់ងារជំនាញរបស់អង្គ

ការសហប្រជាជាតិ ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ(NHRIs) ទីភ្នាក់ងារស្ថិតិ និង អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត។ សូមមើល "របាយការណ៍ស្តីពីសូចនាករសម្រាប់ការលើកស្ទួយ និងការឃ្លាំមើលការអនុវត្តន៍សិទ្ធិមនុស្ស" (HRI/MC/២០០៨/៣)។ ចំពោះសិទ្ធិមានលំនៅដ្ឋានក្របខណ្ឌនេះក៏បានផ្អែកផងដែរ លើលទ្ធផលនៃគំនិតផ្តួចផ្តើមកន្លងមករបស់កម្មវិធីសិទ្ធិលំនៅដ្ឋានរបស់អង្គការសហប្រជាជាតិ ដើម្បីបង្កើតយន្តការឃ្លាំមើលជាសកលមួយ ដើម្បីធ្វើឲ្យសម្រេចបានជាលំដាប់នូវសិទ្ធិមានលំនៅដ្ឋានសមរម្យ។ កម្មវិធីសិទ្ធិលំនៅដ្ឋានរបស់អង្គការសហប្រជាជាតិ "ឯកសារការងារលេខ ២ ៖ សូចនាករសិទ្ធិមានលំនៅដ្ឋាន៖ ការវាស់វែងអំពីការសម្រេចបានជាលំដាប់នូវសិទ្ធិមានលំនៅដ្ឋានសមរម្យ" (នឹងមានក្នុងពេលឆាប់ៗនេះ)។

*យន្តការច្បាប់*

យន្តការច្បាប់ គឺជាសមាសធាតុមួយដ៏សំខាន់នៃវិធានការពង្រឹងការអនុវត្តន៍ច្បាប់ក្នុងស្រុក ដោយវាផ្តល់នូវដំណោះស្រាយសមរម្យដល់បុគ្គលទាំងឡាយ ប្រសិនបើសិទ្ធិមានលំនៅដ្ឋានសមរម្យរបស់គេ ត្រូវបានរងការរំលោភបំពាន។

ការបញ្ចូលទៅក្នុងច្បាប់ជាតិ នូវលិខិតុបករណ៍អន្តរជាតិ ដែលទទួលស្គាល់សិទ្ធិមានលំនៅដ្ឋានសមរម្យ អាចជួយពង្រីក និងបង្កើនវិធានការដោះស្រាយយ៉ាងច្រើន។ វាជួយសម្រួលដល់តុលាការ ក្នុងការវិនិច្ឆ័យលើករណីរំលោភបំពានផ្សេងៗ ដោយយោងផ្ទាល់ទៅលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋធម្មនុញ្ញ ឬ ច្បាប់ជាក់លាក់ ដែលទទួលស្គាល់ ឬ ដែលបញ្ចូលសមាសភាគមួយចំនួននៃសិទ្ធិមានលំនៅដ្ឋានសមរម្យ។ តុលាការក្នុងស្រុក នឹងជំនុំជម្រះរឿងក្តីបែបនេះកាន់តែច្រើនឡើងៗ។

ឧទាហរណ៍គួរឲ្យកត់សម្គាល់មួយ ទទួលបានពី**តុលាការធម្មនុញ្ញនៃប្រទេសអាហ្វ្រិកខាងត្បូង** ក្នុងសំណុំរឿងរវាង *រដ្ឋាភិបាលនៃសាធារណរដ្ឋអាហ្វ្រិកខាងត្បូង និងជាមួយអ្នកផ្សេងទៀត និងអ្នកនាង Grootboom និងអ្នកដទៃទៀត។*

អ្នកនាង Grootboom និងអ្នកដទៃទៀត ដែលត្រូវបានគេបណ្តេញចេញពីដីឯកជន ហើយទៅរស់នៅតាមចិញ្ចើមនៃទីធ្លាកីឡាដ្ឋានក្នុងស្ថានភាពយ៉ាប់យ៉ឺនពន់ពេកនោះ បានដាក់ពាក្យបណ្តឹងទាមទារឲ្យរកដំណោះស្រាយជាបន្ទាន់ ខណៈពេលដែលភ្លៀងរដូវរងារបានធ្វើឲ្យទីជម្រកបណ្តោះអាសន្នរបស់ពួកគេគ្មានស្ថិរភាព។ តុលាការបានកំណត់ថា បើទោះបីជាមានច្បាប់ និងគោលនយោបាយទូលំទូលាយស្តីពីលំនៅដ្ឋានរួចហើយនៅក្នុងគោលដៅបង្កើនការធ្វើឲ្យសម្រេចបានសិទ្ធិមានលំនៅដ្ឋានសមរម្យក្តី ក៏ច្បាប់ និងគោលនយោបាយទាំងនេះ មិនបានគិតគូដល់ស្ថានភាពជាក់ស្តែងរបស់ប្រជាជនដែលមានសេចក្តីត្រូវការជាបន្ទាន់ឡើយ។ តុលាការបានអនុវត្តសាកល្បងមើលភាពសមហេតុផលនៃគោលនយោបាយលំនៅដ្ឋាន ហើយបានសន្និដ្ឋានថា គោលនយោបាយនេះ មិនបានឆ្លើយតបទៅនឹងការសាកល្បងនេះទេ ដោយហេតុថា ផ្នែកសមស្របមួយនៃកញ្ចប់ថវិកាជាតិសម្រាប់លំនៅដ្ឋាន មិនត្រូវបានផ្តល់ឲ្យប្រជាជនដែលមានសេចក្តីត្រូវការបន្ទាន់នោះឡើយ។ តុលាការ បានរកឃើញថា បើទោះជារដ្ឋមិនមានកាតព្វកិច្ចផ្តល់លំនៅដ្ឋានភ្លាមៗបន្ទាប់ពីមានការស្នើសុំក្តី ក៏រដ្ឋមានកាតព្វកិច្ចត្រូវផ្តល់ជំនួយសង្គ្រោះដល់ប្រជាជនដែលមានសេចក្តីត្រូវការបន្ទាន់ទាំងនោះដែរ។ ម្យ៉ាង

វិញទៀត តុលាការបានបញ្ជាក់ថា កាតព្វកិច្ចធ្វើឲ្យសម្រេចបានជាលំដាប់នូវសិទ្ធិមានលំនៅដ្ឋានសមរម្យ គឺរាប់បញ្ចូលទាំង កាតព្វកិច្ចបន្ទាន់ ក្នុងការតាក់តែង និងអនុម័តផែនការសកម្មភាព ដើម្បីបង្កើតធនធានថវិកាសមស្រប ឈានទៅអនុវត្តផែនការនោះ។

**ជំនួយតាមផ្លូវច្បាប់ និងការទទួលបានដំណោះស្រាយ**
ជនរងគ្រោះដោយការរំលោភបំពានលើសិទ្ធិមានលំនៅដ្ឋានសមរម្យ ភាគច្រើនជាក្រុមជនក្រីក្រខ្លាំង និងជនដែលត្រូវបានគេរើសអើង មានដូចជា ជនក្រីក្រតាមទីក្រុង និងទីជនបទ ជាតិពន្ធុ ឬជនភាគតិច ជនជាតិដើមភាគតិច ទេសន្តរប្រវេសន៍ ជនចំណាកស្រុកមិនអចិន្ត្រៃយ៍ ជនចំណាកស្រុកក្នុងប្រទេស ឬ ស្ត្រី។ ការផ្តល់ជំនួយតាមផ្លូវច្បាប់ អាចធានាឲ្យជនរងគ្រោះទាំងនោះ មានលទ្ធភាពទទួលបានដំណោះស្រាយ ចំពោះករណីនៃការរំលោភបំពានលើសិទ្ធិមានលំនៅដ្ឋានសមរម្យ។ ពុំនោះទេ ពួកគេ អាចនឹងត្រូវជ្រើសរើសរវាងការបង់ប្រាក់ទៅតុលាការ និងការបញ្ជូនកូនរបស់ខ្លួនទៅសាលារៀន។

ដើម្បីធានាឲ្យដំណោះស្រាយតាមផ្លូវច្បាប់មានប្រសិទ្ធភាព វាគឺជាការសំខាន់ចាំបាច់ណាស់ដែលប្រព័ន្ធតុលាការមានដំណើរការល្អ និងឯករាជ្យ។ ចៅក្រម និងមេធាវី ត្រូវតែអាចបំពេញការងាររបស់ខ្លួនដោយមិនលំអៀង ផ្អែកលើអង្គហេតុ និងអនុលោមតាមច្បាប់ ដោយមិនទទួលឥទ្ធិពល ការគម្រាមកំហែង ឬការជ្រៀតជ្រែកមិនសមស្រប។ មន្ត្រីតុលាការ មេធាវី និងអ្នកវិជ្ជាជីវៈច្បាប់ដទៃទៀត ត្រូវមានសមត្ថភាពបំពេញតួនាទី និងទទួលខុសត្រូវចំពោះទង្វើខុសឆ្គងរបស់ខ្លួន។

*ស្ថាប័នសិទ្ធិមនុស្សជាតិ*

ស្ថាប័នសិទ្ធិមនុស្សជាតិ(NHRI) ផ្តល់យោបល់ដល់រដ្ឋាភិបាល និងស្នើឲ្យមានការកែប្រែគោលនយោបាយ ឬច្បាប់ ទទួលពាក្យបណ្តឹង បើកការស៊ើបអង្កេត ធានាការផ្តល់សច្ចាប័ន និងការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងផ្តល់ការបណ្តុះបណ្តាល និងការអប់រំជាសាធារណៈ។[៧១] ពេលខ្លះស្ថាប័នសិទ្ធិមនុស្សជាតិ(NHRI) មានមុខងារក្នុងការដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ និងអាណត្តិមួយដែលអនុញ្ញាតឲ្យពួកគេរួមចំណែកក្នុងការបង្កើតច្បាប់។ ស្ថាប័ននេះភាគច្រើនត្រូវគេហៅថា គណៈកម្មការ ឬ អំបុតស្មាន (ombudsmen) ។

**គណៈកម្មការសិទ្ធិមនុស្សជាតិ និងសិទ្ធិមានលំនៅដ្ឋានសមរម្យ ៖ ឧទាហរណ៍មួយចំនួន**

*គណៈកម្មការសិទ្ធិមនុស្ស និងសមភាពកាលានុវត្តភាពរបស់ប្រទេសអូស្ត្រាលី* មានរបៀបអនុវត្តល្អមួយ ក្នុងការស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្សជាប្រព័ន្ធ ជាពិសេស សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ការស៊ើបអង្កេតដំបូង ពាក់ព័ន្ធនឹងសិទ្ធិរបស់កុមារអនាថា។ នៅក្នុងរបាយការណ៍ឆ្នាំ១៩៨៩ មានចំណងជើងថា *កុមារអនាថារបស់យើង ៖ របាយការណ៍ស៊ើបអង្កេតថ្នាក់ជាតិ អំពីកុមារអនាថា* គណៈកម្មាធិការបានផ្តល់នូវកម្រងអនុសាសន៍ពិស្តារមួយចំនួនធំដល់រដ្ឋាភិបាលជាតិ និងរដ្ឋរបស់អូស្ត្រាលី ព្រមទាំងអង្គការ

[៧១] សូមមើលសេចក្តីសម្រេចរបស់មហាសន្និបាតលេខ៤៨/១៣៤ ស្តីពីស្ថាប័នជាតិសម្រាប់ការការពារ និងការលើកកម្ពស់សិទ្ធិមនុស្ស ("គោលការណ៍ទីក្រុងប៉ារីស")។

ឯកជន និងអង្គការសហគមន៍។ ក្នុងនោះ គណៈកម្មាធិការបាន ណែនាំថា "នៅពេលមានកុមារ និងយុវវ័យ ចាកចេញ ឬអាចចាក ចេញពីផ្ទះរបស់ខ្លួន ដោយសារតែការព្រងើយកន្តើយ ឬ ការរំលោភ បំពានធ្ងន់ធ្ងរនោះ Commonwealth គួរបំពេញកាតព្វកិច្ចជួយឧបត្ថម្ភ ដល់ពួកគេ ដោយមិនគិតពីអាយុ ក្នុងលក្ខខណ្ឌដែលពួកគេត្រូវបាន ការពារ និងអាចលូតលាស់បាន ដូចមានចែងក្នុងសេចក្តីប្រកាសស្តីពី សិទ្ធិកុមារ"។ របាយការណ៍នេះ បានលើកកម្ពស់ការយល់ដឹងរបស់ សហគមន៍ អំពីភាពគ្មានផ្ទះសម្បែងរបស់កុមារថា គឺជាបញ្ហាសិទ្ធិ មនុស្ស ហើយបានលើកកម្ពស់ការរំពឹងទុករបស់សាធារណៈជន អំពី សកម្មភាពកាន់តែមានប្រសិទ្ធភាពរបស់រដ្ឋាភិបាល ក្នុងការដោះ ស្រាយនូវកង្វល់សេចក្តីត្រូវការរបស់កុមារ។

*គណៈកម្មាការសិទ្ធិមនុស្សជាតិនៃប្រទេសកេនយ៉ា* មានកម្មវិធីជាក់ លាក់មួយ សម្រាប់ឃ្លាំមើលការធ្វើឲ្យសម្រេចបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ លើកស្ទួយសិទ្ធិទាំងនេះ ដោះស្រាយការ រំលោភបំពានសិទ្ធិទាំងនេះ ព្រមទាំងធ្វើការស្រាវជ្រាវ និងរៀបចំ របាយការណ៍ស្តីពី បញ្ហាទាំងឡាយទាក់ទងនឹងការប្រើប្រាស់សិទ្ធិ នេះ ។ ដោយវាជាផ្នែកមួយនៃការផ្តោតការយកចិត្តទុកដាក់ គណៈក ម្មាធិការនេះ បាននិងកំពុងធ្វើការគួរឲ្យកត់សម្គាល់លើបញ្ហានៃការ បណ្តេញចេញដោយបំពាន និងតំបន់រស់នៅមិនទាន់រៀបរយ។ បន្ថែមពីនេះ គណៈកម្មាធិការនេះ ក៏បាននិងកំពុងធ្វើការជាមួយ ក្រសួង និងអង្គការជាច្រើន ដែលធ្វើសកម្មភាពផ្នែកលំនៅដ្ឋាន ដើម្បី បង្កើតគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់បង្ការ និងដោះស្រាយ បញ្ហានៃការបណ្តេញចេញ។

នៅប្រទេសខ្លះ ស្ថាប័នសិទ្ធិមនុស្សជាតិ(NHRI) បាននិងកំពុងផ្តោតការងាររបស់ខ្លួនបន្ថែមទៀត លើការធានាការការពារសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ក្នុងនោះ ពួកគេអាចផ្តល់មធ្យោបាយផ្សេងទៀត សម្រាប់ការពារសិទ្ធិមានលំនៅដ្ឋានសមរម្យ។

បន្ថែមពីលើការងាររបស់ស្ថាប័នសិទ្ធិមនុស្សជាតិ(NHRI) រដ្ឋមួយចំនួនបានបង្កើតវិធីសាស្រ្តថ្មីៗផ្សេងទៀត ដើម្បីការពារ និងលើកស្ទួយសិទ្ធិលំនៅដ្ឋានក្នុងការអនុវត្តន៍ជាក់ស្តែង។

**អ្នករាយការណ៍ជាតិ ស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ**

ដោយមានការជម្រុញពីប្រព័ន្ធនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ (ដូចបានរៀបរាប់ខាងក្រោម) ប្រទេសប្រេស៊ីល បានបង្កើតអ្នករាយការណ៍ជាតិ ដើម្បីឃ្លាំមើលការអនុវត្តន៍សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៅទូទាំងប្រទេសនេះ។ ក្នុងនោះ ម្នាក់ក្នុងចំណោមអ្នករាយការណ៍ជាតិទាំងនេះ ផ្តោតទៅលើសិទ្ធិមានលំនៅដ្ឋានសមរម្យ និងដីនៅតំបន់ទីប្រជុំជន ដែលអាចទទួលពាក្យបណ្តឹងពីបុគ្គល និងសហគមន៍ផ្សេងៗដែលអះអាងថា មានការរំលោភបំពាន បំពេញបេសកម្មស៊ើបអង្កេតលើករណីរំលោភបំពាន និងផ្តល់អនុសាសន៍ជាក់លាក់មួយចំនួនទាក់ទងនឹងសិទ្ធិមានលំនៅដ្ឋានសមរម្យ ជូនទៅរដ្ឋាភិបាលប្រេស៊ីល។

សូមមើល OHCHR, សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ៖ សៀវភៅណែនាំសម្រាប់ស្ថាប័នសិទ្ធិមនុស្សជាតិ ការបណ្តុះបណ្តាលជំនាញ លេខ ១២ (បោះពុម្ពដោយអង្គការសហប្រជាជាតិ សម្រាប់លក់ លេខ E.0៤.XIV.៨)

## ខ.	គណនេយ្យភាពថ្នាក់តំបន់

សន្ធិសញ្ញា និងអនុសញ្ញាសិទ្ធិមនុស្សថ្នាក់តំបន់មួយចំនួន បានទទួលស្គាល់សិទ្ធិមានលំនៅដ្ឋានសមរម្យ។

តុលាការ និងស្ថាប័នឃ្លាំមើលសន្ធិសញ្ញាទាំងនេះ ជាពិសេស គណៈកម្មការអាហ្វ្រិកផ្នែកសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ គណៈកម្មការសិទ្ធិមនុស្សអន្តរអាមេរិក តុលាការសិទ្ធិមនុស្សអន្តរអាមេរិក និងគណៈកម្មាធិការអឺរ៉ុបផ្នែកសិទ្ធិសង្គមកិច្ច បានដើរតួនាទីដ៏សំខាន់ក្នុងការការពារសិទ្ធិមានលំនៅដ្ឋានសមរម្យ និងបានបង្កើតយុត្តាធិការជាក់លាក់ទាក់ទងនឹងសិទ្ធិនេះ។

### ការសម្លាប់រង្គាលនៅទីក្រុង Ituango ប្រទេសកូឡុំប៊ី

ករណីសម្លាប់រង្គាលនៅទីក្រុង *Ituango ប្រទេសកូឡុំប៊ី ពាក់ព័ន្ធនឹងការបណ្តេញចេញដោយបំពាន ការផ្លាស់ទីលំនៅ និងការបំផ្លិចបំផ្លាញលំនៅដ្ឋាននៅទីក្រុង* Ituango (ស្រុក La Granja និងស្រុក El Aro) ក្នុងប្រទេសកូឡុំប៊ីពីសំណាក់កងជីវពល ដែលមានសម្ព័ន្ធភាពជាមួយរដ្ឋាភិបាល។ ករណីនេះ មានអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរ បានលើកឡើងថា ជាការរំលោភបំពានលើសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ រាប់ទាំងការបណ្តេញចេញដោយបំពាន អមដោយអំពើហិង្សាកម្រិតខ្ពស់ផងដែរ។

ក្នុងខែកក្កដា ឆ្នាំ២០០៦ តុលាការអន្តរអាមេរិក បានរកឃើញថា មានការបណ្តេញចេញដោយបំពាន និងការបំផ្លិចបំផ្លាញលំនៅដ្ឋានដែលបានបំពានលើមាត្រា ១១ (២) (សិទ្ធិរួចផុតពីការជ្រៀតជ្រែកតាមទំនើងចិត្ត ឬ ដោយបំពានទៅលើលំនៅដ្ឋាន) និងមាត្រា ២១ (សិទ្ធិលើអចលនទ្រព្យ) នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស។ តុលាការនេះ បានយល់ឃើញថា ផលប៉ះពាល់នៃការបំផ្លិចបំផ្លាញ

លំនៅដ្ឋាន គឺជាការខាតបង់ ដែលមិនត្រឹមតែចំពោះទ្រព្យសម្បត្តិជាសម្ភារៈប៉ុណ្ណោះទេ តែថែមទាំងចំពោះក្របខណ្ឌសង្គមដែលជាទីពឹងពាក់របស់អ្នករស់នៅ។ តុលាការនេះ បានបញ្ជាក់ផងដែរថា ទង្វើនេះ បានបង្កើតការជ្រៀតជ្រែករំខានធ្ងន់ធ្ងរ មិនសមរម្យ និងដោយបំពានទៅលើជីវិត និងលំនៅដ្ឋានឯកជនរបស់ជនរងគ្រោះ។

ស្នងការសិទ្ធិមនុស្សរបស់ក្រុមប្រឹក្សាអឺរ៉ុប ដែលត្រូវបានផ្តល់អាណត្តិលើកកម្ពស់ការយល់ដឹង និងការគោរពសិទ្ធិមនុស្សនៅក្នុងរដ្ឋសមាជិករបស់ខ្លួននោះ ក៏បានលើកឡើងផងដែរអំពីការប្រើប្រាស់សិទ្ធិមានលំនៅដ្ឋានសមរម្យ ជាពិសេស ទាក់ទងនឹងការរើសអើងប្រឆាំងនឹងក្រុមជាក់លាក់មួយចំនួន។

## គ. ការឃ្លាំមើលថ្នាក់អន្តរជាតិ

*ស្ថាប័នសន្ធិសញ្ញាអង្គការសហប្រជាជាតិ*

ការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗរបស់អង្គការសហប្រជាជាតិត្រូវបានឃ្លាំមើលដោយគណៈកម្មាធិការនានានៃអ្នកជំនាញការឯករាជ្យ ដែលជារឿយៗសំដៅលើ*ស្ថាប័នសន្ធិសញ្ញា* ដូចជា គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ជាដើម។ គណៈម្មាធិការទាំងនេះ បានចេញទាំងសេចក្តីសង្កេតចុងក្រោយ ស្តីពីរបាយការណ៍ទៀងទាត់របស់រដ្ឋភាគី និង*សេចក្តីពន្យល់រួមតាមគោលរឿង*។

គណៈកម្មាធិការមួយចំនួន បានចេញសេចក្តីសង្កេតចុងក្រោយ ដែលលើកឡើងអំពីសិទ្ធិមានលំនៅដ្ឋានសមរម្យនេះ បន្ថែមពីលើគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ គណៈកម្មាធិការសិទ្ធិមនុស្ស បានពិចារណាលើសិទ្ធិមានលំនៅដ្ឋានសមរម្យ ពាក់ព័ន្ធនឹងគោលការណ៍មិន

រើសអើង និងការការពារប្រឆាំងនឹងការជ្រៀតជ្រែកមិនស្របច្បាប់ទៅលើសិទ្ធិឯកជនរបស់បុគ្គលណាមួយ។[២២] គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ បានទាញចំណាប់អារម្មណ៍លើករណីនៃការរើសអើងពូជសាសន៍ ក្នុងការរារាំងជនភាគតិច ពីការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិមានលំនៅដ្ឋានសមរម្យ។[២៣] គណៈកម្មាធិការសិទ្ធិកុមារ បានលើកឡើងនូវបញ្ហាមួយចំនួនធំជុំវិញសិទ្ធិកុមារគ្រប់រូប ក្នុងការមានលំនៅដ្ឋានសមរម្យ រាប់ទាំង ស្ថានភាពរបស់កុមាររស់នៅតាមចិញ្ចើមថ្នល់ និងកុមារផ្លាស់ទីលំនៅ។[២៤] គណៈកម្មាធិការប្រឆាំងទារុណកម្ម បានលើកកង្វល់ផ្សេងៗអំពីរបៀបធ្វើការបណ្តេញចេញដោយបំពាន និងការតាំងទីលំនៅថ្មីរបស់សហគមន៍រ៉ូម៉ា ហើយបានផ្តល់ជាអនុសាសន៍មួយចំនួនផងដែរ។[២៥]

ម្យ៉ាងវិញទៀត គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មាធិការប្រឆាំងទារុណកម្ម គណៈកម្មាធិការបំបាត់ការរើសអើងពូជសាសន៍ គណៈកម្មាធិការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ គណៈកម្មាធិការពលករទេសន្តរប្រវេសន៍ គណៈកម្មាធិការសិទ្ធិជនពិការ និងគណៈកម្មាធិការប្រឆាំងការបាត់ខ្លួនដោយបង្ខំ (ដែលនៅមិនទាន់បានបង្កើតនៅឡើយ) មាន*យន្តការទទួលពាក្យបណ្តឹងពីបុគ្គល*។ ក្នុងករណីមួយចំនួនដែលបានបញ្ជូនមកខ្លួន គណៈកម្មាធិការប្រឆាំងទារុណកម្ម ជាអាទិ៍ បានសំដែងទស្សនៈថា ការបណ្តេញដោយបំពាន

[២២] មើល ឧទាហរណ៍ "សេចក្តីសង្កេតចុងក្រោយ របស់គណៈកម្មាធិការសិទ្ធិមនុស្ស៖ ប្រទេសព័រទុយហ្គាល់ "(CCPR/CO/៧៨/PRT).

[២៣] មើល ឧទាហរណ៍ "សេចក្តីសង្កេតចុងក្រោយ របស់គណៈកម្មាធិការបំបាត់ការរើសអើងពូជសាសន៍៖ ប្រទេសអ៊ុយក្រែន" (CERD/C/UKR/CO/១៨).

[២៤] មើល ឧទាហរណ៍ "សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារ ៖ ប្រទេសកូឡុំប៊ី" (CRC/C/15/Add.១៣៧).

[២៥] មើល ឧទាហរណ៍ "សេចក្តីសន្និដ្ឋាន និងអនុសាសាន៍របស់គណៈកម្មាធិការប្រឆាំងទារុណកម្ម ៖ ប្រទេសក្រិច" (CAT/C/CR/៣៣/២).

អាចចាត់ទុកថា ជាការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។[២៦] ក្នុងខែធ្នូ ឆ្នាំ២០០៨ មហាសន្និបាតបាន អនុម័តពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ពិធិសារនេះ អនុញ្ញាតឲ្យមានការដាក់ពាក្យបណ្តឹងលើ*គ្រប់*ទិដ្ឋ*ភាព*ទាំងអស់នៃសិទ្ធិមានលំនៅដ្ឋានសមរម្យ ដោយគ្មានកំណត់ចំពោះការរើស អើងលំនៅដ្ឋាន ឬចំពោះបញ្ហាទាំងឡាយដែលបានលើកឡើងដោយសន្ធិសញ្ញា ដទៃទៀតឡើយ។ ពិធីសារបន្ថែមនេះ នឹងចូលជាធរមាននៅពេលដែលរដ្ឋចំនួន ១០ បានផ្តល់សច្ចាប័ន។

*អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមានលំនៅដ្ឋាន សមរម្យ ជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ។*

"យន្តការនីតិវិធីពិសេស" គឺជាឈ្មោះទូទៅមួយ ដែលគេដាក់ឲ្យយន្តការ ដែលបានបង្កើតឡើងនេះ និងបានផ្តល់អាណត្តិឲ្យដោយគណៈកម្មការសិទ្ធិ មនុស្ស និងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សចាប់ពីខែមីនា ឆ្នាំ២០០៦ មក សម្រាប់ ដោះស្រាយបញ្ហាជាកង្វល់ទាំងឡាយដែលកើតមាននៅគ្រប់ទិសទីលើពិភព លោក។ ទោះបីជាអាណត្តិរបស់អ្នករាយការណ៍ពិសេសទាំងនោះ មានលក្ខណៈ ខុសប្លែកពីគ្នាក្តី ក៏ពួកគេតែងតែឃ្លាំមើល ត្រួតពិនិត្យ និងរាយការណ៍ជាសាធារ ណៈអំពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសជាក់លាក់ ឬ អំពីបញ្ហាសិទ្ធិ មនុស្សធំៗនៅទូទាំងពិភពលោក។

ក្នុងសេចក្តីសម្រេចចិត្តរបស់ខ្លួនលេខ ២០០០/៩ គណៈកម្មការនេះ បានបង្កើតអាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសម រម្យ ជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ និងស្តីពីសិទ្ធិគ្មានការ

[២៦] មើលគណៈកម្មាធិការប្រឆាំងទារុណកម្ម សេចក្តីសំរេចលើបណ្តឹងលេខ ១៦១/២០០០, *Hajrizi Dzemajl et al.* v. *ប្រទេសសាប៊ីយ៉ា និងម៉ុងតេណេហ្គ្រូ*, ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០០២ (A/៥៨/៤៤).

រើសអើងក្នុងបរិបទនេះ ដែលអាណត្តិនេះត្រូវបានបន្តជាថ្មី ដោយសេចក្តីសម្រេចចិត្តលេខ ៦/២៧ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ លោក **មីលូន គូតារី** ត្រូវបានតែងតាំងជាអ្នករាយការណ៍ពិសេសទីមួយ នៅឆ្នាំ២០០០។ អ្នកទទួលអណត្តិបន្តពីលោកគឺ លោកស្រី **រ៉ាគែល រ៉ូនីក** ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សតែងតាំងនៅក្នុងឆ្នាំ២០០៨។

**អាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ**

- លើកកម្ពស់ការអនុវត្តន៍ឲ្យសម្រេចបានយ៉ាងពេញលេញនូវសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ។
- កំណត់វិធីអនុវត្តដែលប្រសើរបំផុត ព្រមទាំង បញ្ហាប្រឈម និងឧបសគ្គផ្សេងៗ ដល់ការសម្រេចបានពេញលេញនូវសិទ្ធិមានលំនៅដ្ឋានសមរម្យ និងកំណត់ភាពចន្លោះប្រហោងនៃការការពារក្នុងបញ្ហានេះ។
- សង្កត់ធ្ងន់ជាពិសេស លើការដោះស្រាយជាក់ស្តែង ចំពោះការអនុវត្តន៍សិទ្ធិដែលទាក់ទងនឹងអាណត្តិនេះ។
- អនុវត្តទស្សនវិស័យយេនឌ័រ រួមទាំង តាមរយៈការកំណត់អត្តសញ្ញាណនៃភាពងាយរងគ្រោះជាក់លាក់នៃយេនឌ័រ ពាក់ព័ន្ធនឹងសិទ្ធិមានលំនៅដ្ឋានសមរម្យ និងដីធ្លី។
- ជួយសម្រួលដល់ការផ្តល់ជំនួយបច្ចេកទេស ។

វិធីសាស្ត្រធ្វើការងាររបស់អ្នករាយការណ៍ពិសេស រួមមាន ការបំពេញបេសកកម្មតាមប្រទេស ការស៊ើបអង្កេតបញ្ហាដែលជាកង្វល់ ការពិនិត្យឡើងវិញលើបណ្តឹងរបស់បុគ្គល ឬក្រុម ដែលអះអាងថា មានការរំលោភបំពានលើសិទ្ធិ

មានលំនៅដ្ឋានសមរម្យ ការធ្វើអន្តរាគមន៍ទៅរដ្ឋាភិបាល ប្រសិនបើសមស្រប ទាក់ទងនឹងការរំលោភបំពានដែលបានអះអាងនោះ ហើយរាយការណ៍ជារៀង រាល់ឆ្នាំជូនមហាសន្និបាត និងក្រុមប្រឹក្សាសិទ្ធិមនុស្ស។

ការងាររបស់អ្នករាយការណ៍ពិសេស កន្លងមកបានផ្ដោតលើ៖ ស្ថានភាព ច្បាប់ និងខ្លឹមសារនៃសិទ្ធិមានលំនៅដ្ឋានសមរម្យ, ភាពគ្មានផ្ទះសម្បែង, ការ បណ្ដេញចេញដោយបំពាន, សកលភាវូបនីយកម្ម និងសិទ្ធិមានលំនៅដ្ឋាន សមរម្យ, ការរើសអើង និងការទទួលបានពេញលេញសិទ្ធិមានលំនៅដ្ឋានសម រម្យ, ការបង្កើតនូវសូចនាករ, លទ្ធភាពប្រើប្រាស់ទឹក និងសេវាអនាម័យដែលជា សមាសភាពនៃការប្រើប្រាស់សិទ្ធិមានលំនៅដ្ឋានសមរម្យ, និងសិទ្ធិស្ត្រីក្នុងការ មានលំនៅដ្ឋានសមរម្យ។

អ្នករាយការណ៍ពិសេស ទទួលព័ត៌មានពីបុគ្គល និងក្រុមផ្សេងៗ ហើយ ឆ្លើយតបទៅពួកគេវិញតាមការគួរ។ លោក/អ្នក អាចទំនាក់ទំនងទៅគាត់បាន តាមរយៈការិយាល័យ OHCHR ៖

**អ្នករាយការណ៍ពិសេស របស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិមាន លំនៅដ្ឋានសមរម្យ**

OHCHR–UNOG
8-14 avenue de la Paix
CH–1211 Geneva 10
Switzerland
E-mail: urgent-action@ohchr.org

សិទ្ធិមានលំនៅដ្ឋានសមរម្យ ក៏ជាកង្វល់មួយរបស់ យន្តការនីតិវិធីពិសេសជាច្រើនផ្សេងទៀតផងដែរ ហើយយន្តការនេះមួយចំនួន បានទទួលដោះស្រាយបញ្ហាដែលទាក់ទងនឹងអាណត្តិជាក់លាក់របស់ខ្លួន។[២៧]

*ក្រុមប្រឹក្សាយោបល់លើការបណ្តេញចេញដោយបំពាន*

ក្នុងឆ្នាំ២០០៤ អង្គការUN-Habitat បានបង្កើតក្រុមប្រឹក្សាយោបល់ផ្នែកការបណ្តេញចេញដោយបំពាន ដើម្បីឃ្លាំមើលការបណ្តេញចេញមិនស្របច្បាប់ ដើម្បីកំណត់ និងបង្កើនជម្រើសផ្សេងៗ ដូចជា ការលើកម្ពស់ និងការសម្របសម្រួលការតាំងទីលំនៅថ្មីជាដើម។ ក្រុមប្រឹក្សាយោបល់រាយការណ៍ជូននាយកប្រតិបត្តិរបស់អង្គការ UN-Habitat។ ក្រុមនេះ មានអ្នកជំនាញការមកពីអង្គការអន្តររដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន រដ្ឋាភិបាលថ្នាក់ជាតិ សង្គមស៊ីវិល និងអ្នកជំនាញការនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍។

ចាប់ពីបានបង្កើតមក ក្រុមប្រឹក្សាយោបល់នេះ បានបំពេញបេសកកម្មស្វែងរកការពិតមួយចំនួន ទៅកាន់ទីក្រុងអាក្រា ទីក្រុងបូនូសអៀរ៉េស ទីក្រុងយ្សួរីធីបា(ប្រេស៊ីល) ទីក្រុងអ៊ីស្តាន់ប៊ូល(ទួគី) ទីក្រុងញូអ័រឡិនស៍(សហរដ្ឋអាមេរិក) ទីក្រុងផតហារខត(នីសេ្សរីយ៉ា) ទីក្រុងរ៉ូម និងទីក្រុងសាន់តូដូមីនហ្គូ។ នៅក្នុងរបាយការណ៍រៀងរាល់ពីរឆ្នាំម្តងលើកដំបូង ទាំងពីររបស់ខ្លួន មានចំណងជើងថា *ការបណ្តេញចេញដោយបំពាន ការឈានឆ្ពោះទៅរកដំណោះស្រាយ?* ដែលបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០០៥ និងឆ្នាំ២០០៧ នោះ ក្រុមប្រឹក្សាយោបល់នេះ បានចងក្រងករណីទាក់ទងនឹងការបណ្តេញចេញដោយបំពាន ដែលកំពុងកើតមាន ឬដែលនឹងកើតមាន នៅក្នុងប្រទេសមួយចំនួន និងបានបង្ហាញអំពីវិធីសាស្ត្រដោះស្រាយផ្សេងៗគ្នាជាច្រើន។[២៨]

---

[២៧] សម្រាប់តារាងយន្តការនីតិវិធីពិសេសទាំងអស់ និងព័ត៌មានស្តីពីអាណត្តិរបស់ពួកគេ និងទំនាក់ទំនងលំអិត សូមមើលលើវិបសាយ http://www.ohchr.org

[២៨] របាយការទាំងពីរនេះ មាននៅលើវិសាយ http://www.unhabitat.org/unhrp

# ឧបសម្ព័ន្ធ

# លិខិតុបករណ៍អន្តរជាតិ ដែលបានជ្រើសសម្រាំង និងសំណុំឯកសារផ្សេងៗទៀត ទាក់ទងនឹងសិទ្ធិមានលំនៅដ្ឋានសមរម្យ

# (រៀបតាមលំដាប់កាលបរិច្ឆេទ)

## សន្ធិសញ្ញាអន្តរជាតិ

ធម្មនុញ្ញអង្គការសហប្រជាជាតិ (១៩៤៥)

អនុសញ្ញាស្តីពីឋានៈជនភៀសខ្លួន (១៩៥១)

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៩៦៦) និងពិធីសារបន្ថែមនៃកតិកាសញ្ញានេះ (២០០៨)

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦) និងពិធីសារបន្ថែមពីរទៀតនៃកតិកាសញ្ញានេះ (១៩៦៦ និង១៩៨៩)

អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (១៩៦៥)

អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប (១៩៨៤) និងពិធីសារបន្ថែមនៃអនុសញ្ញានេះ (២០០២)

អនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ(ILO) លេខ ១៦៩ ស្តីពីជនជាតិដើមភាគតិច និងពួកកុលសម្ព័ន្ធនៅក្នុងបណ្តាប្រទេសឯករាជ្យ(១៩៨៩)

អនុសញ្ញាស្តីពីសិទ្ធិកុមារ(១៩៨៩) និងពិធីសារបន្ថែមចំនួនពីរទៀតនៃអនុសញ្ញានេះ (២០០០)

អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ (១៩៩០)

អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (១៩៧៩) និងពិធីសារបន្ថែមនៃអនុសញ្ញានេះ (១៩៩៩)

អនុសញ្ញាស្តីពីសិទ្ធិជនពិការ(២០០៦) និងពិធីសារបន្ថែមនៃអនុសញ្ញានេះ (២០០៦)

## សន្ធិសញ្ញាថ្នាក់តំបន់

ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ (១៩៨១)

ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិ និងសុខុមាលភាពរបស់កុមារ (១៩៩០)

អនុសញ្ញាអឺរ៉ុប ដើម្បីការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (១៩៥០)

ធម្មនុញ្ញសង្គមអឺរ៉ុប (១៩៦១)

អនុសញ្ញាអឺរ៉ុបស្តីពីស្ថានភាពផ្លូវច្បាប់របស់ពលករទេសន្តរប្រវេសន៍(១៩៧៧)

ធម្មនុញ្ញសង្គមអឺរ៉ុបដែលបានកែសម្រួល (១៩៩៦)

អនុសញ្ញាអាមេរិក ស្តីពីសិទ្ធិមនុស្ស (១៩៦៩)

## សេចក្តីប្រកាសអន្តរជាតិ និងលិខិតុបករណ៍ដទៃទៀត

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)

គោលការណ៍អង្គការសហប្រជាជាតិសំរាប់មនុស្សចាស់ សេចក្តីសម្រេចចិត្តរបស់មហាសន្និបាត លេខ ៤៦/៩១ (១៩៩១)

គោលការណ៍ណែនាំស្តីពីការផ្លាស់ទីលំនៅក្នុងប្រទេស (១៩៩៨)

អនុសាសន៍របស់អង្គការពលកម្មអន្តរជាតិ(ILO) លេខ ១១៥ ស្តីពីលំនៅដ្ឋានរបស់កម្មករ (១៩៦១)

សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនជាតិដើមភាគតិច សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៦១/២៩៥ (២០០៧)

## ការណែនាំដោយយន្តការជំនាញសិទ្ធិមនុស្ស

គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេចក្តីពន្យល់រួមលេខ ៣ (១៩៩០) ស្តីពីចរិតលក្ខណៈនៃកាតព្វកិច្ចរបស់រដ្ឋភាគី (E/១៩៩១/២៣)

គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេចក្តីពន្យល់រួមលេខ ៤ (១៩៩១) ស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ (E/១៩៩២/២៣)

គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេចក្តីពន្យល់រួមលេខ ៥ (១៩៩៤) ស្តីពីជនពិការ (E/១៩៩៥/២២)

គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេចក្តីពន្យល់រួមលេខ ៧ (១៩៩៧) ស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ការបណ្តេញចេញដោយបំពាន (E/១៩៩៨/២២ ឧបសម្ព័ន្ធ ៦)

គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេចក្តីពន្យល់រួមលេខ ១៥ (២០០២) ស្តីពីសិទ្ធិទទួលបានទឹក (E/C.១២/២០០២/១១)

គណៈកម្មាធិការបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ សេចក្តីពន្យល់រួមលេខ ១៩ (១៩៩២) ស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ (A/៤៧/៣៨)

គណៈកម្មាធិការបំបាត់ការរើសអើងពូជសាសន៍ សេចក្តីពន្យល់រួមលេខ ២៣ (១៩៩៧) ស្តីពីជនជាតិដើមភាគតិច (A/៥២/១៨ ឧបសម្ព័ន្ធ ៥)

គោលការណ៍ស្តីពីបដិទានលើលំនៅដ្ឋាន និងទ្រព្យសម្បត្តិ សំរាប់ជនភៀសខ្លួន

និងជនចំណាកស្រុក (E/CN.៤/Sub.២/២០០៥/១៧/Add.១)

គោលការណ៍ និងគោលការណ៍ណែនាំជាមូលដ្ឋាន ស្តីពីការចាកចេញដោយបង្ខំចិត្ត និងការបណ្តេញចេញ ដើម្បីធ្វើការអភិវឌ្ឍន៍(A/HRC/៤/១៨ ឧបសម្ព័ន្ធ ១)

## សេចក្តីសម្រេចចិត្តផ្សេងៗរបស់គណៈកម្មការសិទ្ធិមនុស្ស និង ក្រុមប្រឹក្សាសិទ្ធិមនុស្ស

សេចក្តីសម្រេចចិត្តរបស់គណៈកម្មការ ២០០០/៩, ២០០១/២៨, ២០០២/២១, ២០០៣/២៧, ២០០៤/២១ ស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ

សេចក្តីសម្រេចចិត្តរបស់គណៈកម្មការ ១៩៩៣/៧៧ ស្តីពីការបណ្តេញចេញដោយបំពាន

សេចក្តីសម្រេចចិត្តរបស់គណៈកម្មការ ២០០០/១៣, ២០០១/៣៤, ២០០២/៤៩, ២០០៣/២២, ២០០៤/២១, ២០០៥/២៥ ស្តីពីសិទ្ធិកម្មសិទ្ធិស្មើគ្នារបស់ស្ត្រី ក្នុងការប្រើប្រាស់ និងការគ្រប់គ្រងដីធ្លី និងសិទ្ធិស្មើគ្នាក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងសិទ្ធិមានលំនៅដ្ឋានសមរម្យ

សេចក្តីសម្រេចចិត្តលេខ ៦/២៧ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យដែលជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ។

## ឯកសារផ្សេងៗទាក់ទងនឹងលទ្ធផលនៃសន្និសិទអន្តរជាតិ

សេចក្តីប្រកាសទីក្រុងអ៊ីស្តាន់ប៊ូល ស្តីពីការតាំងទីលំនៅរបស់មនុស្ស (១៩៩៦)

របៀបវារៈស្តីពីលំនៅដ្ឋាន (១៩៩៦)

សេចក្តីប្រកាសសហសវត្សរ៍អង្គការសហប្រជាជាតិ ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ "មហាសន្និបាតសហសវត្សរ៍របស់អង្គការ

សហប្រជាជាតិ" (២០០០)

សេចក្តីប្រកាសទីក្រុង Vancouver ស្តីពីការតាំងទីលំនៅសម្រាប់មនុស្ស (១៩៧៦)

សេចក្តីប្រកាសទីក្រុងរីយ៉ូ ស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ និងរបៀបវារៈ ២១ នៃសន្និបាតអង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ (១៩៩២)

សេចក្តីប្រកាសទីក្រុងវីយែន និងកម្មវិធីសកម្មភាព ដែលបានអនុម័តដោយសន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្ស (១៩៩៣)

## គេហទំព័រដែលបានជ្រើសរើស

### អង្គការអន្តររដ្ឋាភិបាល

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស http://www.ohchr.org

(គេហទំព័រនេះ មានព័ត៌មានទូទៅ និងធនធានឯកសារស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងមានគេហទំព័ររបស់ស្ថាប័នសន្និសញ្ញាសិទ្ធិមនុស្ស និងយន្តការនីតិវិធីពិសេស រាប់ទាំងអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ)។

កម្មវិធីអង្គការសហប្រជាជាតិ សម្រាប់លំនៅដ្ឋានមនុស្សជាតិ (UN-Habitat): http://www. unhabitat.org

កម្មវិធីសិទ្ធិលំនៅដ្ឋានរបស់អង្គការសហប្រជាជាតិ (UNHRP): http://www. unhabitat.org/unhrp

ក្រុមប្រឹក្សាយោបល់ស្តីពីការការបណ្តេញចេញដោយបំពានរបស់នាយកប្រតិបត្តិនៃអង្គការ UN-Habitat (AGFE): http://www.unhabitat.org/unhrp

កម្មវិធីផ្តល់លំនៅដ្ឋានដល់ជនក្រីក្រនៅតាមទីប្រជុំជន (គម្រោងរបស់គណៈកម្មការអង្គការសហប្រជាជាតិ សិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក): http://www.housing-the-urban-poor.net

ស្នងការសិទ្ធិមនុស្សនៃក្រុមប្រឹក្សាអឺរ៉ុប ttp://www.coe.int/t/commissioner

## អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ

អង្គការលើកលែងទោសអន្តរជាតិ http://www.amnesty.org

សម្ព័ន្ធអាស៊ី ដើម្បីសិទ្ធិមានលំនៅដ្ឋាន (ACHR): http://www.achr.net

មជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ (COHRE):

http://www.cohre.org

សហព័ន្ធអង្គការជាតិអឺរ៉ុបដែលធ្វើការងារជាមួយអ្នកគ្មានផ្ទះសម្បែង (FEANTSA): http://www.feantsa.org

មជ្ឈមណ្ឌលសិទ្ធិរ៉ូម៉ា អឺរ៉ុប (ERRC): http://www.errc.org

បណ្តាញសកម្មភាព និងព័ត៌មានអាហារបន្ទាន់ (FIAN): http://www.fian.org

សម្ព័ន្ធលំនៅដ្ឋានអន្តរជាតិ (HIC): http://www.hic-net.org

អង្គការអ្នកគ្មានលំនៅដ្ឋានអន្តរជាតិ: http://www.homeless-international.org

បណ្តាញសិទ្ធិដីធ្លី និងលំនៅដ្ឋាន (HLRN): http://www.hlrn.org/english/home.asp

អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW): http://www.hrw.org

គណៈកម្មការអ្នកច្បាប់អន្តរជាតិ (ICJ): http://www.icj.org

សហព័ន្ធអន្តរជាតិផ្នែកសិទ្ធិមនុស្ស (FIDH): http://www.fidh.org

បណ្តាញអន្តរជាតិផ្នែកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ESCRNet): http://www.escr-net.org

អង្គការអន្តរជាតិស្តីពីសហគមន៍អ្នកជួល(IUT): http://www.iut.nu

អង្គការអន្តរជាតិស្តីពីអ្នករស់នៅលើគំនររសំរាម/សំណង់មិនរៀបរយ(SDI): www.sdinet.org

អង្គការឃ្លាំមើលសង្គម: http://www.socialwatch.org

អង្គការពិភពលោកប្រឆាំងទារុណកម្ម (OMCT): http://www.omct.org

## ប័ណ្ណព័ត៌មានស្ដីពីសិទ្ធិមនុស្ស ៖*

លេខ. ២ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ (Rev.1)
លេខ. ៣ សេវាប្រឹក្សាយោបល់ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យ សិទ្ធិមនុស្ស (Rev.1)
លេខ.៤ ការប្រយុទ្ធប្រឆាំងទារុណកម្ម (Rev.1)
លេខ.៦ ការបាត់ខ្លួនដោយបង្ខំ និងដោយគ្មានការស្ម័គ្រចិត្ត (Rev.3)
លេខ.៧ នីតិវិធីបណ្ដឹង (Rev.1)
លេខ.៩ សិទ្ធិជនជាតិដើមភាគតិច (Rev.1)
លេខ.១០ សិទ្ធិកុមារ (Rev.1)
លេខ.១១ ការសម្លាប់ក្រៅប្រព័ន្ធតុលាការ ភ្លាមៗ ឬ តាមទំនើងចិត្ត (Rev.1)
លេខ.១២ គណៈកម្មាធិការបំបាត់រាល់ទំរង់នៃការរើសអើងពូជសាសន៍
លេខ.១៣ ច្បាប់មនុស្សធម៌អន្តរជាតិ និងសិទ្ធិមនុស្ស
លេខ.១៤ ទម្រង់ទាសភាពសហសម័យ
លេខ.១៥ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ៖ គណៈកម្មាធិការសិទ្ធិមនុស្ស (Rev.1)
លេខ.១៦ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (Rev.1)
លេខ.១៧ គណៈកម្មាធិការប្រឆាំងទារុណកម្ម
លេខ.១៨ សិទ្ធិជនភាគតិច (Rev.1)
លេខ.១៩ ស្ថាប័នជាតិលើកស្ទួយ និងការពារសិទ្ធិមនុស្ស
លេខ.២០ សិទ្ធិមនុស្ស និងជនភៀសខ្លួន
លេខ.២១ សិទ្ធិមានលំនៅដ្ឋានសមរម្យ (Rev.1)
លេខ.២២ ការរើសអើងប្រឆាំងស្ត្រីភេទ ៖ អនុសញ្ញា និងគណៈកម្មាធិការ

---

* ប័ណ្ណព័ត៌មានលេខ ១, ៥ និងលេខ ៨ មិនត្រូវបានចេញផ្សាយទៀតទេ។ ប័ណ្ណព័ត៌មានទាំងនេះ អាចរកបានតាមអ៊ិនធឺណេត http://www.ohchr.org.

លេខ.២៣ ការអនុវត្តន៍ជាប្រពៃណី ដែលប៉ះពាល់ដល់សុខភាពស្ត្រី និងកុមារ
លេខ.២៤ អនុសញ្ញាអន្តរជាតិស្តីពីពលករទេសន្តរប្រវេសន៍ និងគណៈកម្មាធិការរបស់ខ្លួន (Rev.1)
លេខ.២៥ ការបណ្តេញចេញដោយបំពាន និងសិទ្ធិមនុស្ស
លេខ.២៦ ក្រុមការងារផ្នែកការឃុំឃាំងតាមទំនើងចិត្ត
លេខ.២៧ សំណួរដប់ប្រាំពីរ ដែលត្រូវបានសួរជាញឹកញាប់ អំពីអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ
លេខ.២៨ ផលប៉ះពាល់លើសិទ្ធិស្វ័យសម្រេច នៃសកម្មភាពរកប្រាក់ចំណូល
លេខ.២៩ អ្នកការពារសិទ្ធិមនុស្ស ៖ ការការពារសិទ្ធិ ដើម្បីការពារសិទ្ធិមនុស្ស
លេខ.៣០ ប្រព័ន្ធសន្ធិសញ្ញាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ - ការណែនាំអំពីសន្ធិសញ្ញាសិទ្ធិមនុស្ស និងស្ថាប័នសន្ធិសញ្ញាសំខាន់ៗ
លេខ.៣១ សិទ្ធិសុខភាព
លេខ.៣២ សិទ្ធិមនុស្ស ភេរវកម្ម និងការប្រឆាំងភេរវកម្ម
លេខ.៣៣ សំណួរដែលត្រូវបានសួរជាញឹកញាប់អំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

*ប័ណ្ណព័ត៌មានស្តីពីសិទ្ធិមនុស្ស តាមឈុតបន្តបន្ទាប់* ត្រូវបានបោះពុម្ពផ្សាយដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅការិយាល័យអង្គការសហប្រជាជាតិ នាទីក្រុងហ្សឺណែវ។ *ប័ណ្ណព័ត៌មាននេះ* ដោះស្រាយបញ្ហាជម្រើសមួយចំនួនទាក់ទងនឹងសិទ្ធិមនុស្ស ដែលកំពុងស្ថិតក្រោមការពិនិត្យពិចារណាយ៉ាងសកម្ម និងដែលមានសារៈប្រយោជន៍យ៉ាងខ្លាំង។

*ប័ណ្ណព័ត៌មានស្តីពីសិទ្ធិមនុស្ស* ត្រូវបានចងក្រងឡើង ក្នុងគោលដៅជួយដល់អ្នកប្រើប្រាស់ទាំងឡាយ ឲ្យមានការយល់ដឹងបន្ថែមទៀត អំពីសិទ្ធិជាមូលដ្ឋាន កិច្ចការដែលអង្គការសហប្រជាជាតិកំពុងធ្វើ ដើម្បីលើកស្ទួយ និងការពារសិទ្ធិទាំងនោះ និងយន្តការអន្តរជាតិ ដែលមានសម្រាប់ជួយធ្វើឲ្យសម្រេចបានសិទ្ធិទាំងនោះ។ *ប័ណ្ណព័ត៌មានស្តីពីសិទ្ធិមនុស្ស* ត្រូវបានចែកជូនដោយឥតគិតថ្លៃនៅទូទាំងពិភពលោក។ ការបោះពុម្ពផ្សាយឡើងវិញនៃប័ណ្ណព័ត៌មាននេះ ជាភាសាផ្សេងក្រៅពីភាសាផ្លូវការរបស់អង្គសហប្រជាជាតិ ត្រូវបានជម្រុញលើកទឹកចិត្ត ដរាបណា ការបោះពុម្ពផ្សាយនោះ មិនមានការកែប្រែខ្លឹមសារដើមរបស់វា ហើយស្ថាប័នដែលបោះពុម្ពផ្សាយឡើងវិញនោះ ត្រូវជូនដំណឹង និងសុំការអនុញ្ញាតប្រើប្រាស់ប្រភពឯកសារ ពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នាទីក្រុងហ្សឺណែវ។

សម្រាប់ព័ត៌មានផ្សេងៗ សូមទំនាក់ទំនងមកៈ

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ
៨–១៤, Avenue de la Paix
CH–១២១១ ទីក្រុងក្រុងហ្សឺណែវ ១០
ប្រទេសស្វីស

ការិយាល័យនៅទីក្រុងញូវយ៉ក ៖
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
អង្គការសហប្រជាជាតិ
ទីក្រុងញូវយ៉ក, NY ១០០១៧
សហរដ្ឋអាមេរិក

បោះពុម្ពនៅអង្គការសហប្រជាជាតិ នាទីក្រុងហ្សឺណែវ ISSN ១០១៤-៥៥៦៧
GE.0៩-១៤៨៨៣– ខែ វិច្ឆិកា ឆ្នាំ ២០០៩–៩,២៤៥